ប្រជុំសន្ថរសម្ភីរ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ហិតោបទេស

ភាគទី ១

ការគប់មិត្ត



ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស. ២៥៣៧

២៤០.
៨៩

www.budinst.gov.kh www.elibraryofcambodia.org

ស្គាដែនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

ពុទ្ធសាសនបណ្ឌិត្យ និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

អង្គការរីហ្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ

ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា

ដែលបានគាំទ្រគម្រោងការស្កេនដែននេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

២៤០. ៤៩

នារាយណាបណ្ដិត

ស្ត្រី

ហិតោបទេស

ភាគទី ១

ការគប់មិត្ត

ភិក្ខុ ប៉ាង ខាត់ រិយបណ្ឌិតោ

ជា

អ្នកប្រែចេញពីភាសាសំស្ក្រឹត

បោះពុម្ពឡើងវិញ ចំនួន ៥.០០០ ក្បាល

INSTITUT BOUDDHIQUE

ព្រះពុទ្ធសាសនបណ្ឌិត្យ
LIBRARY
BUDDHIST INSTITUTE

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥៣៧ ត.ស ១៩៩៤

១៣៤១ / ៤៤

06.12

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីបញ្ជាក់

ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ " ស្រីហិតោបទេស " នេះ ត្រូវបានថតចម្លង និងបោះពុម្ពឡើងវិញ នៅឆ្នាំ១៩៩៤ ដោយមានការឧបត្ថម្ភពីអង្គការជំនួយសុត្តស៊ូជប៉ុន (JSRC) និងពីមូលនិធិ តេនដាយស៊ូ (TENDAISHU) ។

គោលចំណងនៃការបោះពុម្ពសៀវភៅនេះឡើងវិញ គឺសំដៅ :

- ផ្តល់អោយសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងអ្នកអានទូទៅ មានឧបករណ៍ សម្រាប់សិក្សា ស្រាវជ្រាវ យ៉ាងល្អប្រសើរ,

- រក្សាមតិកវប្បធម៌ អក្សរសាស្ត្រសាសនា អក្សរសាស្ត្រជាតិ អោយគង់វង្សឡើងវិញ និងរីកចំរើន,

- ពង្រីកចំណេះដឹងទូទៅខាងសីលធម៌ ក្នុងបណ្តាពលរដ្ឋកម្ពុជា ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ។

សូមឧទ្ទិសសៀវភៅ " ស្រីហិតោបទេស" នេះ ចំពោះការរីកចំរើនស្មារតីសិក្សា, ស្មារតីស្រឡាញ់ និងលើកស្ទួយអក្សរសាស្ត្រជាតិ ហើយជាពិសេស ស្មារតីបង្រួបបង្រួមជាតិ ដើម្បីសុខសន្តិភាពដ៏ស្ថិតស្ថេរ នៅកម្ពុជា !

សូមជនានុជនក្នុងកម្ពុជរដ្ឋ បានចំរើនលូតលាស់ដុះដាលដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេស និងលើកស្ទួយអក្សរសាស្ត្រជាតិ និងព្រះពុទ្ធសាសនា អោយបានរីកចំរើនជាភិយ្យោភាព តរៀងទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំផុត ចំពោះគណៈកម្មាធិការជំនួយសូត្រស្ងួជប៉ុន និងអង្គការតេនដាយស្ងួ ដែលបានផ្តល់ការឧបត្ថម្ភយ៉ាងឧត្តុង្គឧត្តមដល់ការបោះពុម្ពស្បៀវភៅនេះ ។

ភ្នំពេញ, ថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៤

ពុទ្ធសាសនបណ្ឌិត្យ

www.budinst.gov.kh www.elibraryofcambodia.org

ごあいさつ

この本は、天台宗と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

ACKNOWLEDGEMENT

This book has been printed by Japan Sotoshu Relief Committee with the contribution from

TENDAISHU

We pray that this book would contribute to the friendship with Cambodian people and their cultural preservation.

និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ដោយមានការឧបត្ថម្ភពី

មូលនិធិ តេនដាយស៊ូ

យើងខ្ញុំអធិដ្ឋាន សូមអោយសៀវភៅនេះ បានជាវិភាគទានរក្សាមិត្តភាព ជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

បញ្ជីរឿង

កថាមុខអ្នកវាយ		ក
ការម្ភចខ		១១
ការតបមិត្រ	(រឿងវត្តក ការណ៍ក កណ្តុរ និង ច្រែស)	៦៤
ផ្តើមរឿង	(រឿងព្រាហមចិត្រគ្រូត)	៦៩
កថាខ័ ១	រឿងអ្នកដំណើរ និង ឆ្កាចស់	៦៩
កថាខ័ ២	រឿងច្រែស បចក និងវត្តក	៧៧
កថាខ័ ៣	រឿងត្មាត ឆ្មា និង ចក្រី	៧៤
កថាខ័ ៤	រឿងកណ្តុរចាំរណ្យក:	៧៦
កថាខ័ ៥	រឿងតាណាជចាស់ជក និង ភរិយាក្រមុំ	៧៣
កថាខ័ ៦	រឿងត្រាន ច្រែស ជ្រូក ពស់ និង បចក	៨៤
កថាខ័ ៧	រឿងព្រះរាជា បុត្រតាណាជ និង ភរិយា	១០៦
កថាខ័ ៨	រឿងបចក និង ដំរីស្ត	១០៨

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

កថាមុខ

កាលខ្ញុំគាន់ធ្លក់លោកវេជ្ជបណ្ឌិតលោកអ្នកនាយកញ៉ាំសុភន្តប្រ័ជាំ ឥន្ត មុន
ដំបូង, ខ្ញុំឃើញមានខិតខានខំឯសុកាសិតជាកាព្យ មានសេដាតំផ្អែមល្ហែម
ចាប់ចិត្តចាប់ថ្នើម តាំឲ្យនឹកស្ទើចស្ទាំដៃលោក និង ទឹកចិត្តលោកគេញ
ដោយមេត្តាករុណាដ៏ជ្រាលជ្រៅ ខ្ញុំយល់ថា លោកមិនមែនត្រឹមតែជា
អ្នកកវីឯកប៉ុណ្ណោះទេ លោកជាអ្នកប្រាជ្ញសិលធម៌ និង ទស្សនវិជ្ជាផង ។
តមកមិនយូរប៉ុន្មាន ខ្ញុំបានគាន់ហិតាថេសថណ្ដិតអាកយណៈទៀត
ខ្ញុំឃើញសិលធម៌ និងអរិយធម៌ខ្ពង់ខ្ពស់វិសេសសៀក្រវែងខៀវទៀត ខ្ញុំគិតថា
ធ្វើដូចម្ដេចហ្ន៎ តំណិមានលោកណាប្រែជាភាសាខ្មែរ ពុកជាសម្បុត្តិចិត្ត
វិសេសសម្រាប់ជនជាតិខ្មែរ ? តាំងពីកាលនោះប្រែនឹង ឋញ្ញតន្ត្រៈជា
ប្រកតហិតាថេសនិងរឿងព័រតាំងឡាយក្នុងពិភពលោក ធ្លាក់មកលើ
ដៃខ្ញុំទៀត ដូចជាទេពតាប្រទាន ខ្ញុំគាន់ហ៊ានទៀត ដាច់ចិត្តស្ដីត
ចំពោះអរិយធម៌នេះ មានចិត្តបាមោជ្ឈដែតកាយ ដែតចិត្ត ហាក់ដូចជា
ជាន់ក្រចរឹតចិតអម្រឹត, ហើយសរសើរកត្តសំណាងខ្ញុំដែលកើតមកក្នុង
សម័យថៃតូអក្សរសាស្ត្រខ្មែរ ជាន់ជួបប្រទះកិច្ចការដាស្ថាដៃសំខាន់ថែប
នេះ, ខ្ញុំនឹកដល់លោក យើត្ត ការជាតិតាល្អីម៉ងដ៏ ដែលជាន់ក្រចរស់ជាតិ
តាព្យសក្ខន្តលា ជាចន្លោនកវែកលិតាស: ជាតិឥណ្ណាមុនដំបូង លោក
លុតជង្គង់ចុះដល់ដី លើកដៃសំតះប្រណម្យទៅលើ អគុណចំពោះទេពតា

www.budinst.gov.kh www.elibraryofcambodia.org

ដែលថាខុសគាឃុឲ្យសោក រហូតដល់ថាខានរឿងវិសេសនេះ ។
មិនតែប៉ុណ្ណោះទេ អក្សរសាស្ត្រសំស្ក្រឹតផ្នែកពុទ្ធសាសនាក្តី ផ្នែក
សាសនាព្រាហ្មណ៍ក្តី ឬផ្នែកឯទៀតក្តី សុទ្ធសឹងប្រកបដោយលំអគួរ
ស្ងើចជាច្រើនផុត ។ រឿងនេះជាដើមហេតុ នាំឲ្យខ្ញុំតាំងចិត្តមាំថា:
„ជាតិណា ខ្ញុំមិនខាន់អស់ជីវិតទេ ជាតិនោះ ខ្ញុំនឹងប្រែហ៊ានតែទេស
និងបញ្ចូតន្ត្រៈកាសាសំស្ក្រឹតនេះ មកជាភាសាខ្មែរខ្លះជាប្រយោជន៍ដល់
ជនាខ្លះជនាំនឹងឮ តាមកម្លាំងដែលខ្ញុំតាចធ្វើបាន„ ។

ការប្រែដម្ពីដើការក្លួនខ្លាតជាអរិយធម៌ឥណ្ឌាមកជាភាសាខ្មែរ ខុក
ជាជាការផ្លែកកំពុំមែន ឬខុកថាជាការមិនផ្លែក កំពុំមែនដែរ ។ ព្រះចាប
តេវណ្ណិ ណ្យៈជាក្សត្រសម័យក្រុងភ្នំ (Fou-nan) ជាជាតិឥណ្ឌាបាននាំ
អរិយធម៌មកកាន់ប្រទេសកម្ពុជាមុនដំបូង រវាងទាងចុងសតវត្សរ៍ទី ៥ នៃ
គ្រីស្តសកពជ ។ ចាប់តីសម័យនោះមក អរិយធម៌ឥណ្ឌា ហូរចូលមក
កាន់ប្រទេសកម្ពុជាឥតអាក់ រហូតដល់បច្ចុប្បន្នកាលនេះ មានគោលតី
សាសនាព្រាហ្មណ៍ មានតម្ពីរវៃត្រវេទ តម្ពីរឧបនិស័ទ តម្ពីរហិរវង្ស
តម្ពីរបុកណារឿងភមកេរ៍ រឿងមហាភារតៈ និង ពុទ្ធសាសនា មានតម្ពី
ព្រះវិន័យជាដើម តែតម្ពីរដីកានិង ទំនៀមទំលាប់សាសនាព្រាហ្មណ៍
អស់នោះ កប់បាត់ទៅក្រោមប្រាសាទបុកណាតាំងឡាយស្ទើរតែអស់

www.budinst.gov.kh www.elibraryofcambodia.org

ហើយ ទៅសល់តែពុទ្ធសាសនាដែលហូរចូលមកគ្រាយេះ ។ តាំយេនមិ
អស់នេះ មិនមែនជាអាថ៌កំបាំងអ្វីសោះ កាលបើយើងបើកក្បែកក្រមួក
មើលទៅលើទំព័រប្រវត្តិសាស្ត្រសាកល ដែលអ្នកច្រាជ្ញាំងឡាយបាន
តែកពុកមក ។ ដើម្បីបញ្ជាក់សេចក្តីពិតនេះ លោកស៊ីល្វាំងឡេវីសរសេរ
ថា:(១)"ប្រទេសឥណ្ឌា ជាដើមមេគំនិតច្រាជ្ញា មេដើមរឿងនិទាន
ផ្សេង។ មេដំនឿសាសនា មេទស្សនវិជ្ជា មេច្បាប់ នឹង មេការរចនាទ្វីប
អាស៊ីអស់កាល ៣ ក្នុង ៤ ។ លោកស៊ីដែលសរសេរថា:(២) អ្នកច្រាជ្ញ
ប្រទេសឥណ្ឌាក្បែចសួនឈើង មិនដឹងជាវប្បធម៌ពុទ្ធផ្សាយទៅកាន់
ប្រទេសអាស៊ីភាគនាងកើត នឹង ភាគអាគ្នេយ៍ រហូតមកដល់កាលឥឡូវនេះ
អ្នកច្រាជ្ញឥណ្ឌាខ្លះចេះបាំងនឹង នឹងចេះហុលង់ដ៍ ទៅសួរសែ្ទងរកច្រកត
ប្រវត្តិអស់នេះចេញពីមហាវិទ្យាល័យក្រុងប៉ារីស(Paris) និងឡីដ៍(Leyde)
ហើយគោលថា "មហាប្រទេសឥណ្ឌា" (Greater India) ។

ហ៊ីគោមរទេសនេះ វែចថា ការច្រៀនច្រៃដើម្បីប្រយោជន៍ ការ
តម្សៅប្រយោជន៍, ការច្រាប់ប្រយោជន៍ ឬការដឹកនាំជនាទុជនឱ្យបាន
ប្រយោជន៍ទៅនាលោកខាងនេះ ពុំនោះថា ពាក្យច្រៀនច្រៃដើម្បីសីលធម៌
ដល់ជនាទុជនទាំងឡាយ ពុំនោះសោតនឹងហៅថា ធម៌បំពេញមនុស្ស

1; L'Inde civilisatrice: Page 136. 2 Histoire ancienne de Etats hindouies d'EXtreme Orient; Intcoduction, Page III.

www.budinst.gov.kh www.elibraryofcambodia.org

ភាពកំសឹងចាន ជាតម្លៃរបស់បុកណា មានភាយុកថ់ពានឆ្នាំ នេនិយម
ប្រៃស្ទ្រែប់ភាសាក្នុងសាកលលោក ទោះជាភាសុប្ទ ទុកើប នេទុកជា
លោកនីតិ ឬនតិលោកមួយដំរំខាន់ ។ ចាំគោថខេសជាភាសាសំស្ក្រឹត
នេះមានលំអ៤ប្រការគឺ ១ សេចក្តីជ្រាលជ្រៅខន់ផ្ទួម, ២-ប្រើពាក្យ
តេចន៍លែចមាយល្អស្រស់, ៣-ផើនភាព្យណែនណាន, ៤-រឿនភ័ះ
ភាក់ខនឹងនាផើកជួចរឿន ១០០០១ យថ៌ ។ ចើនវេនណាចានភាននហើយ
នវេននោះ ជាថ់ចិត្តនឹកស្ទើចជញ្ជក់មាត់ចង៍មើលចង់ភាន និងនឹកទៅ
ជល់អ្នកនិតន្ទផើម ស្ទើចសរសើរស្មៃដែនិងចិត្តប្រកចដោយមេត្តាក្រាល
ទៅទ្រែចជណ្តាច់សត្វសកូតាំងឡាយ ។

លោកស្ទ ល័ស្ទ ចណ្តិតឥណ្ឌាតិត្រាហ្មណ៍ សរសេរទុកថា
„ ហ៊ានគោថខេសនេះលោកនាកយណៈមហាចណ្តិត ឥណ្ឌារៀចរៀនឡើង
ជកស្រែងតិតម្តីរផើមឈ្មោះចញ្ចកន្ត្រៈនិង តម្តីរផ្សេង ។ ទៀត ជួចសេចក្តី
ផែលចណ្តិតនាកយណៈ ចានគោលទុកក្នុងភាអម្ពចខលោកស្រាច់ ។
ផ្ទួសេចក្តីហ៊ានគោថខេសនេះ បើតាមភាសង្កេតមើល យើញមានខំនង
ស្រេចទៅទាង ពុទ្ធសាសនា ដោយច្រើន ជួចសេចក្តីយល់នៃលោក
ចេន-ផ្ទៅចណ្តិតអង់គ្លេសថា: „ ហ៊ានគោថខេសនេះ តង់ភាស្រ័យគោល
ពុទ្ធសាសនាសផ្សំផងផែរ „ ។ តាមសេចក្តីនេះគ្នាខន់អ្នកច្រាជ្ញតង្ហាវតា

www.budinst.gov.kh www.elibraryofcambodia.org

លោកសរសេរថា ហ៊ានគោរពខ្ញុំសូមស្រ្តីត កើតខ្មែរក្នុងវេន សតវត្សរ៍ទី ១០ នៃពុទ្ធសកាជ សតវត្សរ៍ទី ៥ គ.ស.) ហើយចម្លង គន្លាខ្មែរស្មើតែគ្រប់ភាសាប្រទេសឥណ្ឌា មានភាសាបេន្គ័ល មហ៍ត ជាដើម តែវិវត្តសំខាន់ជាងគេនោះ គឺបេស់ថណ្ឌិតល័ល្ហ. ល័ល្ហ ជា ភាសាក្រ័ជភាខាឈ្មោះកជនីតិ ។ តាប្រទេសឥណ្ឌាខាងខ្មែរ គេប្រើ ជាភាសាបេហ្គ័ រវាងសតវត្សរ៍ទី ១១ នៃពុទ្ធសកាជ (សតវត្សរ៍ទី ៥ គ ស). តាភាសាបេហ្គ័ជាភាសាតាក់ប់រវាងសតវត្សរ៍ទី ១៤ នៃពុទ្ធសកាជ (សតវត្សរ៍ទី ៨ គ.ស). ប្រៃតាក់ប់ខាងភាសាហិចរូ (ផ្ទូហ្ស), ប្រៃតា ភាសាហិចរូខាងជាភាសាក្រ័ក ខាងជាភាសាធំៗក្នុងខ្លួមនុរ៉ោចមានភាសា អល្លីម៉ង់ អង់គ្លេស និង ចាក់ឆជាដើម ។ ខ្ញុំសូមអភ័យទោសដោយខ្ញុំ មិនបានលើកយកឈ្មោះអ្នកប្រាំងអស់មកចារឹកទុកក្នុងន័ន្ទេះទេ ឯកវែង គោលខ្លះ ល្មមឲ្យដឹងដំណើរសេចក្តីដូចតទៅនេះ៖

ក្នុងសតវត្សរ៍ទី ៦៣ នៃពុទ្ធសកាជ (សតវត្សរ៍ទី ១៧ គ.ស.) បណ្ឌិតលន្ទីឥស្លាមជាតិបារាំស៊ី (ចៀរស៍) ឈ្មោះតាជ.ឯទីន បានប្រែជា ភាសាចៀរស៍ទ្បើឈ្មោះថា មហ្គារីហ៍ អល កូលួត ប្រែថា «អម្ពីរចញ្ចឹត ចិត្តទ្បើរកយ» តែជាធម្មតាអ្នកកាន់សាសនាឥស្លាម កាលប្រែនោះ គេចំប្លែងសេចក្តីដើមជាលន្ទីសាសនាព្រាហ្មណ៍ ទ្បើមានចំនងទៅជាលន្ទី

www.budinst.gov.kh www.elibraryofcambodia.org

ឥស្សាមចាំងឥស ។ ឯសេចក្តីប្រែចម្លងចុះឆ្លាក ភាជ ឯ១ ទំព័រ នេះត្រូវ
ចុះតែឥណ្ឌាឈ្មោះមីរ តហា ឬរ-គាលី ហ្គូសែន ប្រែត្រឡប់ជាភាសា
ឥណ្ឌូស្តានីវិញ កាល ព.ស. ២៣៤៩ (គ.ស. ១៨០៦) ចោះពុម្ពនៅ
ក្រុងកល់កុតា ឲ្យឈ្មោះថាឥក្ខាត ឥ.ហ៊ិស្តូ ប្រែថា ស័លធម៌ឥណ្ឌា ។
✓ ឯសេចក្តីប្រែជាភាសាខ្មែរចុះពេលមុនដំបូង ច្រើនមានសេចក្តីយ៉ឺនយ៉ាត
តិះសៀវគៅដើមដោយច្រើន ព្រោះកាលនោះ ការចេះដឹងភាសា
សំស្ក្រឹតនៅខ្វះចុះពេលពុំទាន់មានចប់ណា ក្នុង ព.ស. ២៣៧៧ (គ.ស.
១៨៤៤) ទើបលោកម៉ាក់ មុលែ្លចុះឆ្លាងស្ទើមដំបូង ប្រែបានត្រឹមត្រូវតាម
សៀវគៅដើម ។ កាលព.ស. ២៣៨១ (គ.ស.១៨៤៨ លោកហ្វ្រង្សែ
ជនសុង ចុះឆ្លាងអង់គ្លេស ប្រែជាភាសាអង់គ្លេស ក្នុង ព.ស. ២៣៨៦
(គ.ស. ១៨៥១) លោកដេមក្រៃយ៉ូស តាឡាណូស ជាតិក្រីកនៅក្រុង
ភាវែន ប្រែជាភាសាក្រីក, លោកនេះបានចូលទៅនៅប្រទេសឥណ្ឌា
តាំងពីកាល ព.ស.២៣៦៨ (គ.ស.១៧៨៦) ដល់ ព.ស ២៣៧២
(គ.ស. ១៨ញ៣) ។ ក្នុង ព.ស. ២៣៨៨ (គ.ស. ១៨៥៥)លោក
អេមួតាវេ ឡង់ស៊ីរ៉ូ ប្រែជាភាសាចាក់ឆ្លាងក្នុងបណ្ណាល័យ ឯលសេវីរ
យែន ដឺ ថសាន្ត (Bidliathéqueelzévirienne de P. jannet ។
ក្នុង ព.ស.២៤០៦ (គ.ស ១៨៦១) លោកនាងប្រពន្ធ ចុះឆ្លាង

www.budinst.gov.kh www.elibraryofcambodia.org

សៀម ប្រែជាភាសាសៀម ។ ដើម្បីឲ្យស្រួលទៅតាមទំនៀមភាសា
ខ្លួន, ហ៊ានគោចខេសជាសំស្ក្រឹត ចោះពុម្ពផ្សឆ្នាក្ត័ សេចក្តីប្រែត្រង់ជាតិ
ភាសាក្នុងសាកលលោកក្តី តែងមានសេចក្តីខ្វះខាតលើសលស់គ្នាខ្លះ
ដោយអន្លើ ដោយការចម្លែមចន្លួយទៅតាមអត្ថនោម័តិ ពុំនោះក្លាយទៅ
ជាសុភាសិត ឬរឿងនិទានជាតិភាសានោះៗសុទ្ធសាធ ដូចគម្ពីរលោក
ឡាហ្វុនតែន ឋណ្ឌិតចាក់ឆ្លងជាខ្មែរហរណ៍ សេចក្តីពិត ហ៊ានគោចខេសនេះ
តិបញ្ញត្តន្ត្រៈត្រង់តែម្តង ដោយត្រាន់តែបំព្រួញមកនៅត្រឹមតែ ៤ ភាគតឺ:
ម៉ត្រលាក (ការតម់ម៉ត្រ)១, សុហ្ឋខ្ពេ (ការចំពែកម៉ត្រ)១, វិត្រហៈ
(សង្គ្រាម)១ ឧដ្ឋសន្ធិ (សន្ធិភាព)១, ។ ឯបញ្ញត្តន្ត្រៈ មាន ៥
ភាគ បញ្ចូ «ប្រុំ, ×តន្ត្រៈ «ច្បាប់) ច្បាប់ប្រុំប្រកាវ ។ ខ្ញុំ
ប្រែជាភាសាខ្មែរនេះ ក្នុងមួយភាគចោះពុម្ពជាមួយសៀវភៅរហូតត្រង់
ពាំង ៤ ភាគ ។

ហ៊ានគោចខេសដែលខ្ញុំប្រែខេះ ខ្ញុំប្រែត្រង់តាមច្បាប់ភាសាសំស្ក្រឹត
នាកយណាចណ្តិត ដែលលោក កាស៊ីនាថ ឆាណ្ឌុវង្ស ចរ័ត ចោះពុម្ព
លើកទី ១០ កែតម្រូវដោយលោក វ៉ាសុទេវ- លក្ស្មណៈសាស្ត្រី ឆាង្ស៊ីវ
ការ ចោះពុម្ពផ្សាយដោយលោក ឆាណ្ឌុវង្ស ជាវរ ម្ចាស់រោងពុម្ព
«និយមសាគរ» នៅក្រុងប៊ុំបៃ គ.ស.១៨៦១ ។ កាលប្រែ ខ្ញុំរក
កលទីដែលប្រែផ្តិត មិនឆានបន្ថែមសេចក្តីឲ្យឃ្លាតឆ្ងាយពីច្បាប់ដើមពេកទេ

www.budinst.gov.kh www.elibraryofcambodia.org

✓ គ្រាន់តែសម្រួលទៅតាមទំនៀមភាសាខ្មែរប៉ុណ្ណោះ ព្រោះចង់រក្សាវេជ្ជាតិ
លំនាំភាសាស្ទឹកឲ្យនៅតែនៅ តែគេះជាទំប្រិតប្រឿនយ៉ាំងណា ខ្ញុំនៅ
តែមានភ័យក្នុងរឿងនេះមិនអស់មិនហ៊ាយ ព្រោះការប្រែភាសាមួយទៅ
ភាសាមួយ តែងមានការឃ្លៀងឃ្លាតរវៀងសេចក្តីគាជាធម្មតា ដែលជា
គោលនៃចំណុច ណាមួយ ដ្ឋាអក្សរសាស្ត្រខ្មែរបស់ខ្ញុំទៅខាងខ្ពើតក មិន
អាចឈានចាប់សំនួនវោហារគាក្យមួយមាត់ៗ នៃអក្សរសាស្ត្រសំស្ទឹក
យកមកប្រែជាគាក្យខ្មែរឲ្យច្បាស់លាស់ដូចសេចក្តីដើមបាន ហើយជាការ
លំបាកលើសសមត្ថភាពរបស់ខ្ញុំផង ។ ដើម្បីជាគ្រឿងណែនាំឲ្យខ្លួលយ
គំនិត ខ្ញុំបានយក ហិរញ្ញវត្ថុ ច្បាប់ប្រែជាភាសាសៀមរបស់លោក
នាគប្រទីប ភេងតុម្ព ហត្ថលេខាទៅ ថ្ងៃទី ១ ខែតុលា ព.ស.២៤៤៤ និងហិរញ្ញ
វត្ថុ ច្បាប់ប្រែភាសាបារាំងរបស់លោក អេឌួអារដ៍ ឡង់សីរ៉ូ ភេងតុម្ព
មេសិនទើ ព.ស. ១៨៨៦ ។ ខ្ញុំបានធ្វើន័យលក្ខណៈខ្លះ ច្រាប់សេចក្តីថ្លែក
ន្លាចំពោះសុភាសិតដែលមានប្រយោជន៍តួរឲ្យដឹងហ៊ាយ ចំប្រញាតាមលោក
អេឌួអារដ៍ ឡង់សីរ៉ូ ថា «ឡង់សីរ៉ូ» តាមលោកសេដ្ឋីរយៈកោសល នាគ
ប្រទីបថា "នាគប្រទីប" សូម្បីខ្ញុំខំប្រឹងប្រែងកុំឲ្យមានការភ្លាំងភ្លាត់ ការ
ប្រែនេះនៅតែមានការខុសឆ្គងឥតកំសេចក្តីប្តូរគោលអ្វីមួយ ដែលហួសកំ
លាំងសតិបញ្ញាសេចក្តីព្យាយាមខ្ញុំ ថាបើមានធម្មតាឥតដំអក័យគោលឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

ឋច្ចាជនជាអ្នកប្រាជ្ញគាសាសំស្ក្រឹតអនាគតនិងជាគាជន: ខ្ញុំលក្រដំរេងខ្ញុំ
កេរ្តិ៍តិក តីការភ្ញាំងភ្លាត់ខុសរបស់ខ្ញុំក្នុងការប្រែច្បាប់នេះ ហើយនិងកែ
សំរួលឲ្យបានត្រឹមត្រូវល្អឡើង ពុកជាហិតានុហិតជល់ចង្អុលប្អូនម្នាក់តទៅ
សេចក្តីប្រែនេះ ខ្ញុំពុកជាទីរលឹកការនៅចាំរស្លាសស់ក្រមាសក្នុងដាំទ្រូងឯក
ស័ក ព.ស. ២៤៩២ ។

ខ្ញុំមានអំណរយ៉ាងក្រៃលែង ចំពោះលោកគ្រូព្រះទេពសង្ឃ
សួរ. ហាយ ក្រមជំនុំព្រះត្រៃបិដក និងព្រះគ្រូមុនីសោភ័ណ សេរ តាង
សាស្ត្រាចារ្យសាលាចាលីជាន់ខ្ពស់ ដែលជួយឲ្យទន្ទ័យក្នុងការប្រែ ។ ខ្ញុំ
សូមអរគុណលោកព្រះចារ្យាភ័ន្តោធិកម ជា-ធាយ សាស្ត្រាចារ្យសាលា
ចាលីជាន់ខ្ពស់ ដែលតេញចិត្តនឹងកាសាសំស្ក្រឹតជួចខ្ញុំដែរ ព្រមទាំង
សហការីទាំងឡាយ ដែលបានយកព្រះទ័យពុកជាក់ជួយសរសេរជួយកែ
តម្រង់ជំនួសខ្លួនខ្ញុំ ។ សូមអរគុណលោក ជុំ-ខួត ទីព្រឹក្សាព្រះរាជ
អាណាចក្រ ដែលស្រឡាញ់ការនេះ ហើយបានអាជ្ញាសូមឲ្យប្រែ
ហិតោបទេសនេះយកទៅបោះពុម្ពផ្សាយជាលក់ សាធារណជន ។

ខ្ញុំសូមឲ្យប្រែជាជនខ្មែរបានប្រកបដោយសេចក្តីសុខចំរើនគ្រប់ប្រការ!

វត្តឧណ្ណាលោម ថ្ងៃពុធ ៦ រោចខែភទ្របទ ឆ្នាំជូវឯកសក ព.ស.២៤៩២
ត្រូវនឹងថ្ងៃទី ២៧ ខែកញ្ញា គ.ស. ១៩៤៩

ភិក្ខុ ជាំង-ខាត់ ពីរោយជណ្តើរតោ

www.budinst.gov.kh www.elibraryofcambodia.org

អារម្ភកថាលើកទី ២

ហិរញ្ញវត្ថុសាលាទី ១ ទៀងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៣/៣៣ ចុះ
ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ឡើងវិញ ដោយបានបំបែកចេញពីក្រសួងផែនការ ហើយបានបង្កើតជាអង្គភាព
ថ្មីមួយ ដែលមានឈ្មោះថា អគ្គនាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីធ្វើការងារ
ទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្នុងរយៈពេលជិត ៣ ឆ្នាំ
ចុងក្រោយនេះ ការងារនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រីក
ទូលាយ ដោយមានការបង្កើតក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធថ្មីៗជាច្រើន
ដែលត្រូវការធនធានហិរញ្ញវត្ថុសាធារណៈ ដើម្បីដំណើរការ ។ ដូច្នេះ
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្លាយជាការងារមួយដែលមានភាព
ស្មុគស្មាញ ទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ ។ ដោយឃើញពីភាព
ចាំបាច់ និងសារៈសំខាន់នៃការងារនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បានបោះពុម្ពផ្សាយ ទស្សនាវដ្តីហិរញ្ញវត្ថុ ជាលើកដំបូង ក្នុងឆ្នាំ ១៩៩៤
ដើម្បីជាឧបករណ៍ផ្សព្វផ្សាយ ព័ត៌មានស្តីពីការងារហិរញ្ញវត្ថុ ដល់
មន្ត្រីរាជការ និងសាធារណជន ។ ក្នុងរយៈពេលជាង ២ ឆ្នាំកន្លងមក
ទស្សនាវដ្តីហិរញ្ញវត្ថុ បានបោះពុម្ពផ្សាយចេញជាបន្តបន្ទាប់ ដោយមាន
ការកែលម្អជាលំដាប់ ទាំងខ្លឹមសារ និងទម្រង់បែបបទ ដើម្បីឲ្យកាន់តែ
ស្របតាមតម្រូវការ ។ ដោយមានការយកចិត្តទុកដាក់ពីសំណាក់ក្រុមការងារ
ទស្សនាវដ្តីហិរញ្ញវត្ថុ ដែលមានសមាជិកមកពីមន្ទីរ អង្គភាព និងនាយកដ្ឋាន
ជាច្រើន ទស្សនាវដ្តីហិរញ្ញវត្ថុ បានក្លាយជាឧបករណ៍ដ៏មានប្រយោជន៍
សម្រាប់ការផ្សព្វផ្សាយ ព័ត៌មានស្តីពីការងារហិរញ្ញវត្ថុ ដល់មន្ត្រីរាជការ
និងសាធារណជន ។ ដូច្នេះ ការបោះពុម្ពលេខទី ៦ នេះ
ក៏ដោយ ។ ខ្ញុំបានកែតម្រូវតម្រូវសេចក្តីខ្លះ ដែលភ្លាត់ធ្លាំធ្លងឲ្យបានល្អ
ហើយបានអនុញ្ញាតឲ្យចាត់ការបោះពុម្ព ។

ភ្នំពេញ ថ្ងៃសៅរ៍ ៥ កើត ខែផល្គុន ឆ្នាំមមី ឆស័ក ព.ស. ២៥៤៧

ត្រូវនឹងថ្ងៃទី ២៦ ខែឧសភា គ.ស. ១៩៩៦

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

www.budinst.gov.kh www.elibraryofcambodia.org

ស្ថាប័នពុទ្ធសាសនៈ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ស្រី
ហិរគោបរទេស

អារម្ភបទ

១-សូមសេចក្តីក្រាបថ្វាយបង្គំ សាធុជនទាំងឡាយ ចូរសម្រេចផល ដោយការយោគ្រងសំដីនៃព្រះអង្គ ដែលរស្មីភាគ១ក្នុង ១៦ ស្តុកនៅ ក្បែជិព្រះខណៈ ដូចជាលេខា(១) នៃតារុខឹកខន្ធគង្គា ។

២-ហិរគោបទេសនេះ នរជនចូលត្រងត្រាប់ស្តាប់ហើយ នឹងប្រគល់ឲ្យនូវសេចក្តីជំនាញក្នុងភាសាសំស្រ្តឹត នូវសេចក្តីឆ្លៀវឆ្លាសក្នុងសំដីថ្លែងតាក់ នឹងក្នុងនីតិវិជ្ជាទាំងឡាយដ៏វិចិត្រផ្សេងៗ ក្នុងទីទាំងពួង ។

៣-អ្នកប្រាជ្ញ កាលបើសិនរក វិជ្ជា ឥន ច្រឡំ តយ៉ាតតាមដូចជាខ្ពុនមិនចាស់មិនស្ងាប់, កាលបើសិនរកឆមិ តយ៉ាតតាមខ្ពុនត្រូវម្រីក្បុចាប់ក្រមួចសក់ចោកសម្លាប់តទៅនេះហើយ ។

៤-បណ្តាច្រឡំទាំងពួង, វិជ្ជា លោកគោលថាជាច្រឡំដ៏ខ្ពស់ព្រោះវិជ្ជាចោរលួចយកមិនបានផង កាត់ថ្លៃមិនបានផង មិនចេះរេចរលែអស់ទៅផង សព្វកាល ។

១- បន្ទាត់ ដំនូសឬព្រា គឺ រស្មីភ្ញីផ្ទៀកជិចបន្ទាត់ ឬព្រាផ្សាយចេញពីតារុខឹក ។

www.budinst.gov.kh www.elibraryofcambodia.org

๕- វិជ្ជាយ៉ាងអ្វីជាផលដែលទៅជាកាម ឲ្យបានចូលទៅជិតព្រះនិព្វានដែលគេទៅជិតបានដោយក្រ ឬ អ្នកមានបុណ្យជាំក្រៃលែងជាងព្រះនិព្វានទៀត ដូចស្តីនៃផលទៅក្នុងចំណាចតែងប្រមូលយកចំកចូលទៅកាន់សមុទ្រ ។

๖- វិជ្ជា នាំឲ្យមានវិនិច្ឆយ. វិនិច្ឆយ នាំឲ្យបានសេចក្តីថ្លៃថ្នូរ, សេចក្តីថ្លៃថ្នូរ នាំឲ្យបានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិ នាំឲ្យបានយស យស ជាកនាំឲ្យបានសេចក្តីសុខ ។

๗- សស្ត្រវិជ្ជា (๑) និងសាស្ត្រវិជ្ជា (๒) ទាំងពីរនេះ គួរប្រតិបត្តិសិក្សា រឿនឲ្យចេះដឹងទាំងអស់ វិជ្ជាច័ទ ទាងដើម (សស្ត្រវិជ្ជា) កើតចំរើនខ្លាំង ដើម្បីសើចលេងជាភ្នុកកំថ្នង, វិជ្ជាទី ๒ ទាងចុង (សាស្ត្រវិជ្ជា) បុគ្គលគួរគោរពក្នុងកាលទាំងពួង ។

๘- ប្រចំនួរដែលគេគួរពុកឮជាកាជនៈថ្នី មិនភ្លេចក្នុងយោងជាប្រការដទៃយ៉ាងណា ឥតវិជ្ជា ដែលគេ បង្ខិក បង្ហាត់ ដល់កូនក្មេងទាំងឡាយដោយថា ជាគ្រឿងប្រៀបធៀប កំជាប់ទៅយ៉ាងនោះលោកពោលពុកក្នុងទីនេះឯង:

๑-វិជ្ជាកសាងឬប្រើជាអាវុធសម្រាប់ប្រហារគ្នាទៅវិញទៅមក ។ ๒ វិជ្ជា ការចេះដឹងក្បួនច្បាប់ គម្ពី និការឬប់សម្រាប់ប្រតិបត្តិឲ្យកើតសេចក្តីសុខក្សេមក្សាន្ត ឬសេចក្តីចំរើនលោក ។

www.budinst.gov.kh www.elibraryofcambodia.org

๕.๑ មិត្រលាភ (ការគប់មិត្រ) ๒. សុហជ្ជខ្ពង (ការចំរើនមិត្រ) ๓.វិគ្រហៈ(សង្គ្រាម) ๔.សន្ធិ (សន្ធិភាព) ដែលជកស្រង់យកមកពីតម្ពីរ ឋញ្ញតន្ត្រៈ ខ្ញុំឯតម្ពីរដៃខ្មែរនោះ ខ្ញុំពោលទុកក្នុងទីនេះដូចសេចក្តីតទៅ។ ក្នុងអតីតកាល,មានឧសភមួយឈ្មោះចាជលិប្បុត្រ ស្ថិតនៅក្បែរស្ទឹងគង្គា ។ ព្រះចាទសុទសិនៈ ទ្រង់ប្រកបដោយស្វាមីគុណត្រប់ប្រការ សេចក្តីត្រង់ឧសភនោះ។ សម័យមួយ,ទ្រង់ចាត់ឲ្យព្រះសណ្តាប់ស្វាកពីរ ចូលដែលអ្នកប្រាជ្ញចានពោលទុក មានសេចក្តីដូចតទៅនេះ ៖

๑๐- សាស្ត្រវិជ្ជា ជាគ្រឿងកាត់ចង់ខ្លួនសេចក្តីសង្ស័យជាអនេក ជាគ្រឿងបើកបង្ហាញខ្លួនកាចំកំចាំង ឧឯជាភ្នែកសម្រាប់មើលសព្វសារតើ ការណ៍ចាំងឡាយ, អ្នកណាមិនមានសាស្ត្រវិជ្ជា អ្នកនោះទុកដូចជាមនុស្សខ្វាក់ ។

๑๑-កាតជាយុវជន១ កាតជាអ្នកមានទ្រព្យច្រើន១ កាតជាអ្នកមានអធិបតេយ្យ១ ឧឯកាតជាអ្នកមិនបែកបាក់គ្នា ១ បើមានតែមួយ។ ក៏នាំឲ្យខូចប្រយោជន៍, ធ្វើដូចម្តេចហ្ន៎ ឲ្យបានគ្រប់ចាំង ๔ ប្រការក្នុងខ្លួនមនុស្ស? កាលព្រះកជាអង្គនោះ ទ្រង់ព្រះសណ្តាប់ជូនព្រះហើយ ក៏ទ្រង់ព្រួយតានតឹងព្រះកជហឫទ័យ ចំពោះព្រះកជបុត្រវេស់ព្រាអង្គ ដែល

www.budinst.gov.kh www.elibraryofcambodia.org

អារម្ភកថា

មិនខាន់ចានសិក្សាសាស្ត្រវិជ្ជាចាំនឡាយ ព្រមចាំនប្រព្រឹត្តក្នុងផ្លូវទុស
គន្ធនធម៌ដោយសេចក្តីប្រមាថ ទើបទ្រង់ព្រះដម្រិះក្នុងព្រះកដហឫទ័យ
ដូច្នេះថា:

១២-មានប្រយោជន៍អ្វី ចំពោះកូនដែលកើតហើយស្លាន់ផង មិន
ប្រកបដោយធម៌ផង? ដូចកែកឈើ មានប្រយោជន៍អ្វី? ចានគ្រាន់តែ
ឈើ ចាក់ដោតនាំឲ្យរំខានចុំណ្ណោះ ។

១៣-ថណ្ការកូន ៣ ពួក គឺកូនមិនខាន់កើត ១ ពួក កូនកើត
ហើយស្លាប់ទៅវិញ ១ ពួក និងកូនស្លាន់ ១ ពួក កូនពីរពួកខាងដើមជាកូន
គាប់ប្រសើរ, ពួកកូនចុងបំផុត មិនប្រសើរឡើយ ព្រោះថា កូនពីរពួក
ខាងដើម ធ្វើទុក្ខព្រួយតែម្តងក៏អស់ហើយទៅ ឯពួកកូនក្រោយចុងបំផុត
ធ្វើទុក្ខមាតាបិតាឲ្យលំបាកត្រង់ដំហានជើងឯង ។

១៤-អ្នកណាកើតហើយដឹកនាំត្រកូលឲ្យចំរើនខ្ពង់ខ្ពស់ឡើង អ្នក
នោះទើបឈ្មោះថា «កើត» មែនទែន ឬ គេញាំជាកើតត្រឹមត្រូវ ព្រោះក្នុង
សំសារវដ្តដែលប្រព្រឹត្តទៅនេះ អ្នកណាមួយដែលស្លាប់ទៅហើយមិន
ត្រឡប់កើតវិញទេឬអី?

១៥- ក្នុងគ្រាដែលប្រាថ្នាចង់រើសរកឈ្មោះ នៃពួកអ្នកមានគុណ ចុះ
ក្នុងបញ្ហាប្តីផង ឈ្មោះអ្នកណាឥតគុណ មិនញ៉ាំងចិត្តគេឲ្យរំភើបត្រឹមត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ហ៊ានពោលទេស

✓ ១៩ ! តេមិនចាំកឈ្មោះអ្នកនោះទេឬយ ចើដូច្នោះ តើគួរនឹងហៅម្ដាយ
ដែលបង្កើតកូននោះ ថាជាស្ត្រីគា ឬស្ត្រីអ្វីហ្ន៎ ?

១៦- អ្នកណាមិនដំកល់ខ្លួនក្នុងការទ្បែតន, ក្នុងតថធម៌ តែសុច្ចរិត,
ក្នុងសេចក្តីអធំអាចគ្បាហាន, ក្នុងវិទ្យាសាស្ត្រ និងការសិក្សារកទ្រព្យ
អ្នកនោះលោកពុក្ខជាទុច្ចារៈនៃនាគា ។

១៧- កូនមានគុណគាប់តែម្នាក់ជាកូនប្រសើរ កូនល្អឥតប់រមែនប្រសើរទេ
ដូចព្រះចន្ទតែមួយដួង គាចកំចាត់នឹងឥតន្ធការបាន កងគាកតាំងឡាយ កំចាត់នឹងមិនបានទេឬយ ។

១៨- តបៈ តីការបំពេញកុសល ដែលបុគ្គលណាមួយធ្វើក្នុងទីស័ក្តិសិទ្ធិ តុំនោះបំពេញពុក្លកម្មដ៏ក្រៃលែងឯណាមួយ ព្រោះគ្រាថាកូនកូនរៃអ្នកនោះ គួរជាកូនប្រពៅងាយ សមប្តិ សម្រេចប្រយោជន៍ប្រកបដោយធម៌ និងមានគ្រាជាបរិបូណ៌ ។

១៩- អរិយោបានទ្រព្យ ១ ភាពជាបុគ្គលមិនមានពេនជាន់ចុ ១ អរិយោជាទីស្រឡាញ់ ១ អរិយោគោលតាក្យតិពេះ ១ កូនប្រពៅងាយ ១ និងមានវិជ្ជាធ្វើប្រយោជន៍ដល់សាធារណជន ១, បតិត្រព្រះកជា ! ធម៌ ៦ ប្រការនេះ ជាបរមសុខក្នុងជីវលោកនេះ ។

៦០- គួរនឹងកប់អ្នកមានកូនច្រើនថា តាប់ប្រសើរឬទេ ? ចើកូន

www.budinst.gov.kh www.elibraryofcambodia.org

តាំងឡាយនោះខុកជួចជានាឡិខេក្នុងចង្រ្កែក, កូនតែម្ចាក់ជាទីពឹងផ្អែក
ទុកចំរុងត្រកូលល្អជាជាង ក្បើរឈ្មោះចិតាកំល្បីល្បាញ ឮ ខ្ទរខ្ទាយ
ទៅត្រង់ទិសានុទិស ។

៤១- ចិតាធ្វើបំណុលខុកឲ្យកូនជាសត្រូវ, មាតាប្រព្រឹត្តខុចំតែទុស
តទ្វេងប្រពៃណាជាសត្រូវ, អរិយោមានរូបល្អជាសត្រូវ, កូនល្ងង់ពិជាសត្រូវ។

៤២- វិញ្ញា បើមិនយកទៅប្រើប្រាស់ ជាពិសពុល, គោជន
ដែលថរគោនទៅហើយមិនលួយ ជាពិសពុល សភា(១)ជាពិសពុល
សម្រាប់អ្នកក្រក្រ, ស្ត្រីក្រមុំជាពិសពុល សម្រាប់មនុស្សចាស់ជរា ។

៤៣- នរជន សូម្បីកើតចេញពីត្រកូលណាក៏ដោយ តែមានគុណ
តាប់ប្រសើរហើយ លោកក៏គួរគោរពបូជា, ឯសូម្បីចរិសុទ្ធដោយវិន្ស(២)
តែមិនប្រសើរ តើនឆ្លើអ្វីកើត ?

៤៤- ម្នាលកូនកំសត់អើយ! អ្នកមិនគាន់បានរៀនសូត្រសោះ
ក្រែតាំងឡាយចេះតែប្រព្រឹត្តកន្ទួនៅ។ បើដូច្នោះ ខ្លួនអ្នកនឹងកប់ចាត់
នៅកណ្តាលហ្វូងអ្នកប្រាជ្ញតាំងឡាយ ដូចគោលង់ទ្រនេសជាប់ក្នុង

---

๑ ទីប្រជុំ ភេងមហោស្រព ឬទីជាន៧ស្បែរជន ។ ២វិស, ប្រែថា ឬស្បែ រន្ធត រត ខ្ទុយ
ផ្ចិតខ្ចៃ ខ្សែស្រឡាយវិង្សជាតិ ។ ទីនេះមានសេចក្តីផ្សេងគ្នា តាំងឬស្បែនេះ គេមិនប្រសើទ្វីក៏មិន
ពួកែ, ឯមានវិង្ស ផ្ទុយជាឯព្រះឥស្សរ ព្រះរាមជាដើម បើមិនបានប្រសើទ្វីក៏មិនពួកែ ។

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

កណ្តាលចំឆកត់ ។

តាលបើដូច្នេះ ត្រូវដូចម្តេចឲ្យកូនតាភ្នាអញ ត្រឡប់បានជាបុគ្គលមានគុណតាប់ប្រសើរឡើង ក្នុងតាលឥឡូវនេះ ?

៦៥- ចរិកោគតាហារ ១ ការជក ១ ភ័យ ១ និង សេតមេថុន ១ ធម៌ទាំង៤ប្រការនេះ មនុស្សនិងសត្វមានដូច្នោះ, មានតែព្រះធម៌ប៉ុណ្ណោះទេ ទើបតាចធ្វើមនុស្ស និង សត្វឲ្យវិសេសថ្លែកពីគ្នា ពីណាស្រាសចាកធម៌ អ្នកនោះខុកស្មើសត្វ ។

៦៦- ធម៌ (ព្រះវេទ), អាថ៌ធម៌ (សេចក្តីអធិប្បាយព្រះវេទ) កាម (សេចក្តីប្រាថ្នាធម៌ និង អាថ៌ធម៌) និងមោក្ខៈធម៌ទាំង ៤ ប្រការនេះ អ្នកណាមិនមានក្នុងខ្លួន សូម្បីតែមួយប្រការ ជាតែអ្នកនោះឥតប្រយោជន៍សោះសូន្យទេ ដូចចូកតពែ(១) រកប្រយោជន៍គ្មាន ។

៦៧- អាយុ ១ កម្ម ១ ទ្រព្យ ១ វិជ្ជា ១ និងសេចក្តីស្លាប់ ១ ធម៌ ៥ ប្រការនេះកើតសម្រេចមកជាមួយកងកាយមនុស្ស តាំងពីស្ថិតនៅក្នុងគភ៌ម៉្លេះ ។

៦៨- តាវធម៌ នៃបុគ្គលមានតាវធម៌ តែងកើតមានផល់តាវៈ នៃបុគ្គលជាធំដោយពិត, តាវៈអាក្រាត តែងមានផល់ព្រះឥស្សរ តិរយោ

១- នៅប្រទេសឥណ្ឌាខាងបេង្គាល់មានពពែមួយពួកគេហៅថា គលស្តនី ប្រែថា ពពែមានដោះនោក ។

www.budinst.gov.kh www.elibraryofcambodia.org

ដោកលើតស់ដំ(๑) តែងមានដល់ព្រះហរិ(๒) ។

๒๙-ចេស់ណាមិនមានចច្ចំយ ចេស់នោះកំតែងមិនមាន, ថាចេ ចេស់ណាមានចច្ចំយ ចេស់នោះកំមិនមែនជាមិនមាន, ថ្នាំនេះរម្ងាប់នូវ តិសពុលគឺសេចក្តីតក្ខាន ហេតុដូចម្តេចកំនេមិនផឹកថ្នាំនោះហ្ន៎? ។

តែការិតនេះ ច្រើនជាសំដីមនុស្សខ្វិលពួកខ្លះ ក្នុងចំណោមមនុស្ស មិនចេះអត់ធន់ដល់ការងារតាំងឡាយ ។

๓๐-បុគ្គល សូមីតិតយើញ្ញាត្រង់វាសនា កំមិនគួរលះបង់សេចក្តី ព្យាយាមខ្លួនចោលឡើយ, បើបុគ្គលមិនព្យាយាមចម្រាញ់ល្អ មិនបាន ច្រើនល្អទេ ។

๓๑-ដោតលាក តែងចូលទៅរកបុរសស័ហ: ដែលជាអ្នកមាន ព្យាយាមក្តៀវក្តា, ទានតែបុរសតម្រក់ទេ តែងពោលថា "ស្រេចតែត្រង សំណាង! », បុគ្គលចូរផ្តាញ់វាសនា ហើយធ្វើខ្លួនព្យាយាមឲ្យគេញ៉ាំ កូនច្រុស តាមកម្លាំងខ្លួនដែលអាចធ្វើបាន ថាចើតាំងព្យាយាមប្រឹងច្រែង ធ្វើហើយ នៅតែមិនសម្រេចទៀត តើវាខំធ្វើតើសម្អី? ។

๓๒- ចេមិនតប្បីទៅបានដោយកន់តែមួយយ៉ាំងណា, ត្រូវវាន ចើវៀរចាកព្យាយាមនៃបុរសហើយ កំមិនសម្រេចយ៉ាំងនោះដែរ ។

๑-ឃានព្រះនាយណ៍ ឈ្មោះមហាអហិ ។ ๒-តាមព្រះនាយណ៍ ។

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

ឈ្មោះ- កម្ម ដែលបុគ្គលធ្វើអត់ចុកថ្នាំ ឈ្មោះហៅថា «ព្រែងវ៉ាសនា» ព្រោះហេតុនោះ បុគ្គលមិនឲ្យលែងព្រមស្រួល តម្រូវធ្វើសេចក្តីប្រែងព្រែងដោយត្បាយថាមតែញ៉ាំបុរស ។

ឈ្មោះ- ជាងចាំន់ ចាំន់ដុំដីជារូបផ្សេង។ តាមចិត្តខ្លួនចាំន់យ៉ាងណា កម្មដែលបុគ្គលសាងទុកខ្លួនឯង ក៏ចាំន់មនុស្សមានភាវៈផ្សេង។ តាមលក្ខណៈនៃកម្មរបស់ខ្លួនយ៉ាងនោះដែរ ។

ឈ្មោះ- បុគ្គល សូម្បីឃើញកំណាច់ព្រត្យនៅក្នុងទីចំពោះមុខ ដូចរឿងក្អែកដោយមិនឆ្កួតថា ខ្លឹង ក៏តមានចុង ហើយចាំព្រែងវ៉ាសនាតាស់តតាយយកមកឲ្យឯង។ មិនវេលាច្នើសេចក្តីត្បាយាមតែញ៉ាំប្រុសមិនចានកំណាច់នោះទេ ។

ឈ្មោះ- ការចាំងត្បាយ តែងសម្រេចដោយសេចក្តីត្បាយាមប្រែងព្រែងដោយពិត មិនមែនដោយមនោរថទេ ដូចម្រឹងចាំងត្បាយ មិនដែលចោលចូលមាត់សីហៈផងលក់ឡើយ ។

ឈ្មោះ- កូនក្មេង ដែលមានមាតាបិតាចានហ្វឹកហ្វឺនហើយ ទៅជាកូនមានគុណតាប់ប្រសើរចាន មិនដែលមានកូនក្មេងណាចានទៅជាចណ្ដាំដោយគ្រាន់តែឲ្យតទេញតិតតិមាតាទេ ។

ឈ្មោះ- កូនក្មេង ដែលមានមាតាបិតាណា មិនចានឲ្យរៀនសូត្រ

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

មាតានោះត្រឡប់ជាសត្រូវ ចំតានោះត្រឡប់ជាបុគ្គលមានតឿរ ព្រោះកូនមិនបានរៀនក្នុងទីប្រជុំជន ដូចកុកកណ្តាលហ្វូងហង្ស ។

៣៩-ក្មេងចរិចូណាដោយរូបនិងវ័យក្មេងសម្អាតក្នុងត្រកូលជាវិសេសអភរេះដ៏ងវិជ្ជាគ្មី មិនមានភស៊ីរៀនទេ ដូចជ្ញាតាវតមានក្តិនត្រអូប។

៤០-មនុស្សល្ងង់ ប្រដាប់កាយដោយគ្រឿងអម្ពរតែងមានភស៊ីរៀនក្នុងទីប្រជុំជន បើមនុស្សល្ងង់នោះ មិនតាន់ហារមាត់ចេញនិយាយជាកថណា ក៏នៅតែមានភស៊ីរៀនជាកថនោះ ។

កាលព្រះរាជាទ្រង់រំពឹងដូច្នោះ ទ្រង់ត្រាស់ចង្អាប់ឲ្យប្រជុំអ្នកប្រាជ្ញតាំងឡាយ ទើបទ្រង់ត្រាស់ថា: « នែលោកបណ្ឌិតតាំងឡាយ សូមលោកស្តាប់ខ្ញុំ បណ្តាលោកបណ្ឌិតតាំងឡាយនេះ មានលោកណាខ្លះ ជាអ្នកប្រាជ្ញអាចបង្រៀនន័តិសាស្ត្រដល់កូនខ្ញុំ ដែលល្ងង់ខ្លៅប្រព្រឹត្តខុសតន្ធឆមិជាន់ច្រ ឲ្យមានកំណើតថ្មី ឲ្យត្រឡប់ជាមនុស្សខ្លៀនក្នុងកាលឥឡូវនេះជាមួយ ? » , ព្រោះថា ៖

៤១-កញ្ជក់នៅរួមជាមួយនឹងមាស អាចចាលស្រមោលក្លាយទៅជាកែវមរកតយ៉ាងណា, មនុស្សល្ងង់ នៅរួមជាមួយនឹងលោកសប្បុរស ក៏អាចត្រឡប់ទៅជាសប្បុរសឆ្លៀវឆ្លាតជាមួយយ៉ាងនោះដែរ ។

៤២-កូនអើយ ! មតិយោកថាថ ព្រោះសមាគមមួយភន្លេះដោយ

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

ប្តូរគ្នាលេងកាច សមាគមមួយអន្លើដោយប្តូរស្មើគ្នា មិនកំស្មើគ្នា, សមាគមមួយអន្លើដោយប្តូរច្រើរ មិនកំរីនតែច្រើរខ្លាំង ។

សម័យនោះ, មហាឋលិតម្នាក់ឈ្មោះវិស្សសិមន មានការចេះដឹងសកលនីតិសាស្ត្រពិតប្រាកដ ដូចជាព្រះព្រឹហស្បត៍ ក្រាបទូលថា: „បពិត្រព្រះសម្មតិទេវរាជ្យ! ព្រះកដប្តូតាំងឡាយនេះ គ្រប់សម្ភពគុណមហាក្រកូល ខ្ញុំលព្រះបង្គំគាបបង្រៀនទិតិសាស្ត្រតាំងឡាយ តាមព្រះកដបំណងបាន, ព្រោះថា: -

៤៣- កិច្ចការអ្វីមួយដែលប្រកបដោយអំពើឥតប្រយោជន៍ កំរែងមិនបានផលសមតាមប្រាថ្នាទេ ដូចជាប្រើវេលាគ្រាយាមបង្រៀនសត្វកុកឲ្យចេះនិយាយដូចសត្វសេក សូម្បីប្រើនយូរជង់ នឹងបានផលកំរឥតអង្គីមានឡើយ ។

៤៤- តែកុងមហាក្រកូលថែមទេះ អ្នកគ្មានបុណ្យមិនមកកើតទេ ប្រៀបដូចអណ្តូងវែកើតក្បែងទទឹម ធ្វើម្តេចឡើយនឹងកើតមានកញ្ជក់វិ ។

ហេតុនេះ, ខ្ញុំព្រះអង្គសូមទូលយកព្រះកដទានអាសាបង្រៀនព្រះកដកុមារតាំងឡាយនេះ ត្រឹមតែធម៌សប៉ុណ្ណោះ ឲ្យមានការចេះដឹងនិតិសាស្ត្រស្គាល់ជំនាញ„ ។

ព្រះកដា ទើបទ្រង់ត្រាស់តបដោយសុភាពថា : „

www.budinst.gov.kh www.elibraryofcambodia.org

អារម្ភបទ

៤៩- ជន្លឹរឡើងខ្ពស់ទៅលើក្បាលសាធុជនតាំងឡាយបានព្រោះទៅលាយឡំជាមួយកំណើតក្តា, ដុំថ្មដែលអ្នកធំលើកដំកើងហើយ កំភ្លាយទៅជាកាតទេវតាពួកែស័ក្តិសិទ្ធិ ។

៤៦- ទេសន៍ព្រឹត្យដែលទៅលើកំពូលភ្នំទាន់ឧទយាទិត្យ តែងបានខ្លួលតន្ធឹស្ងាត់រុងរឿង ព្រោះទៅជិតព្រះអាទិត្យយ៉ាងណា, ជនទាន់ជាតិវណ្ណៈថោក តែងបានខ្លួលការចេះដឹងជាតន្ធឹ ព្រោះទៅជិតលោកអ្នកសប្បុរសយ៉ាងនោះដែរ ។

៤៧- អ្នកមានគុណតាប់ តែងដឹងល្អ និងតាក្រក់, អ្នកមានគុណតាប់នោះ បើទៅសេពគប់មនុស្សតាក្រក់ ក៏ត្រឡប់ទៅជាតាក្រក់វិញ ដូចស្មឹងមានទឹកជ្រះហើយដោយរសជាតិល្អ លុះហូរចូលដល់សមុទ្រហើយ កំភ្លាយទៅជាមានរសត្រៃពីកមិនបាន ។

ព្រោះហេតុនោះ, ខ្ញុំសូមប្រគល់តំណាចដល់លោកជាអ្នកមេត្រៀនឱវាទស្តេចដល់កូនខ្ញុំ, ទ្រង់ត្រាស់ហើយ ទើបប្រគល់ព្រះរាជទេវដល្ងចណ្តិតវិស្សុស៍ម័នដោយសេចក្តីគោរពក្រៃលែង ។

អារម្ភបទ ចប់ប៉ុណ្ណេះ

www.budinst.gov.kh www.elibraryofcambodia.org

១-ការគប់មិត្ត

កាលនោះ, មហាឧបាសិកាវិសាខាមិគារមាតា ក្រាបបង្គំទូលព្រះកឋបុត្រតំាន
ឡាយ ដែលប្រថាប់នៅក្នុងទីចំពោះមុខ ដោយសេចក្តីសុខសម្រួលលើ
ផ្នែនៃប្រាសាទ ដោយស្មោកដូច្នេះថា :

១-អ្នកប្រាជ្ញតែងប្រើកាលវេលាឲ្យប្រព្រឹត្តទៅ ដោយការកំសាន្ត
កាឡសាស្ត្រ, មនុស្សល្ងង់តែងប្រើកាលវេលាឲ្យប្រព្រឹត្តទៅ ដោយការ
ប្រព្រឹត្តសេចក្តីវិនាស ដោយការដេក និងដោយការឈ្លោះទាស់នែង ។

ព្រោះហេតុនោះ ទូលព្រះបង្គំនឹងពោលកថាដ៏វិចិត្រមានរឿងក្អែកនិង
អណ្តើកជាដើមចម ខុកជាព្រះសណ្តាប់ដើម្បីកំសាន្តព្រះហឫទ័យនៃទ្រង់
តំាន ឡាយ ។ ព្រះកឋបុត្រតំាន ឡាយត្រាស់តបថា: ចតុត្រៃលោកនាយ! I
សូមលោកមេត្តាពោលរឿងនោះ ឲ្យមានស្តាប់» ។ ឧបាសិកាវិសាខា
ពោលតាក្យជាសំណៀនថា: «បើដូច្នោះ, សូមទ្រង់តាំនព្រះទ័យស្តាប់ចុះ
ការគប់មិត្រនេះនឹងផ្តើមពោលឥឡូវនេះដូចមាននៅស្មោកខុកជាទាំងដើមថា :

២-អ្នកប្រាជ្ញមានចិត្តល្អ សូម្បីរួតត្រួតគ្នាហើយឥតកម្លាំង ក៏
អាចជួយកែទៅឲ្យសម្រេចប្រយោជន៍បានដោយរួសរាន់ ដូចរឿងក្អែក
អណ្តើក និង កណ្តុរ ។

ព្រះកឋបុត្រតំាន ឡាយត្រាស់សួរថា: «រឿងនោះតើដូចម្តេច» ។
ឧបាសិកាវិសាខាមិគារមាតាក្រាបបង្គំទូលថា :

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

រឿងក្អែក អណ្តើក និង កណ្តុរ

- នៅលើត្រើយស្ទឹងគោទាវ៉ី មានដើមធំត្រសុំសាខាមែក ក្រឡឹងក្រវែល ។ ពួកហ្វូងចកៀវផ្សេង ។ លុះដល់វេលាខន់តាចព្រះសុរិយាល្ងាចថ្ងៃហើយវែងឯចបួលគ្នាហើរមកពីទិសខុទិស ប្រៀវប្រៃបួលមកជ្រកកាស្រ៍ឃ្លាដើមដើមជ្រៃនោះ ។ សម័យមួយ, វេលាព្រឹកព្រាងស្វាងខ្ចីង ជិតអស់រៃនៃកត្តិកាលហើយ ព្រះចន្ទជាទ័គោរតាងាយកនៃកងគោមុខជាតិ លិចបាត់រងំស្មើ កំពូលភ្នំអស្តង្គត, មានក្អែកមួយឈ្មោះលឃុបតនក: ភ្ញាក់ខ្ចីងពីពន់ត្រលឹម ក្រខ្លែកមើលទៅឃើញព្រានម្នាក់មកដល់ ប្រៀចដូចជាឃើញព្រះយមកជាទ័ ៦ លុះឃើញហើយក៏រំពឹងគិតថា « ថ្ងៃនេះ, យើញ។ចព្រត្យចង្រៃកើតខ្ចីងតាំងពីព្រលឹមតែម្តងគាត្មាអញមិនអប្បីជីងបានថា ។ចព្រត្យចង្រៃនេះ ខ្លីង កើតច្រាកដខ្ចីងមែចណា! រំពឹងគិតហើយ ខ្ទេរត់តក់ស្លុតក្នុងចិត្តឥតឧបមា ក៏ហើរត្រាទៅតាមមើលស្ថានព្រាននោះចរៅ, ព្រោះថា ៖

ញ-មនុស្សល្ងង់ តែងជួបច្រេះ ចំរេងច្លិច ហេតុដែរមេនាំឲ្យកើតសេចក្តីសោកមួយពាន់ជង ឬហេតុដែលនាំឲ្យកើតភ័យច្បួយរយជង ក្នុងមួយថ្ងៃ។ តែអ្នកប្រាជ្ញជួបច្រេះប៉ះចង្កិចហេតុដូច្នេះឥតអស្ចឹមានឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំជនខ្មៅកន្លះលោកនេះគួរធ្វើ មនុស្សការ: កន្លះចិត្តដូច្នេះកាលថ្ងៃកុំទាន ។

៤- ការភ្ញាក់ក្រោកឡើងព្រលឹម ខ្ញុំជន តែងជាស់សតិ រាល់ថ្ងៃថា «មហាភ័យខាំនឹងយើងជិតមកដល់ហើយ ចូរភ្ញាមហាភ័យខាំនឹងយើងនោះ ការឈឺចាប់ សេចក្តីស្លាប់និងសេចក្តីទុក្ខសោកគ្រោះភ័យ ឬ អន្តរាយអ្វីមួយ អុំនជាធ្លាក់មកដល់អាត្មាអញក្នុងថ្ងៃនេះ» ។

កាលនោះ, ព្រានបក្សីនោះខ្លាំងក្លា ព្រោះគ្រាប់ស្រូវ ហើយត្រងាងលាប់ លុះចាក់ចែងរួចសព្វគ្រប់ហើយ ក៏ពួនសម្ងំអាត្មាក្នុងទីមួយ ។ ក្នុងកាលនោះឯង, ស្តេចត្រាបចិត្រត្រឹត ហើរចេរមកតាមក្បាយ ព្រមមួយអន្ធើរដោយត្រាបជាច្រើន រោករលើអាកាសវេហាស៍ ឃើញគ្រាប់ស្រូវកំពុងភ្នាក់ភ្នួយដូច្នោះ ក៏គោលំពែក ព្រាបជាច្រើនដែលស្មោកចង់ចុះទៅស៊ីគ្រាប់ស្រូវនោះថា: «ហេតុអ្វី ក៏មានគ្រាប់ស្រូវនៅក្នុងជង្រៃព្រៅ ខ្ញុំជនលន្ធឹងលន្ធោចឆ្ងាយតាមហានមនុស្សដូច្នេះហ្ន៎ ? ដំណើរនេះគួរគិតារណាមើលសិន យើងយើញរាល់នេះ ខ្លាចគុំជាលាភចំរើន ក៏ឥតអន្តីមាន, ព្រោះការស្មោកស៊ីគ្រាប់ស្រូវនេះ ខ្លាចត្រូវច្រាំទ្បាស អន្តរាយ ក្តៅក្រហាយស្តាយក្រោយដល់យើងគ្រប់គ្នាក៏សឹងថាបាន ។

៥- ព្រោះលោកចង់បានកន្លះមាស, អ្នកដំណើរខ្លាក់ខ្លាក់ផុងជាប់ក្នុងចិនកក់ជ្រៅឡើងមិនរួច ត្រូវខ្លាចស់សង្រ្គប់ចាប់ហែកស៊ីស្លាប់ទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

ហ៊ានពោលទេស

ព្រោះជាចរិកស្ងួរខ្សឹងថា: រឿងនោះកើដូចម្តេចៗ ។ ស្តេចព្រោះ
ឈ្មោះចង្រៃត្រេតនំយាយរឿងត្រាប់ថា:

កថាទី ១

រឿងអ្នកដំណើរ និង ខ្វាចាស់

ថៃ្ងមួយ, កាលខ្ញុំចាំចេះហ៊ីរកាត់ផ្លូវឆ្ងល់កន្លែងណាវណ្ណៈ ខ្ញុំបានឃើញ
រឿងនេះ, មានខ្វាចាស់មួយ ទ្រើតិចមុជទឹកលាងថ្ពាប(១) ហើយឡើងមក
ដៃកាន់ស្បូវក្តាំង ឈរខ្ចៀចមាត់ស្រះ ស្រែកហៅអ្នកដំណើរម្នាក់ថា:
✓ "នែអ្នកដើរ! អ្នកចូលមកយកកន្ទបមាសឯនេះ„ ។ លំដាប់នោះ, អ្នក
ដំណើរ បានឮហើយ តំមានចិត្តចង់បានកន្ទបមាសដោយសេចក្តីលោភ!
ទើបតំតថា „គាត្មាអញមានបុណ្យវាសនាធំណាស់ ត្រូវបានកន្ទបមាស
តែក្នុងទីនេះប្រាកដដោយសេចក្តីរន្ធឹស ក្រែងមានសេចក្តីអន្តរាយខ្លះ
គាត្មា មិនស្តាយតាខ្លួនទេ, ព្រោះថា ៖

"— ការស្វែងលាភ ក្នុងកន្លែងដែលគេញ័រចិត្តអំពីមនុស្សគ្រោកក្រក់ មិន
មែនជាគតិល្អទេ ព្រោះថា ទឹកអម្រឹតលាយដោយឈាមសុល មានក្នុងទី
ណា គេគាចស្ងាប់បានក្នុងទីនោះ ។

១—ទំនៀមសាសនាព្រាហ្មណ៍ ត្រូវមុជទឹកលាងថ្ពាប គេប្រកាន់ថាជាការបរិសុទ្ធ ។ តៅ
ទទ្វេគង្គាប្រទេសឥណ្ឌាមានព្រាហ្មណ៍រាប់ពាន់នាក់ ចុះទៅមុជទឹកលាងថ្ពាបរាល់ ៦ ថ្ងៃ ។ តៅ
ប្រទេសខ្មែរយើងគេយកទឹកក្នុងដំបូលទឹកពង្គា លាងជាតុប្រកាន់ថាបរិសុទ្ធដ្រែះ។បច្ចុប្បន្ន

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្រ

ការសែនរកគ្រូឲ្យក្នុងចិត្តឆាប់ ខំឯងថាមិនត្រូវតាមតារៈបស័ន្តក៏មិនមែន ព្រោះថា ៖

៧-នរជនមិនខ្លាំងកាន់សេចក្តីសង្ស័យ (មិនចេះសង្ស័យ) ម៉ែលមិនឃើញសេចក្តីចំរើនទេ ថាចេះខ្លាំងកាន់សេចក្តីសង្ស័យម្តងហើយ ម្តងទៀត ចិត្តនៅសាឲ្យ សាំញុំ ចេះតែសង្ស័យ ស្មាក់ស្មែរ កាលចេះឃើញសេចក្តីចំរើនហើយ ក៏ឈ្មោះថាមិនឃើញដែរ ។

ចើជួបគ្នា គាត្មាអញតួសួរដេញដោលឲ្យតស់ដើងសិន ។ អ្នកដំណើរនោះ, ប្រកាសសួរទៅថា « នៅឯណាកន្លងឯងខ្លះ? » ។ ពេលនោះ, ខ្លាកំលើកដើងមុខចង្អាញឲ្យមើល ។ អ្នកដើរផ្លូវពោលថា:« ឆ្នើម្តេចឲ្យខុកចិត្តស្ងួតស្ងាលនឹងឯង ព័ត្រោះឯងនេះជាសត្វខ្លា ចូលចិត្តស៊ីសាច់ប្រចាំថ្ងៃ សម្លាប់គេជួរច្រះ? » ។ ខ្លាឆ្លើយតបថា : „ នែអ្នកអើយ! ចូរអ្នកស្តាប់ខ្ញុំ កាលខ្ញុំនៅព័ទ្ធវ័យនៅឡើយ ខ្ញុំប្រព្រឹត្តតាក្រក់មែន ខ្ញុំទាំសម្លាប់គោ មនុស្ស ច្រើនអនេក, ដល់អំពើតាក្រក់នោះឲ្យផល កូនប្រពន្ធខ្ញុំស្លាប់ចោលអស់ ខ្ញុំផុតពួជអស់ហើយ ខ្ញុំនៅកំព្រាតែម្នាក់ឯង ។ លំជាប់មក, មានតាបសអស៊ីចិត្តសប្បុរសម្នាក់ខ្ជាន់ប្រដៅខ្ញុំឲ្យតាន់ធម៌ថា: „ នែអ្នក! អ្នកចូរប្រព្រឹត្តធម៌ ឲ្យទាន កុំប្រព្រឹត្តតាក្រក់ទៀត » ។ តាំងពីនោះមក ខ្ញុំធ្វើតាមពាក្យប្រៀនប្រដៅរបស់តាបសអស៊ីនោះ ដរាប

www.budinst.gov.kh www.elibraryofcambodia.org

ហ៊ានពោលទេស

មិនដែលហ៊ានប្រព្រឹត្តធ្វើការក្រក់ទេ ប្រព្រឹត្តមុនចំកណាងជាប(១) ជានិច្ច រក្សាសីលជាក់ខានជាប្រក្រតី មានមេត្តាករុណា, ពេលនេះ ខ្ញុំក៏ការនៃតាស់ជាតគ្រាំគ្រាខុតិល ឆ្នេញ ក្រចក កំរោចរលស់លើងហើយ ដូចម្តេចកំស្អកនៅតែមិនដឿខ្ញុំទៀត មិនអាចយកខ្ញុំជាវិស្សាសភូមិបាន, ព្រោះថា:

៨- ការថ្លូជាយញ្ញ។ ការសិក្សាព្រះវេទ។ ទាន។ តប: ។ សច្ច: ។ សន្តោស ។ សេចក្តីអត់ធន់ ។ និងការមិនលោភ ។ ទាំង ៨ ប្រការនេះ ជាបដិបទានៃព្រះវេទ ឋុគ្គលគប្បីចាំខុកបុះ ។

៨- បណ្តាធម៌ ៨ ប្រការនេះ ធម៌ ៤ ប្រការខាងដើម គេប្រតិបត្តិដើម្បីបង្ហូតឋុគ្គលកំបាន, ធម៌ ៤ ប្រការខាងចុង ស្ថិតនៅបានចំពោះតែឋុគ្គលមានមហាភ័ន (មានចិត្តប្រសើរ) ។

ឥឡូវនេះ,ខ្ញុំអស់សេចក្តីលោភលើងហើយ ហួតដល់ចង់ឲ្យកងទាសដែលនៅក្នុងដៃខ្ញុំនេះ ជាទានដល់អ្នកថែមទៀត តែបើខុកជាខ្ញុំប្រព្រឹត្តល្អដូច្នេះ ក៏នៅតែពិបាកនឹងគេចឬ ឃាត់ហាមលោកប្រាថ្ន(២) ពាក្យញុះញង់សិក្សៀតមនុស្សលោកថា « ទ្វាស៊ីមនុស្ស » ព្រោះថា:

១០-មនុស្សលោក តែងឆ្អែនៅតាមដំណើរហេតុដែលកន្លងទៅហើយ មិនដឿខុកចិត្តស្តាប់ទាស ដែលគេបានឲ្យឧបទេស (គេបាន

១.មើលន័យលក្ខណៈលេខ ១ ទំព័រ ៤៦ ។ ២.ពាក្យមនុស្សលោកពោលបង្ខិច ។

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំនាងស្អ) ហើយមិនគិតយកព្រះធម៌ជាប្រមាណ ដូចគេមិនជឿទុកចិត្ត ព្រាហ្មណ៍ដែលធ្លាប់គាប់សម្ងាប់គោ ។

មួយទៀត តម្ពីរធម៌សាស្ត្រ ខ្ញុំក៏បានរៀនសូត្រអស់ដេរដែរហើយ សូមអញ្ជើញអ្នកត្រង់ត្រាប់ស្តាប់ដូចតទៅនេះ:

១១- បពិត្រព្រះបាទបាណ្ឌនន្ទនៈ[1] ក្មួនដែលបង្អុរចុះលើដែនតស៊ុធាដែលរីងហែងរំហួតយ៉ាងណា ការឲ្យគោជនាហារដល់ជនស្រែកឃ្លានអត់ថាយក្រហាយខ្លាក៏យ៉ាងនោះដែរ ។ ការឲ្យទានដែលបានផលនិសង្សច្រើន គឺការឲ្យទានដល់មនុស្សអ្នកខ្ជិលក្រក្រលំបាកគោកយំក ។

១២-ជីវិតរបស់ខ្លួនជាទីស្រឡាញ់គេញាប់ក្តយ៉ាងណា ជីវិតរបស់ជនដទៃក៏យ៉ាងនោះដែរ ។ លោកសប្បុរសទាំងឡាយ តែងទ្រទ្រង់សេចក្តីមេត្តាករុណា ព្រោះលោកយកខ្លួនរបស់លោកជាគ្រឿងឧបមា ។

មួយទៀតលោកគោលទុកថា:

១៣-កំណាញ់ និងការឲ្យទាន, សេចក្តីសុខ និង សេចក្តីទុក្ខ, ស្រឡាញ់ និងស្អប់ បុគ្គលគប្បីយកប្រមាណសេចក្តីថាន ដោយយកខ្លួនភាក្ខាជាគ្រឿងឧបមា ។

១- តាមព្រះជាតិបាណ្ឌិតសូត្រយ័មានបងប្អូន ៥ ព្រះអង្គ ក្នុងរឿងមហាភារតៈ, ជាឱរសព្រះតាងកុន្តី បានជាតាមខ្វះថា កោន្តេយ្យ ។

www.budinst.gov.kh www.elibraryofcambodia.org

ហិរោចទេស

๑๖- នរជនណាឃើញកវិយាអ្នកដទៃ ពុកស្មើដោយមាតាបិតាខ្លួន, ឃើញទ្រព្យអ្នកដទៃ ពុកស្មើដោយដុំថ្ម, ឃើញសត្វសត្វទាំងឡាយ ពុកស្មើដោយរូបខ្លួន នរជននោះ លោកហៅថា «បណ្ឌិត» ។

ខ្លួនអ្នកជាបុគ្គលពុតត្បុតកំសត់ក្រីក្រក្រៃលែង ព្រោះហេតុនោះទើបខ្ញុំទំព្រឹងរំព្រែងជាប់ផុតខឹង ឲ្យទានដល់អ្នក ព្រោះថា :

๑๗- បពិត្រព្រះបាទបាណ្ឌុ(๑) សូមទ្រង់មេត្តាករុណាចំពោះអ្នកក្រីក្រកំសត់ពុតត្បុត កុំប្រទានទ្រព្យដល់ឥសូរជនដែលមានទ្រព្យច្រើនឡើយ ដូចជាទុសថជាប្រយោជន៍ដល់អ្នកជម្ងឺឈឺចាប់ពុនពុក ជនឥតពេទ្យាធិប្រសើរគាត់អ្វីដោយទុសថ ?

๑๘- ទានជារបស់គួរតបាឲ្យ តែឲ្យដល់អ្នកមិនមានទុបការគុណមិនសូវមានផលប្រយោជន៍ទេ, ការឲ្យទានដែលអ្នកច្រូតជ្រូតគាស់ថាប្រកបដោយផលប្រយោជន៍នោះ គឺឲ្យទានត្រឹមត្រូវតាមកាលៈទេសៈ និងឲ្យដល់បុគ្គលមានគុណគួរឲ្យ ។

ដូចេ្នះ, អ្នកចូរទៅមុជទឹកលាងបាប(๒) ក្នុងត្រពាំងនេះឲ្យស្អាតបាតសិន ហើយសឹមទៅដឹងមកយកកងមាសត្រឡប់ចុះ ។ លំដាប់នោះអ្នកដំណើរបានស្តាប់ពាក្យភ្លាតស់គោលលះលួង ឲ្យរំដួងស្មុងស្មាប់តំនឹងហើយ

---

๑. មើលន័យលក្ខណៈលេខ ๑ ទំព័រ ๒๙ ។ ๒ មើលន័យលក្ខណៈ លេខ ๑ ទំព័រ ๒๖ ។

www.budinst.gov.kh www.elibraryofcambodia.org

ដើរចុះទៅមុខទឹកលាងជ្រាប(๑) ក្នុងត្រកាំងនោះ ដោយចិត្តលោភលន់ពន់ប្រមាណ កំផុងត្រចាណលន់ទ្រនេសជាប់ក្នុងបឹងកក់ជ្រៅ ខឹងនេះចេះវេះកន់លួនទៅតួនក្នុងទឹងឯណាកំពុំបាន ; រីឯខ្លាចាស់ កាលឃើញអ្នកដំណើរផុងលន់ទ្រនេសជាប់ក្នុងកក់ហើយមិនចូលមកចំណាងហើយ ទើបភ្លែងធ្វើជាស្រែកជួយតយ៉ាងថា : «ហ៊ា ! ហ៊ា ! ឃើអ្នកផុងលន់ក្នុងកក់ហើយឆេ ! មិនអីទេ ចាំខ្ញុំចុះទៅជួយស្រង អ្នកកុំភ័យ ! ថាហើយក៏ដើរចុះសន្សឹមៗ ដល់ចាំ ស្ទុះស្ទង់មើល ធ្វើជាខ្លាចផុងខ្លួនឯង ចូលទៅចាប់អ្នកដំណើរនោះ ។ ឯអ្នកដំណើរ កាលបើខ្លាចូលទៅសង្កត់ជាប់ក្នុងដៃហើយ ក៏ទឹកភ្នែកស្រក់ខ្លួន ទើបគោលបន្ទោសខ្លួនឯងថា :

๑๗- ប៉ុន្តែលុះតិត្តភក្រក់សាមាទ្យ ខឹងសំគាល់ថានេះជាយគាងហេតុថា « ចេះគោលធម្មសាស្ត្រ » ក៏មិនមែនឬថា « ចេះស្ទាត្បាយគម្ពីរព្រះវេទ » ក៏មិនមែនដែរ. មធុរសនៃទឹកដោះគោរមែងផ្អែមល្ហែមទៅតាមប្រក្រតីរបស់ទឹកដោះយ៉ាងណា, សភាពសត្បុរសក្នុងសំសារវដ្តនេះលោកគោលថា ដូចគ្នាយ៉ាងនោះឯង ។

๑๘- ការធ្វើអ្វីតាំងពួន នៃបុគ្គលអ្នកមានអន្ទ្រីយ ខឹង ចិត្តមិនល្អុះ

๑.មើលខ័យលក្ខណៈ លេខ ๑ ទំព័រ ๒๕ ។

www.budinst.gov.kh www.elibraryofcambodia.org

ហ៊ានពោលទេស

✓ នៅក្នុងអំណាចខ្លួន ក៏មិនជាផល ដូចជាការលាងជំរះដំរី(១) តុំនោះ ការចេះដឹង បើប្រាសចាកការធ្វើឲ្យជាប្រយោជន៍ហើយ ក៏ឆ្ងល់ខ្លួនក្សាលផតអំពើ ដូចជាការចំណាក់គ្រឿងអលង្កា ចំបំនឲ្យកេរយោចង្រៃ ចាន់តែឆ្ងល់ខ្លួនឥតប្រយោជន៍ ។

គាត្មាអញ ធ្វើសេចក្តីស្ងប់ស្ងាលខុសចិត្ត មនុស្សគ្រាក្រក់សាមាន្យ ចូលចិត្តសម្លាប់គេ ដោយហេតុឯណា ហេតុនោះគាត្មាអញឈ្មោះថា មិនធ្វើសេចក្តីចំរើនទេ ព្រោះថា ៖

១៩- បុគ្គលមិនគួរនឹងប្លន់ធ្វើសេចក្តីស្ងប់ស្ងាលខុសចិត្តទីការខ្លួន, បុគ្គលមានសាស្ត្រាវុធក្នុងដៃ, សត្វមានក្រចកមុត, សត្វមានស្នែង និង ស្ត្រីក្នុងភជក្រកូលតាំងខ្លាយ ។

២០- សភាព (លក្ខណៈ) នៃបុគ្គលតាំងអស់ ក្នុងលោកនេះ គេមើលឃើញច្បាស់ច្រាកជ តែគុណធម៌តាំងខ្លាយនៃបុគ្គល គេមើលមិនឃើញជាយទេ, សភាពនៃបុគ្គលនិមួយៗ កំចាត់ចង់នូវគុណធម៌តាំងពួង ហើយចូលទៅចំនៅលើក្សាលបាន ។

២១- មែនពិត ព្រះចន្ទ្រច្រេងនូវសហស្សរង្សី គ្រាចំបាំងរឿងឮដំនាល់យប្រទេស កំចាត់ចង់នូវឥន្ទឹតអន្ធការអ័ព្ទសូន្យសុងកណ្តាល

១- ការលាងដំរី ឥតអំពើ ព្រោះស្បែកដំរីត្រឹម ។ ហើយដំរីប្លុលចិត្តជាចង្រឹងជាប់លើខ្លួន។

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្រ

ដូនតាកន្ត្រោងក្រោង សូម្បីមានបុត្តដល់ម្ភៃ៎ះ ដល់គ្រោះជាតគ្រោះជាំ
ក៏ត្រូវកហូចាប់លេបបាន នរណាហ្ន៎! អាចវេះគេចឲ្យរួចពីលិខិតដែល
ព្រះជាម្ចាស់ត្រាទុកឮដ៏ថ្លាសបាន ? ។

រីអ្នកដំណើរនោះ, កាលកំពុងត្រិះរិះពិចារណាដូច្នេះ ត្រូវខ្លាចស់
ទាំងដង្ហែនហែកស៊ី ស្ងាប់រំងាសអន្តរជានឮដ៏កាលនោះហោង ។ ហេតុ
នេះបានជាខ្ញុំ (ស្តេចត្រាប) គោលជាស្មោកមានតាំទ័ថា ៖ « ព្រោះ
លោកចង់បានកងមាសដូច្នេះជាដើម »[៤] ។ ព្រោះហេតុនោះ ការងារ
ផងទាំងពួង ដែលមិនបានពិចារណាឲ្យដុំវិញខ្លួនសព្វគ្រប់ មិនគួរគប្បីធ្វើ
ឡើយ ព្រោះថា ៖

៦៦-អាហាដែលរលួយល្អ, កូនមានច្រើនជាឆ្កែវែងឆ្ងាត, អាយុ
ស្តាប់ថ្ងាច់ទាប. ព្រះនរបតីមានប្រជាកស្ត្រីស្អាមឥតកំណៀ, តែគួរឲ្យស្អិតល្អ
ហើយទើបនិយាយ, ពិចារណាឲ្យដុំវិញខ្លួនហើយទើបធ្វើ ពាំងអស់នេះ
លោកគោលថា សូម្បីស្ថិតនៅអស់កាលយូរអង្វែងក៏ដោយ ក៏មិនឃ្លាត
ក្លាយទៅជាអ្វីឡើយ ។

កាលនោះ មានព្រាហ្មណ៍ជាបរិវារមួយ បានឮស្តេចត្រាបគោលថា
ដូច្នេះហើយ ក៏ទាស់ចិត្តនិយាយដោយអាការខ្ពើមឆ៊ីឆ្ងល់ថា ៖ អ៊ាំ!
ដូចម្តេច ក៏លោកមានប្រសាសន៍ដូច្នេះ ?

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

៤៣-ចេីមានការអន្តរាយមកដល់ជីក ឬបុគ្គលតប្រឹក្សាតាមការ ចាស់ព្រឹទ្ធាចារ្យ តែចេីប្រឹក្សាតិចារណាឲ្យសព្វគ្រប់ យ៉ាងនោះហើយ សួមប្រីស្នងរកអាហារគោជន កិមិនត្រូវស្នងរកដែរ ។

៤៤-បុគ្គលដែលស្នងរកជាយថំកនំចំណេ លេីដែនពាសុធានេះសុទ្ធ សឹងចំរះខ្ជិច ដោយសេចក្តីរេឡ្ងៀសកយន្តកយតាំងឡាយ នឹងប្រព្រឹត្តស្នងរកក្នុងកាលណា ។ ធ្វេីម្តេចហ្ន៎ គេនឹងអាចចិញ្ចឹមជីវិតឲ្យប្រព្រឹត្តទៅជាន-។

៤៥-បុគ្គលមានឥច្ឆាឈ្មោន័ស បុគ្គលគោលតាក្យនិន្ទារះតន់, បុគ្គលមិនសន្ធោស, បុគ្គលក្រោធច្រេីន, បុគ្គលមានសេចក្តីរេឡ្ងៀសជានិច្ច និង បុគ្គលតឹងផ្នែកស្តីតែងជាយសារបុគ្គលដទៃ បុគ្គលតាំង ៦ ចែចនេះ ត្រូវខ្លួលចំណែកនៃសេចក្តីទុក្ខ ។

ព្រោះដាចរាំងតាំងឡាយ លុះបានស្តាប់តាក្យព្រោះអ្នកនិយាយនោះហើយ កិចបួលគ្នាហេីរត្រសងទេចុះក្នុងស្រែនោះ ព្រោះថា ៖

៤៦-បុគ្គលដាតហូសប្រូត ចេះដឹងខ្លួសាស្ត្រវិជ្ជាតាំងឡាយច្រេន ឧហិមា តាតាត់ខ្លួសេចក្តីសន្ធិះសង្ស័យត្រប់ប្រការបាន កាលបេី សេចក្តីលោភចង់បាន មកបំបាំងគំនិតឲ្យល្ងិតសូន្យសុងហើយ កំតែងខ្លួលសេចក្តីទុក្ខលំបាកគោកយ៉ាក ។

៤៧-សេចក្តីក្រោធមានដេីមកំណេីតមកពីលោភ:, តាមកនកេីតមក

www.budinst.gov.kh www.elibraryofcambodia.org

ព័លោក: មោហ: និងសេចក្តីវិនាស កំកើតមកពីលោក:ដែរ ព្រោះ
ហេតុនោះ លោក:ជាប្រភពនៃសេចក្តីអាក្រក់ត្រប់ប្រការ ។

៦៨- ដោយតិត ប្រើសមាសមិនដែលគ្មានទេ បើពុកជាដូច្នេះ
ព្រះកមកំទ្រង់នៅតែជាប់ព្រះទ័យចង់ថានប្រើសមាស រីសេចក្តីអន្តរាយ
ក្នុងកាលខែក្តុមកដល់ សូមប្រាជ្ញានៃបុរសជាតិ កំត្រូវប់ជា ឆ្លឹត
ឆ្លើល់ តែតមិនយល់ថានដែរ ។

លំដាប់នោះ ព្រាហមាំឆ្លាយត្រូវលប់ជាប់ក្រញាំមាំនអស់គ្នា ។
ឯកព្រាហមាំឆ្លាយដែលផ្សឹស្តាប់ពាក្យព្រាហមាអ្នកនិយាយនោះ កំដេរ
ប្រទេចផ្តាសា អើរទាំដោយប្រការផ្សេង ។ ព្រោះថា:

៦៩. (១)បុគ្គលមិនគប្បី ចេញមុខជាមេឆណៈ ធ្វើការងារណា
ដែលសំរេចប្រយោជន៍ទៅហើយ ត្រូវបានផលស្មើគ្នាទេ ព្រោះថា ចើ
ការងារនោះអន្តរាយវិញ អ្នកចេញមុខនោះត្រូវស្តាប់ក្នុងចិនោះមុនគេ ។
កាលដែលព្រាហមាំឆ្លាយ កំពុងអើរទាំគោលគោសព្រាហមអ្នក
និយាយនោះ ស្តេចព្រាហប្រកាសឲ្យដឹងច្បាស់ថា: «គោសនេះមិនមែន

១- ហ៊ិតោបទេសសេចក្តីប្រែជាភាសាបារាំងរបស់លោកស៊ីរ៉ូ និង សេចក្តីប្រែជាភាសា
សៀម របស់លោកនាគប្រទីប មានគាថាលើសនេះ គឺ ការមិនបានទុច្ចានជាទ្រព្យ លោក
ពោលថា ជាផ្លូវតាំឲ្យកើតអន្តរាយ, ការទុច្ចានជាទ្រព្យឈ្នះហើយ ជាផ្លូវតាំឲ្យកើតសេចក្តីចំរើន,
ខរជនដើរផ្លូវណាក៏ដើរចុះតាមចិត្តប្រាថ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

ទោសត្រាថជាអ្នកនាំនោះទេ ។, ត្រោះថា៖

✓ ๓๐- សូម្បីមិត្រ ជាអ្នកធ្វើប្រយោជន៍ច្រើនៗ ក៏អាចក្លាយទៅជាដើមហេតុនាំបណ្តាលឲ្យកើតអន្តរាយដ្ឋាក់មកបាន ដូចជាស្នងមេនោអាចទៅជាស្ថិនចង់កូននោ ។

๓๑- អ្នកណាមួយ អាចជួយអ្នកមានត្រោះឲ្យរួចពីក្តីអន្តរាយដែលមកដល់ អ្នកនោះ លោកពុកជាផៅពង្ស; ឯអ្នកចណ្តិតតែមាត់បានតែគោលបន្ទោសខ្លាក់ពុសទៅគេ អួតថាខ្លួនជួយស្រោចស្រង់ឲ្យរួចពីក្តីភ័យ ន៏ឯពុកថាជាផៅពង្សពុំបានទេរ៉ៃ ។

ក្នុងគ្រាក្រ ការថយកម្លាំងចិត្តជាលក្ខណៈបុរសតម្រក់ ។ ក្នុងរឿងនេះ· ត្រូវសំដែងសេចក្តីមុងមាត់អង់អាច ហើយត្រិះរិះរកឧបាយរើខ្លួនតទៅ ត្រោះថា:

๓๒- (๑)ចិត្តម៉ឺងមាត់ក្នុងគ្រាក្រខ្លុកព្រួយ, ចិត្តធឹងធឺងក្នុងគ្រាសុខចំរើន, សេចក្តីអង់អាចក្នុងទីប្រជុំដោយជនសំដីថ្លៃមាត់, ចិត្តក្លៀវក្លាក្នុងរណរង្គ(๒), ចិត្តត្រេកអរក្នុងយស ន៏ឯចិត្តស្រាកស្រេចញាក្នុងការសិក្សា

๑- ហិតោបទេស សេចក្តីប្រែជាភាសាបារាំងរបស់លោកឡង់សីរ៉ូ មានន័យថាលើសនឹងប្លេះខ្លាជនណា អាចនឹងស្រោចស្រង់យើងឲ្យរួចពីក្តីអន្តរាយ ន៏ឯបេះរកឧបាយដួយឲ្យរួចភ្លាម ។ មិនបង្អង់, ខ្លាជនខោះ លោកហៅថា មិត្រ, ពិត ។ ๒ សមរភូមិទីចំបាំងជាញឹយ ។

www.budinst.gov.kh www.elibraryofcambodia.org

ពាំងអស់នេះ ជាលក្ខណៈសម្បត្តិមានជាប្រក្រតី ចំពោះពែកបុគ្គលមានមហាគ្នេន (មានចិត្តដ៏ប្រសើរ) ។

๗๓- អ្នកណាមិនរីករាយហួសហេតុ ក្នុងគ្រាបានសេចក្តីសុខចំរើន, មិនខ្ជិលកម្ចាំងចិត្ត ក្នុងគ្រាក្រខ្សត់ក្រួយ, មានសេចក្តីក្លាហានក្នុងរណរង្គ, មានចរិតកូនដែលមានតិលក:(๑) ដូច្នេះក្នុងលោកពាំងពីរនេះកម្រមានណាស់ ។

๗๔- ក្នុងលោកនេះ ទោសខ្លះប្រការ បុគ្គលច្រើនថ្នាសេចក្តីសុខចំរើន គួរតម្បីលះបង់ចោល តែដោកទ្រមក់ ๑ ខ្លែលទ្រអូស ๑ ភ័យ ๑ ក្រោធ ๑ ទន់ម្ហូរមុខ ๑ និង ខ្សឹកខ្សួយតយូរក្រោយនេះ ๑ ។

៧ទ្បាយនេះ គួរយើងពាំងអស់គ្នាធ្វើយ៉ាងនេះ ត្រូវអ្នកពាំងអស់ស្រុះចិត្តគ្នាតែមួយ ហើយស្ទុះហ៊ែរតែមួយឯកច្ឆន្ទាឲ្យត្រមាំគ្នា ទើបរបើកលង់រួចខ្លួនបាន ព្រោះថា ៖

๗๕- ការវេញចង់ចាប់វត្ថុអ្វីមួយ សូម្បីតួចគ្នាឲ្យរួបរួមគ្នា កំសាចញាំងការងារឲ្យសម្រេចប្រយោជន៍បាន ដូចគេច្រមួលស្មៅវេញជាខ្នង់យកទៅធ្វើជំរកុះប្រទង់ឲ្យជាប់ចោលទៅណាមិនរួច ។

๑- បុរិសលក្ខណៈនៃបុគ្គលដ៏ប្រសើរក្នុងត្រៃភព ជាតិវណ្ណៈចិត្ត តិលក: នេះយកទៅតួសទៅថ្ងាស ពុកជាគ្រឿងប្រសើរសម្រាប់ស់តាល់តិកាយខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

ហិរោចទេស

៣៦- ការចង់ចាប់រឿងត្រកួលរថស្វ័នសូម្បីតែរបីនាក់ ទ្បើរួមមួលត្រកួលគ្នា កំដាការនាំចូរសើស្អណាស់ ដូចគ្រាប់ស្រូវដែលចកសំចកចេញហើយ យកទៅសាបព្រោះមិនដុះលូតលាស់ទៀតឡើយ ។

លុះត្រាចកាំនឡាយ ចានស្តាប់ពាក្យណែនាំស្តេចត្រាច ឈ្មោះចិត្តត្រើតហើយ ត្រមត្រៀងចបួលគ្នាសុះហើរជាឯកច្ឆហារ រេបើកលប់ចាន រួចតែក្តីនាសអន្តកយនោះទៅហោង ។ រីឯត្រានចកូរ្តែនលចចាំមើល ឃើញហ្វូងចកូរ្តស្រុះគ្នាខះស្ងាចហើរ រេបើកលប់រត់រួចទៅចានដួចោះ កំនឹកស្តាយណាស់ រត់ទៅតាមចណ្តើរតែកចណ្តើរថា៖

៣៧- ហ្វូងចកូរនេះ ស្រុះចិត្តចនិគ្នាជាចាច់ សុះហើររេបើកលប់រត់រួចទៅអស់រលើង តែរេបើកចុះជាដកចណា ភាន់ឆ្គងទៅក្នុងកណ្តាច់ដែនគ្នាតញ្ជាដកចនោះមិនខានឡើយ ។

ចកូរ្តាំងឡាយ ទំប្រើងហើរទៅឆ្ងាយសន្ធឹម ក្រទៀកមើលមកក្រោយ ឃើញត្រានអស់សង្ឃឹមក្រឡាច់រលៀងវិញហើយ កំសួរទៅកាន់ស្តេចត្រាចចិត្តត្រើតថា: ចតិត្រលោកជាស្តេចចកូរ្ត ឥឡូវនេះ តើគួរនឹងធ្វើដូចម្តេច តទៅទៀត ? », ស្តេចត្រាចឈ្មោះចិត្តត្រើតធ្វើយតចថា ៖

៣៨- មាគ, មិត្រ និង ចិគ ទៃត្រអង្គនេះជាអ្នកធ្វើហិតានុហិតតាមសភាតទ្ងន ឯអ្នកដទៃទៀតក៏ធ្វើហិតានុហិតវែចនេះដែរ ត្រោះគេយក

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្រ

តាចំមាត, មិត្រ បិតា មកពុកជាហេតុដើម ។

កាលហើជូខ្នេះ ឃើងមានមិត្រមួយ ឈ្មោះហិរណ្យកៈជាស្តេចកណ្តុរ ចិញ្ចឹមជីវិតតាស្រុយៅតាអរញ្ញប្រទេសឈ្មោះចិត្រវ័ន ទៀបនេះស្មើនឆ្នាក័ ឃើងនឹងទៅសួមឲ្យជួយកកេរកាត់លថ់ ដោះឲ្យរួចពីគ្រោះកាចចង្រៃនេះដោយឆាប់ញេក ។ លុះតាណាឃើញជូច្នោះហើយ ព្រោចតាំងនោះ កំហបួលគ្នាហើរត្រសនៅជិតត្រង់(•) ជាទីលំនៅនៃស្តេចកណ្តុរឈ្មោះហិរណ្យកៈនោះ ។

ឯស្តេចកណ្តុរជាសត្វមានសេចក្តីប្រយ័ត្នខ្លួន ដោយក្តីរង្គៀសតិអយន្តកាយ បានកាយត្រង់មួយមានមាត់មួយរយកនៃ ហើយតាស្រុយៅក្នុងទីនោះ ។ លំដាប់នោះ ស្តេចកណ្តុរឈ្មោះហិរណ្យកៈ ឮសូរសន្ធឹកព្រោចហើរមកចុះជិតលំនៅខ្លួន កំតក់ស្លុតរន្ធត់ក្នុងចិត្ត ទំរាំតម្រិលដោយសេចក្តីព្រួយបារម្ភ ពួនសម្ងំនៅស្ងៀមឈឹងមិនមាត់ឡើយ ។

ស្តេចព្រោចឈ្មោះចិត្រគ្រីតវែស្រែកសួរថា : អីសំឡាញ់ហិរណ្យកៈ ! ហេតុអ្វីក៏សំឡាញ់នៅស្ងៀមទ្រមឹងទ្រមើយ មិនឆាំតាមាត់កចេញមកឧទ្ទូលយើងសោះ ? » ។ណៈនោះ ស្តេចកណ្តុរស្តាប់សំដីស្តេចព្រោចបាន កំស្លុតរន្ធត់ចេញមកក្រៅដោយប្រញាប់ប្រញាល់ ហើយនៅយន្តូន

•- រន្ធ, ប្រហោង

www.budinst.gov.kh www.elibraryofcambodia.org

ទៅវិញថា : « អ៊ាំ សំឡាញ់ ! ខ្ញុំមានភ័ត្តណាស់ ចំត្រង្រ៉ាតសំឡាញ់ ជាមិត្រស្មើចិត្តស្មើថ្នើមគ្នា ឥឡូវមកផល់ហើយតើ ! ។

៣៩-ក្នុងលោកនេះ មិនមាននរណាមានបុណ្យវាសនា ជាងអ្នកដែលបានជួបប្រទះសន្តនារីករាយជាមួយនឹងមិត្រ អ្នកដែលបរិភោគរួមមួយតន្ត្រែដោយមិត្រ និង អ្នកដែលប្រស្រ័យប្រាប់សុខទុក្ខទៅវិញទៅមកមួយតន្ត្រែដោយមិត្រដូច្នេះឯង ។

កាលស្តេចកណ្តារយើញព្រាហ្មចាំងឡាយជាប់ចំណងលង់ដូច្នោះ ក៏ភ្ញាក់ព្រឺតព្រឹងមួយស្រែចក់ ទើបសួរហេតុនោះថា : « នែសំឡាញ់ ! បុះហេតុនេះដូចម្តេច ? » ។ ស្តេចព្រាហ្មឆ្លើយប្រាប់ថា : « អំពើនេះជាផលនៃកម្មចស់យើងត្រង់ឯពីបុកណាកាលណាំសំឡាញ់ ! ព្រោះថា :

៤០-សេចក្តីល្អ និង សេចក្តីអាក្រក់ ជាកម្មចស់ខ្លួនឯណា ព្រោះហេតុឯណា, ដោយប្រការណា, ក្នុងកាលណា, ជាតិណា, ក្នុងទីណា អំពើនោះ សម្រេចផលតាមអំណាចនៃព្រះព្រហ្មចង្កើតលោក ព្រោះហេតុនោះ ដោយប្រការនោះ ក្នុងកាលនោះ ជាតិនោះ ក្នុងទីនោះ ។

៤១- ភេតាត្យាធិ, សោកសង្រ្តែងសង្រៃ, សេចក្តីក្តៅក្រហាយការជាប់អន្ទាក់ចំណង និង សេចក្តីវិនាសអន្តរាយទាំងឡាយនេះ ជាផលដែលមកពីត្រីក្បាជាតិ គឺទោសកំហុសរបស់ខ្លួនរបស់មនុស្សទាំងឡាយ ។

www.budinst.gov.kh www.elibraryofcambodia.org

ស្តេចកណ្តាលបានស្តាប់ពាក្យនោះហើយ ក៏ស្ទុះចូលទៅជិតសំឡាញ់ ដើម្បីកាត់ចំណងលប់ដោយប្រញាប់ប្រញាល់ ។ ស្តេចត្រាចហាត់ថា: «សំឡាញ់! កុំអាល ឈប់សិន! ចូរអ្នកកាត់ចំណងត្រាចចាំឯឡាយដែល ជាបរិវារមុនសិន ហើយសឹមកាត់ចំណងខ្ញុំក្រោយគេ ។ ហិរណ្យកៈតបទៀតថា: «កម្មាំងខ្ញុំខ្លាយណាស់ ធ្មេញក៏មិនស្រួចមាំមួន ហេតុនេះធ្វើម្តេចនឹងអាចកាត់អន្ទាក់ឲ្យបរិវារអ្នកគ្រប់គ្នាត្រេចផុតម្ល៉េះបាន ។ បើដូច្នោះ ខ្ញុំនឹងកកេរកាត់ចំណងឲ្យសំឡាញ់មុនសិន បើធ្មេញខ្ញុំមិនខាន់រេចរឹលទេ ខ្ញុំនឹងកកេរកាត់ឲ្យបរិវារសំឡាញ់ចាំឯឡាយតទៅទៀតជាលំដាប់ តាមកម្មាំងដែលអាចនឹងកកេរកាត់បាន» ។ ចំត្រង់ត្រូតប្រពៃកន្លាំងៗថា «ទេ! ទេ! សំឡាញ់កុំធ្វើដូច្នោះ គោះថាយ៉ាងណាក៏ដោយ សូមសំឡាញ់ឈប់មេត្តាកាត់ចំណងឲ្យបរិវារមុនសិន សឹមកាត់ឲ្យខ្ញុំក្រោយគេ» ។ ស្តេចកណ្តាលថ្លែងសុភាសិតថា: « កិរិយាការពារថែរក្សាខ្លួនជាមួយនឹងបរិវារ ដោយការចិញ្ចឹមខ្លួនជាពលិកម្មនោះ អ្នកប្រាជ្ញទ្វេរត្រូវតែក្នុងនីតិសាស្ត្រ លោកមិនសរសើរទេ ព្រោះថា ៖

៤២- បុគ្គលគប្បីថែរក្សាទ្រព្យទុកដើម្បីការពារគ្រោះក្រ គប្បីរក្សាការយោងដោយទ្រព្យ តែគប្បីរក្សាខ្លួនរឿយៗដោយការយោងដោយទ្រព្យផង។

៤៣- ប្រាណតែជីវិត មានការតាំងនៅមាំជាហេតុដើម្បីប្រព្រឹត្តធម៌

www.budinst.gov.kh www.elibraryofcambodia.org

ស្មែនរកទ្រព្យសម្បត្តិ សេពកាម និង រកខោកសួចមិ បើច្រាណតិជ័រតវិនាសហើយ អ្វីមួយដែលឈ្មោះថាមិនវិនាសទៅខ្ទុះ? ការរក្សាច្រាណតិជ័រតឲ្យតន់រឹងទៅ អ្វីមួយដែលឈ្មោះថាមិនរក្សាផងដែរ?

ស្តេចត្រាចគោលទៀងថា: "សម្ងាញ់អើយសំដីសម្ងាញ់និយាយមកអម្បាញ់មិញនេះ ជាគោលនៃនីតិសាស្ត្រពិតហើយ តែថារូបខ្ញុំទៅតែមិនអស់ចិត្ត មិនអាចឈរមើលចរិកវែដែលអាស្រ័យទៅជាមួយ រង់ទុក្ខវេទនាដូច្នេះចំពោះភ្នែកសោះ ចាន់ជាទំនង់រកសម្ងាញ់ដូច្នេះឯង ព្រោះថា ៖

๘๖-អ្នកច្រាជ្រុតច្បាស់ចេងទ្រព្យផង ជ័រតផង ជាពលិកម្ម ដើម្បីការពារផងដែរ ការចរិញ្ចានជ័រតក្នុងអំពើល្អបែបនេះ ជាកិត្តិយសប្រសើរណាស់ ចើសេចក្តីស្លាប់ជាធម្មតាទៀត ។

សម្ងាញ់! មានសុភាសិតដែលគួរនឹងតាញយកមកជាឧទាហរណ៍ទៀតដូច្នេះថា ៖

๘๗-ចណ្តាគុណធម៌ទាំងឡាយ គឺជាតិ ទ្រព្យ និង គុណសម្បត្តិ គុណធម៌ ៣ ប្រការនេះ ចរិកមានស្មើនឹងម្ចាស់, សម្ងាញ់! ចូរអ្នកនិយាយទៅយើញច្បាស់មកមើល ដូចម្តេចដែលហៅថា ភាពនៃខ្លួនជាធំវិសេសជាងគេ? ដល់កាលណាទៅ ត្រូវសំដែងភាពជាធំ? ។

๘๖- ចរិកទាំងឡាយនេះ មិនមានគ្រឿងភាហារចិញ្ចឹមជ័រត

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំមិនលះបង់ការសំណាក់ពីឆាក់ចោលខ្ញុំទេ ព្រោះហេតុនោះ សូម
សម្លាញ់ជួយស្រោចស្រង់ជីវិតចរៀរចាំងឡាយនេះមុនសិន សូមរ៉ែវែក្រវ
ក្តីវិនាសអន្តរាយណាមួយ ខ្ញុំក៏មិនថាដែរ ។

៤៧- នែសម្លាញ់ ចូរលះបង់ព្រួយក្នុងកន្សែរ: កន្លែងដែលខ្ញុំមិនក្តី
ដោយសាច់ទឹកមួត្រ,អាចម៍ និង ឆ្អឹងឆ្អែងជារបស់តូចផុយរលួយនេះចាល
ឲ្យស្រឡះទៅ សូមជួយអភិបាលលើកដំកើង យសកេរ្តិ៍ឈ្មោះខ្ញុំវិញ។

៤៨- ចារបើបុគ្គលឧត្តមបានខ្ញុំវកំភ្លុយស ដែលខឿងតាត់ មិន
មានមន្ទិល ដោយការចរិញ្ញាឧកាយដែលផ្គុំដោយគ្រឿងមន្ទិលសៅហ្មង
ស្មោកគ្រោក មិនខឿងតាត់នេះបាន បើដូច្នោះតើបុគ្គលនឹងមិនឧត្តឹកាន
យកខ្ញុំវគុណជាមិត្តភ័យសនោះឬអ្វី ?

៤៩- សរីរ: ខ្លួន កិត្តិគុណ មានចម្ងៃះតាំងនៅឆ្ងាយពីគ្នាលខ្ញុំដ
លម្ងៃចណាស់ . សរីរ:នេះ រលាំរលាយទៅក្នុងមួយរាណ: ឯកិត្តិគុណ
ស្ថិតនៅរហូតកល្បាវសាន ។

/ កាលេស្តេចកណ្តាលបានស្តាប់ពាក្យគោលដូច្នេះហើយ ក៏មានចិត្ត
រីករាយក្រៃលែង ព្រះមានព្រះសូរិយានិយាយតបថា : « សាធុ ! សម្លាញ់
សាធុ ! សម្លាញ់ឯងមានចិត្តមេត្តាករុណាខ្ពង់ខ្ពស់ ចំពោះចរិញ្ញាដូច្នេះល្អ

www.budinst.gov.kh www.elibraryofcambodia.org

ណាស់ សមគួរនឹងបានជាចំពូកនឹងគ្រែលោកនេះ ។ ស្តេចកណ្តូរនិយាយ
ហើយក៏កេរកាត់ចំណង ដែលចងត្រោមចាំងឡាយនោះ ឲ្យរួចស្រឡះ
ភ្លាមកាលនោះឯងហោង ។ លំដាប់នោះ ស្តេចកណ្តុរសំដែងសេចក្តីសា
ទរចំពោះត្រោមចាំងឡាយ ហើយមែមៅនិយាយលួងលោមស្តេចត្រោម
ថា : « ម្នៃសម្លាញ់ចិត្តត្រឹត! ក្នុងលោកនេះ ការជាប់លប់ជាប់អន្ទាក់
ជាធម្មតាទេ ត្រូវខ្លាចទោសតែអន្តរាយចាំងអស់នេះ តែកុំគាក់អន់
ចិត្តព្រួយបារម្ភចំពោះភ័ព្វវាសនាដូច្នេះឡើយ ព្រោះថា :

៥០-ក្នុងលោកនេះ សត្វចកូរមើលឃើញអាហារចំណីដែលជិត
នៅឆ្ងាយជាងមួយរយយោជន៍ តែសត្វចកូរនោះ កាលបើគ្រោះជាន
គ្រោះជាំមកដល់ហើយ មើលចំណងមិនឃើញទេ ។

៥១-កាលខ្ញុំបានឃើញព្រះចន្ទនិងព្រះអាទិត្យ ត្រូវរាហូចាប់បៀត
បៀន, ឃើញដីរ៉ែនិង ខានជាប់ចំណង, ឃើញអ្នកប្រាជ្ញខ្លៀវឆ្លាតត្រូវក្តៅ
ក្រៃក្រលំបាកគេកយាំក ខ្ញុំមានមតិដូច្នេះថា « ឧហ្ន៎ វិធីកម្មនេះមាន
ឫទ្ធិតេជៈកម្ចាំងក្លាំងណាស់តើ! »

៥២-រីឯតជាតិ (ចកូរ) ពាំងឡាយ ហ៊ានហើរខ្ពស់ត្រដួចចរមៅ
ឰដ៏អាកាសព្រាមា, សមបើដែរ! ឆ្លាក់ដល់ក្តីវិនាសអន្តរាយបាន, មច្ច
ជាតិពាំងឡាយអាស្រ័យនៅក្នុងសមុទ្រសាគរ មានទឹកដ៏ជ្រាលជ្រៅ

www.budinst.gov.kh www.elibraryofcambodia.org

កប់ប្រមាណមិនបាន សមចើដែរ ! ត្រូវគ្រានប្រមន់ចាប់យកបាននោះជាយ
ការប៉ុនប្រសប់. ចើដូច្នោះមែន ក្នុងលោកនេះ ចាំបាច់មានខ្លួនតែឯង្គីអ្វី ?
ចាំបាច់មានសុខ្លួនតែឯង្គីអ្វី? ចាំបាច់មានគុណតាប់បានលោកដ៏ស្ងួតស្ងៃឯង្គីអ្វី?
សេចក្តីពិត, ព្រះកាល(១) ជាអ្នកមានដៃក្រាលលាតត្រដាង ខ្លួវសេចក្តី
អន្តកយខ្លួនៗ ហើយចាប់សម្លាប់សត្វតាំងឡាយ សូមឲ្យស្តេតនៅក្នុងទី
ឆ្ងាយស្រេខ្លាចកំដោយ ។

ស្តេចកណ្តុរនិយាយដាស់តឿនក្រើនរំឭកដោយពាក្យសុភាសិត ធ្វើ
ចដើមសណ្តោះខ្លួលកក់ខាក់ ចាប់ទេជជាំគ្រាចចិត្រគ្រឹតនោះហើយ ទើប
ចញ្ជូនឲ្យហើរទៅកាន់ស្រុកទេស តាមសេចក្តីប្រាថ្នាត្រមាំងចរៀងទៅ
ហោង ។ ឯស្តេចកណ្តុរ កំចូលទៅក្នុងព្រៃដាលំនៅរបស់ខ្លួនវិញ
ក្នុងពេលនោះឯង ។

ថា- បុគ្គលនឲ្យសែ្វងរកសេពគប់មិត្រ ឲ្យបានច្រើនចំនួនកប់រយ
ចូរមើល ! សត្វគ្រាចចាំងឡាយរួចពីចំណងចងសម្លាប់ខ្លួនបាន ព្រោះ
អាស្រ័យស្តេចកណ្តុរជាមិត្រ ។

កាលនោះ ក្អែកឈ្មោះលឃុបតនកៈ បានឃើញដាក់ឮស់ខ្លួវ

១-សេចក្តីស្លាប់ អ្នកកាន់សាសនាព្រាហ្មណ៍ ទុកជាទេវតាមួយអង្គ កាន់តាទីទាងការ
ចំផ្លាញជីវិតសត្វ ។

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

ព្រឹត្តិការណ៍តាំងពីដើមដល់ចុងកំពឹកសេចក្តីចប់ក្នុងឥតខ្ចោះមា ទើបបន្ទាប់ថា
សរសើរថា: «ហៃសម្លាញ់ហិរណ្យក: បងឯងមានគុណតាប់ប្រសើរណាស់ ឥឡូវនេះខ្ញុំមកសូមយកអ្នកធ្វើជាមិត្រ! ឯបងកំណត់តស្រង្គ្រោះលើកយកបូខ្ញុំធ្វើជាមិត្រវិញដែរ» ។ កណ្តុរបានឮតាក្យសរសើរបស់ក្អែកឈ្មោះលយុថតនកៈហើយ ស្រែកសួរតាក្នុងត្រងំមកថា: «ចុះបងឈ្មោះអ្វី?» ក្អែកឆ្លើយប្រាប់ថា ឈ្មោះលយុថតនកៈណាបង!..។ ស្តេចកណ្តុរ ឮហើយឥស់សំណើច សើចបណ្តើរនិយាយបណ្តើរថា: «យកបងជាក្អែកមកផ្ទុកជាមិត្រម្តេចកើត? ព្រោះថា:

៥៤-ក្នុងលោកនេះ អ្នកមានប្រាជ្ញាតែងធ្វើសមាគមចំពោះតែអ្នកដែលមានសភាពដូចគ្នាគួរបង ជាមិត្របាន ចុះបើខ្លួនខ្ញុំត្រូវជាចំណីតាហារឯខ្លួនបងជាអ្នកស៊ី ដូច្នេះតើគួរបងគ្នាធ្វើជាមិត្រម្តេចបាន?

៥៥- ការបងគ្នាជាមិត្រ រវាងអ្នកស៊ីនឹងអ្នកត្រូវគេស៊ី លោកតាលថាហេតុនាំឲ្យវិបត្តិមិត្រភាព ដូចជារឿងប្រើសជាប់អន្ទាក់ ព្រោះបានបានក្អែកជួយស្រោចស្រង់ ។

ក្អែកសួរទៀតថា: ចុះរឿងនោះ តើដូចម្តេច? កណ្តុរហិរណ្យក: ចាប់ផ្តើមរៀបរាប់រឿងនោះដូចតទៅនេះ ...

www.budinst.gov.kh www.elibraryofcambodia.org

កថាទី ២

រឿងប្រើស ចចក និង កែ្លក

ក្នុងប្រទេសមគធៈ មានព្រៃធំមួយឈ្មោះចម្បាកវត៌ជាទីគាស្រ័យនៅ នៃប្រើស និង កែ្លក សត្វទាំងពីរនេះចងគ្នាជាមិត្រស្និទ្ធស្នេហ ស្រឡាញ់គ្នាយូរយារណាស់មកហើយ ។ ប្រើសតែងត្រេកត្រអាលចរទៅស្វែងរកស្មៅជាចំណីគាហារ ដោយទំនើងចិត្តតាមធម្មតា ជាវិស័យសត្វឥតមានខ្លាចក្រែងរអែងរគាអ្វីឡើយ រហូតដល់មានគាយធាត់ធំមាំមួនឡើងត្រឡប់ចឡប់ច ។ សម័យមួយ មិនដឹងជាទេសកាលអ្វី ចណ្តាលឲ្យភ្លាយគំនិតភ្លាត់ខ្លួនឲ្យចចកយើញ ។ ឯចចក លុះយើញប្រើសហើយ ក៏ត្រេកអរកទិចកទុចនឹកត្រិះរិះតិតរកឧបាយថា : "ធ្វើដូចម្តេចអេះ អាគ្នាអញនឹងបានស៊ីសាច់ប្រើសមុខគួរឲ្យឆ្ងាញ់ណាស់នេះហ្ន៎ ? តង់ថាន កណ្តាប់ដៃអញទេ អាគ្នាអញនឹងបញ្ជោរបោកវៀរអែចឲ្យស្និទ្ធ ទាល់តែស្លាប់ចិត្តជាមុនសិន" ។ ចចកគិតរកឧបាយយើញហើយក៏ដើរចូលទៅសុំជួបនឹងប្រើស រៀបស្រែកសួរតិចម្ងាយថា : អីសំឡាញ់អើយ ! អ្នកបានច្រកបដោយសេចក្តីសុខសប្បាយឬទេ ? ។ ប្រើសបានឮហើយដណ្តឹងសួរថា: "បងឈ្មោះអ្វី ?" ចចកឆ្លើយប្រាប់ថា: "ឈ្មោះក្បូរខ្ញុំគាស្រ័យនៅតាព្រៃនេះ ឥតមានញាតិសាច់សន្តានតិចតួចទេ នៅត្រមង់ត្រមោចឯកោ

www.budinst.gov.kh www.elibraryofcambodia.org

អនាថាវែកម្ខាក់ឯង ជួបជាមនុស្សស្លាប់ទៅហើយ , គេលនេះ មានភ័ព្វ
សំណាង បានសាងមកជួបនឹងបង នាំឲ្យកើតសេចក្តីស្រឡាញ់គេញ
ចិត្ត ហាក់ដូចជាបានចាប់កំណើតកើតក្នុងលោកនេះជាថ្មីម្តងទៀតហើយ
បានជួបជុំញាតិសន្តានត្រឿងលានវិញ, តទៅបងខ្ញុំសូមធ្វើជាមិត្រស្និទ្ធ
ស្មោះជាមួយនឹងបង គ្រាន់បានជាទីពឹងពាក់ ជាណ្តើរគ្នាទៅមកកែស៊ីតាំង
ពីគេលនេះតទៅ ។ ប្រើសស្តុងចិត្តជឿ ហើយឆ្លើយថា : «មិនអីទេ !
តាមចិត្តបងស្នំត្រចុះ» ។

ក្បែរណោះព្រះខ័នការជាទីគោរព មានស្តេរឿងភ្លឺក្រចះតណ្ហ
កយ ទ្រង់ចរេចប្រទក្បែរណាក្តីព្រះសុមេរុ រសៀលជ្រឿនជ្រេរទេខន់តាប
រៀបនឹងអស្តង្គតរលត់ចូលទៅកាន់សន្ធិយាកាត្រី ទេវតាក្តាងឆត្តមិនទិស
សត្តាំងពីរ កំលាភណ្តើរគ្នាត្រសងចូលទៅកាន់ទីលំនៅនៃប្រើស ។
កាលនោះ អ្នកឈ្មោះសុពុទ្ធ ដែលជាមិត្រស្និទ្ធស្មោះនឹងសត្វប្រើស
មកអស់កាលយូរតែឆ្ងៃនហើយ កំពុងទុំគាស្រែយៅលើមែកចំបក់នោះ
សុះឃើញសត្តាំងពីរចណ្តើរគ្នាមកដល់ កំសួរទៅថា ! « ហៃសម្លាញ់
ចត្រាឆ្គ: ! អ្នកទីពីរនោះហ្ន៎ ! ត្រូវជាអ្នកនឹងបងឯង » ។ ប្រើសឆ្លើយ
ត្រាប់ថា : « ជាសត្វចចក ចូលមកសួរចងស្តានមេត្រីកប់តានយើង » ។
អ្នកកំពោលទៀតថា នែសម្លាញ់ ! ការទុកចិត្តចងមេត្រីកប់តានជា

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្រ

មួយអាតន្តុក:មិនស្គាល់មុខដូច្នេះមិនល្អទេ ព្រោះថា ៖

៥៦- អ្នកណាមិនមួយ មិនគួរតបញ្ជូរទីតាស្រ័យនៅរួមគ្នាជាមួយមនុស្ស មិនស្គាល់មុខ មានត្រកូលផ្សែងគ្នាទៀយ ដូចគ្នាតឈ្មោះជាខ្ពង់:ត្រូវគេសម្លាប់បង់ ព្រោះគោសមកតាំ្ន » ។

ប្រើសនិងចកសួរទៀងថា : « រឿងនោះតើដូចម្តេច ? ។ ក្អែកថាថ្វែងរឿងនោះថា : -

កថាទី ៣

រឿងក្អែក, ក្តា និង បក្សី

នៅក្បែរត្រើយទន្លេគង្គា លើកំពូលផ្សែកូដ មានដែ្រមួយដើមធំត្រសុំសាខាជិះហើយដោយត្រង់ជាទីតាស្រ័យនៅនៃបក្សីនិងក្អែកឈ្មោះជាខ្ពង់: ។ ដោយកម្មតាក្រក់តាមទ្បើផល ក្អែកនោះ ក៏ទៅជាទ្វាក់ងងឹតងងល់ក្រចករេចរឹលក្បែលអស់រលីង ។ ហ្វូងបក្សីជាតិតាំងពាយដែលតាស្រ័យនៅតាដើមដែ្រនោះ មានចិត្តតាណិតអាសូរ តែងរំលែកចែកតាហារទ្វូងចន្តិច ។ ម្នាក់ទ្បើផល់ក្អែកនោះ ជួយចិញ្ចឹមទ្បើមានជីវិតរស់នៅតទៅ ។ ត្រាតោះ, មានក្តាមួយឈ្មោះទីឃិតណិ: ចូលមករកចាប់កូនបក្សីស៊ុជាចំណីតាហារនៅក្នុងត្រង់ឈើនោះ ។ កូនបក្សីតាំងពាយ តាលឃើញក្តាកំពុងដើរចូលមក ក៏តិតភ័យខ្លាច់រត់ទ្វេទ្បាកោហាលគេញតាំងត្រង់ ។ ក្អែក

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

ឈ្មោះជាខ្ពស់ ឮនឮសូរសេះមួងអីឯកនឹងខ្សែវាជួញ កំស្រែកសួរទៅថា "អាណាមកធ្វើអ៊ូឲ្យគ្រែលត្រមល់ចល់ដូច្នេះ ? " ឆ្លើយតបទៅវិញថា "ខ្ញុំជាសត្វឆ្កែ" ។ ឯសេះមួងមើលទៅឃើញឆ្កែ ក៏គក់ស្មុតញាប់ញ័រគ្រែរះគិតថា : "អាឆ្កែអញ ដល់គ្រោះស្លាប់ហើយតើ" គ្រោះថា !

๘๗-ជាតិណា ក្តីភយន្តរាយមិនទាន់មកដល់ទេ ជាតិនោះបុគ្គលតម្រិះប្រុងប្រយ័ត្នដល់ភ័យនោះ បើក្តីភយន្តរាយមកដល់ហើយ បុគ្គលតម្រិះក្លាហានតស៊ូនឹងភ័យនោះ តាមគំនិតខ្លួនដែលបានគិតពុះស្រួចហើយ។ ឥឡូវនេះ អាឆ្កែអញចូលមកខាំខ្លួនដល់ជិតក្តីស្លាប់ហើយ ទើបជាតខ្លួនថយរត់ទៅក្រោយវិញក៏មិនបាន. ល្អើយចុះបើមានការណ៍យ៉ាងណាក៏តទៀត ក៏តាមការណ៍ចុះ អាឆ្កែអញនឹងចូលទៅឲ្យដល់ឆ្កែ រៀបអែបឲ្យស្និទ្ធជាមុនសិន ។ ឆ្កែគក់ឃើញដូច្នេះហើយ ក៏លោតចូលទៅជិតឆ្កែ ពោលតាស្សំតះសួរថា: "បពិត្រលោកអាចារ្យ! ខ្ញុំបាទសូមសំតះជម្រាបសួរលោក" ។ ឆ្កែសួរថា: "ឯងជាអ្វី ?" ឆ្កែឆ្លើយតបទៅវិញថា: "ខ្ញុំបាទជាសត្វឆ្កែ" ។ ឆ្កែនិយាយកំហែងថា: "នែអាសត្វចង្រៃ! ចូរឯងចេញឲ្យឆ្ងាយទៅ បើមិនឯងចេញទេ អាឯងត្រូវគ្រោះស្លាប់ឥឡូវមិនខាន" ។ ឆ្កែនិយាយអង្វរកថា: "សូមលោកស្តាប់តាស្សខ្ញុំបាទសិន កាលបើលោកស្តាប់តាស្សខ្ញុំបាទហើយ ឃើញថាគួរសម្លាប់

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្ត

ព្រះពុទ្ធសាសនបណ្ឌិត្យ
LIBRARY
BUDDHIST INSTITUTE

កាលណា ខ្ញុំបាទកំសុខចិត្តខ្លួលស្លាប់ឥតប្រកែកកាលខ្លះ ព្រោះថា:

៥៨- ហេតុអ្វីកំស្រាប់តែត្រូវគេគាប់សម្លាប់ ឬ ត្រូវគេបូជាដល់អ្នកណាខ្លះមួយ តាមតែជាតំអ្វីកំដោយតែម្តង តួរតែគិតពាក្យណាទ្បាំញ៉ែមើលឲ្យឃើញច្បាស់សេចក្តីប្រព្រឹត្តរបស់គេសិន សឹមយល់ជាគួរសម្លាប់ឬគុំខ្លះ គួរបូជា ។

ភ្នាតស្លាប់ហើយនិយាយថា: «មើល៎! និយាយមកមើលតាឯងចូលមកនេះត្រូវការអ្វី?» ។ ភ្នាឆ្លើយប្រាប់ថា: «ខ្ញុំបាទនៅក្បែរត្រើយខ្ញុំតង្កាខេរឯង ប្រព្រឹត្តមុជទឹកលាងជ្រាប(១)ជាន់ខ្ពស់ ប្រព្រឹត្តត្រហ្មចរិយធម៌ជាប្រក្រតី មិនហ៊ានស៊ីសាច់ឈាមទេ សមាទានតែបន្លែឃ្លាយណាត្រគ(២) ខ្ញុំបាទបានឮហ្វូងជាតិ សរសើរគុណលោក ចំពោះមុខខ្ញុំបាទជារឿយៗថា លោកជាអ្នកខេះដឹងច្រើន ចិត្តធ្ងន់ក្នុងធម៌ ល្មមពុកចិត្តស្និទ្ធស្នេហា យកជាវិស្សាសភូមិ, ហេតុនេះ បានជាខ្ញុំបាទមានចិត្តក្រែកអរ បង់ចូលមកក្រងគ្រាប់ស្លាប់ធម៌រឿនវិញ ព្រាប់តតិលោកតតិធម៌អំពីសំ

១- មើលន័យលក្ខណៈលេខ ១ ទំព័រ ២៦ ។ ការប្រតិបត្តិវត្តតាមដំណើរព្រះបន្ទូលតាមទំនៀមប្រទេសឥណ្ឌា ។ ព្រតខេះមានច្រើនបែប, ព្រតដែលគេប្រតិបត្តិដោយច្រើនគោះគឺការប្រព្រឹត្តបរិភោគថាយ ១៥ ពំនូតទៅថ្ងៃ ១៥កើត ហើយបន្ថយ ១ ថ្ងៃ ១ ពំនូតទៅទាំងរនោចគឺថ្ងៃទី ២ បរិភោគ ១៤ ពំនូតថ្ងៃទី៣ បរិភោគ ១៣ ពំនូត ធ្វើដូច្នេះរៀងរាល់ថ្ងៃដល់ទី ១៥ គេអត់អាហារ ។ ដល់ខាងខ្នើតថ្ងៃ ១ កើត គេបរិភោគបង្គើន ១ ពំនូតវិញ គឺថ្ងៃទី១ បរិភោគ ១ ពំនូតថ្ងៃទី២ បរិភោគ ២ ពំនូត ធ្វើដូច្នេះរៀងទៅដល់ថ្ងៃ ១៥ កើត គេបរិភោគ ១៥ពំនូត។

www.budinst.gov.kh www.elibraryofcambodia.org

ហិគោចទេស

ណាត់លោកដែលជាបុគ្គលចាស់ព្រឹទ្ធាចារ្យ មានការចេះដឹងស្ទាត់ដំនាញ ច្រើនចប់ខ្នាតក្នុងវិជ្ជាផ្សេងៗ ហេតុអ្វី ក៏លោកដែលជាអ្នកចេះធម៌អាច់ ជ្រាលជ្រៅច្រើនជយាំងនេះ ចែរទៅជារកឈើងកាច់សម្ងាច់ខ្ទុំបានដែលជាក្បៀវរៅវិញ ព្រោះធម៌ជានាទីអ្នកគ្រប់គ្រងផ្ទះនេះលោកពោលថាដូច្នេះ ៖

៥៩-បុគ្គលនឋ្បីត្រមង្គើចដាសណ្ដោះ ខ្ទួលក្បៀវដែលមកដល់ផ្ទះហើយ ពោះបីក្បៀវជាសត្រូវក៏ដោយ ដូចត្រីក្បាជាតិ វែនឲ្យម្ចប់ជាទីសំចតមិនរើសមុខ សូម្បីអ្នកកាប់ឈើក៏ដោយ ។

ថើខុកជាខ្សែខ្សោយទ្រុឌ្យ មិនមានចំណីតាហារខ្ទួលក្បៀវដែលមកដល់ ដោយហោចទៅ ក៏នូវកាច់តាន់តាក់ខ្ទួលក្បៀវ ដោយសំដីដំពីរកេះជាទីត្រេកអរដែរ ព្រោះថា ៖

៦០-ស្មៅ (ប្រចំបើងសម្រាប់អុជប៉ក្ដឺ) ភូមិទីលំនៅ ទឹក និង សំដីពីរកេះផ្អែមល្ហែម ធម៌ ៤ ប្រការនេះ ក្នុងកាលណាក៏ដោយមិនដែលខ្វះខាតរលីមរលោច ក្នុងផ្ទះលោកអ្នកសប្បុរសទាំងឡាយទេ ។

៦១-(១)លោកសប្បុរសទាំងឡាយតែងសំដែងមេត្តាករុណាចំពោះ

១-ហិគោបទេស សេចក្ដីប្រែជាភាសាថាភ័ង្គ របស់លោកឡង់សឺរ៉ូ និង សេចក្ដីប្រែជាភាសាសៀមរបស់លោកតាគ្រូទីប មានន័យថាលើសន្ធិច្បេះគឺ ទោះបីក្មេងកម្លោះក្រមុំ ឬចាស់ព្រឹទ្ធាចារ្យ ដែលមកផ្ទះហើយ បុគ្គលត្រូវតែជ្រះថ្លាទទួលភក់ទាក់ដោយការរាប់អានយ៉ាងខ្ពង់ខ្ពស់ ព្រោះក្នុងលោកនេះ គេទុកភ្ញៀវជាបុគ្គលខ្ពង់ខ្ពស់ជាងជនទាំងពួង ។

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្រ

សត្វទាំងឡាយមិនរើសមុខសូម្បីបុគ្គលថាកាចក៏ដោយ ដូចជាព្រះចន្ទ
និងថាកំណាញ់តទឹមិនឲ្យដល់លំនៅជនចណ្ឌាល ក៏ឥតអង្គុយមានខ្មៅឡើយ ។

៦៦-កើវិលត្រឡប់ចេញពីផ្ទះអ្នកណា ដោយក្តីក្តៅក្រហាយ
ចំត្តកើវិនោះឈ្មោះថាប្រគល់ឲ្យនូវបាប អកតញ្ញូលដល់អ្នកម្ចាស់ផ្ទះនោះ
ហើយកាន់យកនូវបុណ្យសិរីសួស្តីត្រឡប់ទៅវិញ ។

៦៧- បុគ្គលមានគោក្រកូលខ្ពង់ខ្ពស់ ប៉ើមានកើវិក្រកូល
ចាកតាចមកដល់ផ្ទះហើយ ក៏គួរតែគោរពបូជា តាមគួរដែលតាច
ខ្លួលបាន ព្រោះកើវិតាំងអស់សុទ្ធតែទេវតា ។

ភ្នាកនិយាយតាក់ថា : « ឲ្យឈ្មោះតែឆ្មារហើយ សុទ្ធតែជាសត្វ
ថោកថ្លង់ចំត្តស៊ីសាច់ជាអាហារតាំងអស់ ទៅក្នុងព្រៃដើមឈើនេះ មាន
សុទ្ធតែកូនចកៀរអាស្រ័យទៅ ហេតុនេះក្បែ បានជាអញនិយាយហាម
ឃាត់យ៉ាងនេះ » ។ ឮស្តាប់តាក្សភ្នាកហើយ ក៏ស្រែកគោនទៅជាក់មុខយក
ដើងមុខស្ទាបត្រចៀកតាំងសងខាង ក្រាបសំពះនិយាយបញ្ជាក់ថា ! ខ្ញុំ
បាទបានសិក្សាធម្មសាស្ត្រចប់អស់ដើងហើយ បានប្រព្រឹត្តធម៌ លះ
បង់ កន: ទោស: មោហ: សមាធានចន្ទ្រាយណាព្រត(១) ជាខ្លុះកម្ម
ដ៏ក្រៃលែង សូម្បីតម្ពះធម្មសាស្ត្រតាំងឡាយ ដែលមានសេចក្តីខ្វះបែក

---

១ មើលន័យលក្ខណៈលេខ ២ ទំព័រ ៥១ ។

www.budinst.gov.kh www.elibraryofcambodia.org

ហិរោចទេស

គេតែងជជែកវែកញែកគ្នាទៅវិញទៅមក កំតង់រួមគោលសេចក្តីធំដើមមក
ទៅត្រឹមតែមួយមាំត់គឺ: «អហិសាការមិនបៀតបៀន» ថាជាធម៌ជិះស៊ើ
ក្រៃលែង ព្រោះថា ៖

៦៦- នរជនណា មិនបៀតបៀនសត្វសត្វទាំងឡាយឲ្យក្តៅក្រហាយ
មនញ្ជាយាមអត់ធន់ចំពោះការងារទៅទាំងពួង ទើង ជាឥរិយាបថនាក់តាស្រ័យ
នៃសត្វសត្វ នរជនគេរាប់ថា ភសាធិស្ថានទៅកាន់ស្ថានសួគ៌ ។

៦៧- មានតែធម៌មួយទេ លោកហៅថា «មិត្រធម៌» ដែលជាប់
ជិតតាមជាមួយខ្លួនទៅក្នុងគេលស្ងាប់ ឯអវៈយវៈដទៃទៀត សុទ្ធតែផល់
ខ្លួវក្តៅនាសអន្តកយជាមួយនឹងសរីរកនិកាយទាំងអស់ ។

៦៨- កាលបើអ្នកនឹងស៊ីសាច់គេ គួរពិចារណាមើល អ្នកស៊ីសាច់
គេ និង សាច់គេដែលអ្នកត្រូវស៊ី ឲ្យឃើញបែកគ្នាទាំងសងខាងសិនថា
អ្នកម្ខាងបានដែន មានប៉ិតរីកយកតែក្នុងមួយខណៈប៉ុណ្ណោះ ឯអ្នកម្ខាង
ទៀតគេត្រូវបាត់បង់ជីវិត ។

៦៩- នរជន តែងមានសេចក្តីទុក្ខព្រួយ ដោយគិតឃើញថា
«ខ្លួនត្រូវគេសម្លាប់» កាលបើគិតឃើញដូច្នេះត្រង់គ្នាហើយ និយាយថ្វី
ដល់ទៅមិត្រ សូម្បីសត្រូវក៏គាចជួយការពារជីវិតបាន ។

៧០- ចុន្តលគប្បីបំពេញផ្លូវខ្លួនឯង ដោយបន្ទូលាក្តាលគាជាតិ

www.budinst.gov.kh www.elibraryofcambodia.org

ដែលជុះក្អែងត្រៃតាមចំនើនវាបាន ហេតុអ្វីកំចាំបាច់តាប់សម្ងាប់គេដឹងក្រក់ក្រៃលែង ដើម្បីចំគេញាំផ្លែខ្លួនដែលគ្រាន់តែស្រែកយ៉ាងប៉ុណ្ណោះ? »

កាលឆ្មា វិឡារជាតិ ន័យយថន្ទន់ចិត្តភ្លាតឮដៀងចិត្តហើយកំសរសៀចូលទៅក្នុងត្រង់ជ្រៃនោះបាន ។ លំជាប់មក ឆ្មាចាប់កូនបក្សីក្នុងត្រង់យកមកហែកជាច្រើនស៊ីជាចំណីអាហារកាល ។ ថ្ងៃ ឯមេបក្សីទាំងឱ្យាយលុះឆ្មាស៊ីកូនអស់ហើយ កំសោកសង្រេងសង្រែយំខ្សឹកខ្ញា រត់ទៅផ្លាទៅខាងនេះទៅខាងនោះ ប្រជុំគ្នាសុំថសួរកងដំណើរដើមទង្គៃការបាត់បង់កូន ។ ឯឆ្មា លុះបានដឹងរឿងនោះហើយ កំបោលចេញតែត្រង់រត់ទៅខាងក្រៅបាត់ភ្លាម ។ ក្រោយដែលឆ្មារត់បាត់ទៅ បក្សីទាំងឱ្យាយចូលគ្នាគយគន់មើលខាងនេះខាងនោះ ប្រទះឃើញកែងកូនទៅក្នុងត្រង់ដើមជ្រៃនោះ កំចោទប្រកាន់គ្នាតថាស់នោះថា : « ភ្នាក់ភ្លាក់កញ្ជាស់នេះឯង ដែលស៊ីកូនថស់យើង » ទើបបក្សីទាំងអស់នោះមូលមតិគ្នា សម្ងាប់ភ្នាតថាស់ចោលថង់សៀតឮដឹកាលនោះទៅ ។ ហេតុនោះបានជាខ្ញុំ(ក្អែកឈ្មោះសត្តុខ្ញុំ) គោលថា : « អ្នកណា ឥមួយ មិនគួរគប្បីឲ្យទីពាស្រ័យទៅរួមគ្នា ជួបប្រជុំជាដើម(๙๑) ។

កាលនោះ ចចកបានស្តាប់ក្អែកនិយាយមកត្រូវតំនិតខ្លួនហើយកំក្រេវក្រោធច្រឡោតខឹង និយាយសិកតថទៅវិញថា : « កាលថងឯង

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

ខ្ញុំដែរប្រើសថាខ្លួនមកជួបប្រទះគ្នាជាបឋមនោះ រូបកន្លែងមិនធ្លាប់ស្គាល់ផ្សែ
ក្រែលួចខ្លួនចិត្តថ្នមថាអ្នកណែវ ហេតុអ្វីក៏ឥតចេះស្នេហាស្រឡាញ់គ្នា
ស្និទ្ធស្នាលរហូតមកកើត ?

៦៩- ទីប៉ាន់ណា មិនមានអ្នកប្រាជ្ញជាជនណ្តិត ទីប៉ាន់នោះសូម្បី
មានតែអ្នកចេះដឹងចន្តិចបន្តួច ក៏នូវលើកដំកើងសរសើរ ជូចជាប្រទេស
ណាន័មួយ ដែលឥតមានត្រីក្បាជាតិ ប៉ើមានតែដើមហ្នុង ក៏លោក
សន្មតថាជាដើមឈើបានដែរ ។

៧០- អ្នកខ្លះជាពួកយើង អ្នកខ្លះជាពួកគេ ខ្លះជាសំដៅអ្នក
មានចិត្តគំនិតស្រាលទេ ឯអ្នកដែលមានគារវៈសិក្សាច្រើន មានចិត្តគំនិត
ល្អតែងនិយាយថា អ្នកខ្លះលើដែនពសុធា សុទ្ធតែជាជៀតឆ្នូតនឹងគ្នា
ពាំនឹងអស់ » ។

ប្រើសខ្លះជាជៀតឆ្នូតប្រហែងខ្លាំងណា ចនឯងក៏ឃាំងនោះដែរ ។
ប្រើសទ្វើយ : « និយាយដដែរកន្លាតគេទៀត ថាខ្លួនប្រយោជន៍អ្វី ។
ចូរយើងពាំនឹងៗនាក់ ខ្លះជាសុខសប្បាយក្នុងទីនេះជាមួយគ្នា ជាមិត្រ
ស្និទ្ធស្នាលគេ ព្រោះថា :

៧១- ខ្លះថាអ្នកណាជាមិត្រអ្នកណាក៏ពុំបានខ្លះ ខ្លះថាអ្នកណា
ជាសត្រូវខ្លួនអ្នកណាក៏ពុំបានខ្លះ ដោយអំពើដែលគេប្រព្រឹត្ត ទើបគេ

www.budinst.gov.kh www.elibraryofcambodia.org

ស្គាល់គ្នា „ អ្នកនេះជាមិត្រ អ្នកនោះជាសត្រូវ „ ។

កែកនិយាយថាក់ចណ្តាយតាមថា : „យាំងនេះកំបាន„ ។ លុះ
ព្រឹកព្រាងស្អាងខ្លឹង សត្វទាំងឆ្ម ចបួលគ្នាទៅស្អងរកចំណីតាហារ
តាមទីហានដែលខ្លួនតាប់ចិត្ត ថ្ងៃមួយ ចចកនិយាយនឹងប្រើសដោយ
សម្ងាត់ថា : „សម្ងាញ់អើយ ! ទៅក្នុងព្រៃមួយនោះមានស្រែមួយគេញ
ដោយសន្ធឹងលាស់ទៀវទ្ធឹ រួចខ្ញុំនឹងនាំសម្ងាញ់កក្តើទៅចង្ហាញសន្ធឹងក្នុង
ស្រែនោះ „ លុះចចកចង្ហាញស្រែនោះហើយ ប្រើសទៅរកស៊ីសន្ធឹង
ក្នុងស្រែនោះតែរាល់ថ្ងៃ ។ កាលនោះអ្នកស្រែបានឃើញប្រើស ចេះតែ
ចូលទៅស៊ីសន្ធឹងក្នុងស្រែខ្លួន កំនាន់គ្នាញ់មួមៅក្នុងចិត្តណាស់ ទើបធ្វើ
អន្ទាក់ជាក់ប្រើសនោះ ។ អមកមិនយូរប៉ុន្មានប្រើសមកស៊ីសន្ធឹងក្នុងស្រែ
នោះទៀតត្រូវអន្ទាក់ជាប់រើខ្លួនមិនរួច ទើបគ្រិះរិះគិតថា : „ស្រីតាមិត្រ ,
នរណាហ្ន៎ គាចជួយដោះទុក្ខគាត្មាអញចេញពីអន្ទាក់ព្រាន ដែលទុកដូច
ជាអន្ទាក់នៃព្រះកាល(•) នេះបាន ? កាលប្រើសកំពុងរិតក្តូរនេះ ចចក
ដើរមកដល់ជិត ឮដឹងសព្វាយក្នុងចិត្តថា : „ ឱបាយកាលចេះសំគាត្មាអញ
បានសម្រេចផលតាមចំណង់ហើយតើ ! កាលចើអ្នកស្រែគន្លះប្រើសនេះ
គាត្មាអញត្រូវបានឆ្អែង ដែលជាប់ដោយសាចំនឹងឈាមដោយពិតឥត

•-មើលន័យលក្ខណៈលេខ ១ ទំព័រ ៤៥ ។

www.budinst.gov.kh www.elibraryofcambodia.org

សង្ឃយេវេយ្យ អាត្មាអញនឹងបានកោដនាហារឆ្ងាញ់ពិសាយ៉ាងច្រើន ថវិកោតមិនខាន » ។ ឯច្រើស លុះឃើញចចកមកដល់ហើយក្រោកឈរឡើងសប្បាយចិត្តឥតឧបមា ស្រែកច្រាប់ថា: « តើសម្លាញ់តើយ ! ចូរសម្លាញ់គាណិតកាត់អន្ទាក់នេះធាប់ ។ ដើម្បីឲ្យខ្ញុំបានរួចខ្លួន ព្រោះថា:

៧២- គេដឹងចិត្តមិត្រក្នុងគ្រាក្រ, ដឹងចិត្តគាហានក្លៀវក្លាក្នុងសង្គ្រាម ដឹងចិត្តស្មោះត្រង់ក្នុងការសនឹងចំណុលគេ , ដឹងចិត្តអរិយា ក្នុងពេលខ្វះខ្វាត់ទ្រព្យ និងដឹងចិត្តផៅពន្ធុក្នុងគ្រាវិនាសអន្តរាយ ។

៧៣- អ្នកណាមិនលះបង់មិត្រ ក្នុងគ្រាខានខ្វះ ក្នុងគ្រាអន្តរាយ ក្នុងគ្រាខុរភ័ក្ស ក្នុងគ្រាភស្តុតលាតល ក្នុងទ្វារព្រះរាជា និងក្នុងអង្គព្រៃស្មសាន , អ្នកនោះលោកហៅថាផៅពន្ធុ » ។

ចចកសម្លឹងមើលអន្ទាក់ មើលហើយមើលទៀតច្រើនដងឃើញថាអន្ទាក់នេះជាប់មាំមួនណាស់ ទើបនិយាយថា : សម្លាញ់តើយ ! អន្ទាក់នេះធ្វើពីសរសៃសត្វ ថ្ងៃនេះជាភត្តាវកាវ(*) ខ្ញុំយកធ្មេញទៅទ្បាប់ពាល់អន្ទាក់សរសៃសត្វដូចម្តេចកើត ? ល្អើយសម្លាញ់ ! ទំអត់ទ្រាំចន្តិចទៅសិនចុះ ថាបើចិត្តចង់មិនមានតិតអ្វីដទៃផ្សេងទេ ចាំព្រឹកព្រាននៅស្អែកឡើង, ពេលនោះ បើចង់ច្រាប់ឲ្យធ្វើយ៉ាំងណា ខ្ញុំនឹងធ្វើតាមចិត្តចង់មិន

---

*. ថ្ងៃព្រះជាម្ចាស់សូត៌ គឺថ្ងៃអាទិត្យគេកាន់សីលតមមិនធ្វើបាប មិនពាល់សាច់ ។

www.budinst.gov.kh www.elibraryofcambodia.org

ភាន» ។ ចចកថាដូច្នោះហើយ ចូលទៅលាក់ខ្លួនក្នុងអាត្មា សម្ងំក្នុងព្រៃស៊ុមព្រូមដដែរនោះទៅ ។ ថ្ងៃនឹងក្អែក លុះវេលារសៀលជ្រឿងជ្រេរចេរចន់តាមព្រៃចំនួន ក្រឃើញប្រើសវិលត្រឡប់មកលំនៅវិញ ក៏ហើរទៅតាមរកទាំងនេះទាំងនោះ រកទៅ។ បានឃើញប្រើសមានគ្រោះជាប់អន្ទាក់ទើបសួរទៅថា : ម៎ៃសម្លាញ់ ! ហេតុអ្វីក៏ជាប់អន្ទាក់ធ្ងាក់ក្នុងដូច្នេះ ? » ប្រើសបានស្តាប់ពាក្យក្អែកហើយ ទ្រើយត្រាប់ថា "អំពើនេះ ជាផលនៃការមើលងាយពាក្យសំដីមិត្រនេះឯង ព្រោះថា :

๗๒- នរជនណា មិនជឿស្តាប់តាសិតមិត្រសម្លាញ់ដែលត្រាប្ញ ទ្រើយប្រយោជន៍ខ្លួន ក្តីភយន្តរាយបឹងនៅជិតអ្នកនោះ នរជននោះ ឈ្មោះថាធ្វើសេចក្តីត្រេកអរដល់សត្រូវ ។

ក្អែកសួរប្រើសថា: «ចុះគាចចកចង្រៃចោកត្រាស់នេះនោះ វាទៅនៅឯណាហើយ ? » ។ ប្រើសត្រាប់ថា: «វាទៅតួនសម្ងំនៅក្នុងព្រៃស៊ុមព្រូមនោះឯង ដើម្បីចាំស៊ុសាច់ខ្ញុំ» ។ ក្អែកនិយាយសើរើរឿងដើមមកគោលថា: «អើ ! ដូចខ្ញុំបានដាស់តឿនចង់តាំងតាំងពីដើមមកហើយ ។

๗๓- ម៉្លោមានអ្នកណាខ្លះមួយនិយាយថា "ខ្ញុំមិនមានចិត្តគាក្រក់ល្បាបាទទេ ដូច្នេះក៏ដោយ បុគ្គលមិនគួរជឿតាក្យនេះ យកជាហេតុមេត្រីស្និទ្ធស្នាលឡើយ សេចក្តីពិត អ្នកដែលមានគុណគឺការចេះដឹង

www.budinst.gov.kh www.elibraryofcambodia.org

ហិរោចទេស

ច្រើន កំពែងមានន័យកើតមកពីមនុស្សខ្ចប់តែតាំងឡាយដែរ ។

៧៦- មនុស្សស្លាប់ មិនធុំក្លិនផ្សែងចង្កៀងដែលគេលត់ ស្តាប់មិនឮពាក្យដាស់តឿនមិត្រសម្លាញ់ មើលឃើញថ្ពាយអវុន្ទតី(១) ។

៧៧- បុគ្គលឆ្លៀវឆ្លៀរមិត្រ ដែលចំណង់ចំផ្ងាញការងារក្នុងទីកំពាំងនមុខ ហើយនិយាយពាក្យតិះដៀលស្លឹមក្នុងទីចំពោះមុខ មិត្រយ៉ាងនេះត្រូវជួចថ្នាំងជីតេញដោយឫតិសពុល មានមាត់ច្រឡាក់ដោយទឹកដោះផ្អែម» ។

ខណៈនោះ ក្អែកតានតឹងចិត្តស្ទើរប្រេះប្រេង ដកដង្ហើមវែងឃួរៗនិយាយថា : ..ខុនាចនៃរបាកច្រាសនេះ! ម្តេចកំសាងឯងហ៊ានធ្វើកម្មការក្រក់អ៊ីម្លេះ ? គ្រោះថា ៖

៧៨- ក្នុងលោកនេះ បើគេនិយាយឲ្យស្លាប់ចិត្ត ដោយប្រើពាក្យផ្អែមល្អែមជូចទឹកឃ្មុំ បើគេធ្វើឲ្យសុះក្នុងអំណាច ដោយៗបាយមិញ្ចាចារគេមិនបញ្ឆោតបោកបាន ? ខុនួរសង្វែងណាស់ ! ។

៧៩- ខុព្រះខ្លាស់ដែនតសុជា ជំមានបុណ្យអើយ ! ហេតុអ៊ីក៏លោកព្រមទទួលមនុស្សប្រាកតេ ចិត្តបាបការក្រក់ក្រៃលែង មិនដឹងខុបការគុណគេ ដែលគេប្រែរលំជំនឿ តែគេជឿខុកចិត្តអស់ពីពោះពុង

• ផ្តាយព្រឹក ។

www.budinst.gov.kh www.elibraryofcambodia.org

. ការគប់មិត្រ

ឥឡូវដែលគេមានចិត្តចរិសុទ្ធ ឲ្យគេសើរលើផ្លូវដែនដីនេះដូចេ្នះ ។

៨០- ឫគ្គលកុំគប្បីចងមិត្រស្មម្ញាញ់ ឬ ចងស្ពានមេត្រីមួយភនឡើង ដោយមនុស្សទុជ្ជនឲ្យសោះ ដូចជាឆ្នូង បើគេឡើងលាកដៃ ចើលត់ហើយ រាប្រឡាក់ដៃ ។

ពាក្យចាំងនេះ ជាលក្ខណៈនៃមនុស្សទុជ្ជន ។

៨១-គេមុខអ្នក រាសំតះលុតក្រាបជិតជាន់ជើង គេក្រោយអ្នករាចេះសាច់ឆ្អឹងជំនីរស៊ី រាឱយយសជើខន់ផ្តួមល្អុកល្អិន មានលែចមាយជីរចែត្រ ល្អីមារ ជិតក្រចៀកអ្នក ចើមានចង្រៃ លួចចូលគេចេះយកថ្នើមប្រមាត់មួយរំពេច ឥតគោតញាញើតឡើយ , សត្វរុយរាចេះធ្វើត្រាប់លក្ខណៈមនុស្សចិត្តគាក្រក់សាមាន្យបានចាំងអស់ ។

៨២- មនុស្សទុជ្ជន ឱយយតាក្យតិកេះគួរជាទីពេញចិត្ត តែមិនត្រូវយកជាហេតុមកធ្វើសេចក្តីស្និទ្ធស្នាល ព្រោះតែសំដីតិកេះនោះរេចរ្រៃដូចចំកយ៉ាប់នៅពុងអណ្តាត ក្នុងចិត្តពេញដោយតិសតុលជំពុលក្រហាយភេលកល ។

លុះព្រឹកព្រាងស្ងាងឡើង កែអ្នកសុតុទ្ធខោះ ឃើញអ្នកស្រែកាន់ដំបងដងាសដើរមកដល់ ទើបស្រែកសើរច្រើសថា : " អើបងប្រើសសម្លាញ់អើយ ! អ្នកស្រែមកដល់ហើយ ចូរបងដេកតុកកែងជាស្ងាប់សៅ

www.budinst.gov.kh www.elibraryofcambodia.org

ហ៊ានពោលទេស

ធ្វើភ្នែកស្ងឹង បំប៉ោងគោះឡែង ដើងឡើងស្ពក ហើយនៅឡៃស្រឡឹមនឹង
ថ្ពល់ ។ ដកថណាខ្ញុំស្រែកប្រាប់ឡៃសញ្ញា ដកថនោះចូរបងគ្រោកភ្លាម
យ៉ាងរហ័ស ហើយស្ទុះរត់ចោលឡៃអស់ចំហឹង ។ ឯប្រើស លុះបាន
ស្តាប់ពាក្យភ្នែកហើយ ក៏ពុតភ្នែងធ្វើជាស្ងាប់ដូចសំដីភ្នែកប្រាប់ នៅនឹង
ថ្ពល់ ។ ថ្លែងឯអ្នកស្រែ ដើរមកដល់ យល់ប្រើសជាប់អន្ទាក់ស្ងាប់ក្រៃ
ញាន់ដូច្នេះចើកភ្នែកក្រេឡាតង់។ រីករយសប្បាយចិត្តណាស់ លាន់មាត់
ថា : «អេះបៃអាគាយហោង អាឯងស្ងាប់ខ្លួនឯងហើយតើ ! ... ពោល
ដូច្នេះហើយក៏ស្រាយអន្ទាក់ចេញពីប្រើស ដោះរួចស្រេច ក្មេចខ្លួនអា
ល័យតែរៀបចំអន្ទាក់ ស្រាប់តែភ្នែកស្រែកឡៃសញ្ញាភ្លក ។ ប្រើសក៏គ្រោក
ឡើងស្ទុះចោលរត់ប្រិចដូចគេចុះពួយលឿនស្ទាស់ដៅព្រៃប្រាក ឯ
អ្នកស្រែស្រឡាំងកាំង ក៏ស្ទុះលេះលាំង ទៅចាប់បានដំបងត្រែវែងចោល
ប្រើសសំដៅទៅប្រើសនោះភ្លាម ហេតុតែកម្មតាមទាន តានទៅត្រូវខួចក
ខោក ដួលស្ងាប់ហ៊ានហោចទៅហោង ។ ហេតុនេះឯង បានជាលោក
ពោលទុកថា :

៥៣-បុណ្យជាមជ្ឈិមសប្បុគ្គលធ្វើទុកក្នុងលោកនេះ មានកម្លាំងថ្លែក
ចម្លែកអស្ចារ្យណាស់ តែងឡៃផលតបស្នងវិញយ៉ាងយូរ ៣ ឆ្នាំឬក៏ ៣ វស្សា
ពុំនោះ ៧ កប្ប ទើពុំនោះត្រឹម ៧ ថ្ងៃ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះហេតុនោះបានជាខ្ញុំ (កណ្តុរហិរណ្យកៈ) និយាយជាភាសិត ពុទ្ធាធិដ្ឋាន៍ដើម្បីថា : „ការចងគ្នាជាមិត្រវៃឯអ្នកស៊ីនឹងអ្នកត្រូវនេះស៊ុ „ ដូច្នេះ ជាដើម (៥៥) ។

រីឯកណ្តុរឈ្មោះលឃុបតនកៈ ទ្តើយទៀតថា ៖

៨៤- ទុសម្ចាញ់ជាអ្នកនិពុទ្ធជួបស្តេចព្រាហមចិត្តត្រឹត ចើខ្ញុំស៊ីបងជាអាហារ ខ្លួនបងកូចម្ល៉ះមិនស្កប់ផ្តៃខ្ញុំទេ កាលបើបងរស់នៅ ខ្ញុំក៏ឈ្មោះថារស់នៅដែរ ។

៨៥- ទោះបើសត្វកំរបាន ដែលប្រព្រឹត្តល្អតែមក្តាំង រៀស្បាសៈស្ងួនស្ងាស តាបទ្តើយទេនេះយើញជាក់ស្តែងបាន ដូចសភាតលោកសប្បុរសពាំងនឹងយ ឥតឋាវិលត្រឡប់ទៅផ្សេង កំឥតអង្គឹមាន ព្រោះលោកមានសភាពជាសប្បុរសជាប្រក្រតី ។

៨៦- សន្ធានចិត្តលោកសប្បុរសពាំងនឹងយ សូម្បីមានសេចក្តីក្រៃក្រោធកើតទ្បើង ក៏មិនប្រែប្រួលឥតបញ្ឈប់រៀយ ដូចជាគេមិនអាចយកគុបស្មៅមួយគុប ទៅដុតកំដៅទឹកសមុទ្រសោះឡើយក្តៅពុះតោះបានទ្បើយ ។

កណ្តុរឈ្មោះហិរណ្យកៈបានស្តាប់ហើយ ក៏និយាយទៅវិញថា: „ បងឯងនេះជាសត្វចិត្តថ្លុលថ្លើចទៀលខ្លួចណាស់ បុគ្គលមិនគប្បីចងជាមិត្រស្និទ្ធស្នេហាជាមួយនឹងសត្វថ្លុលថ្លើចដូច្នេះទេ ព្រោះថា :

www.budinst.gov.kh www.elibraryofcambodia.org

ហិរោបទេស

๘๗- ម្នា ๑ ក្រមា ๑ ចៀម ๑ ក្អែក ๑ ឱដ្ឋមនុស្សចំពួកអាក្រក់ ๑ ពាំង ๕ ពួកនេះ ចាត់សេចក្តីចំរើនវុឌ្ឍរឿង ព្រោះអាងស្មៀតរៃ៉ំរៃអប ធ្វើវិស្សាសៈស្និទ្ធស្នាល ព្រោះហេតុនោះ បុគ្គលមិនគួរគប្បីប្រគល់ឲ្យនូវវិស្សាសៈស្និទ្ធស្នាលចំពោះបុគ្គលពាំង ๕ ពួកនោះឡើយ ។ ๗

មួយទៀត ខ្ញុំនឹងជាសក្ខីពួកទាំងសត្រូវនឹងយើង៨ឆ ព្រោះថា :

๘๘- ចើជាសត្រូវហើយ បុគ្គលកុំគប្បីចងមេត្រីជឿទុកចិត្តយ៉ាងជិតស្និទ្ធឡើយសោះ ដូចជាខ្ញុំក ខុកជាពុះភ្ជាំងតគ្រឹកឱកាចលត់ក្តៅងជាន

๘๔- រមនុស្សខ្ញុំជន សូមគ្បីប្រជាប់ខ្ញុំនដោយគ្រឿងអម្ពរតិចំណោះវិជ្ជា កំបុគ្គលគប្បីចៀសវាងចេញឲ្យផុត ដូចសក្ខីតាសិរតិស សូមគ្បីប្រជាប់ដោយកែវមណី វាន៏ងមិនធ្វើឲ្យយើងមានភ័យឬអ្វី ?

๘๐- ចេស់ណាមិនគាច ចេស់នោះទៅតែមិនគាចពិតប្រាកដ ចេស់ណាគាច ចេស់នោះទៅតែគាចពិតប្រាកដ ដូចជារេះបរទៅលើពិកមិនបាន ឯពួក អ៊ុំលើនោក កំទៅមិនបានដូច្នេះដែរ ។

๘๑- នរជនណាទៅចងចិត្តស្និទ្ធស្នាលនឹងសត្រូវ ឬនឹងភរិយាដែលមិនមានចិត្តប្រតិព័ទ្ធខ្ជួន ដោយគាងថាមានទ្រព្យសម្បត្តិច្រើន ជីវិតនរជននោះ ឈ្មោះថាចូលទៅដល់ទីបំផុតទៃត្រកើមនោះហើយ ។

វិញ្ញូកពោលតបទៅវិញថា : « ខ្ញុំបាទស្តាប់សំដីបងនិយាយសក្ខីត្រង់

www.budinst.gov.kh www.elibraryofcambodia.org

អស់ប៉ុណ្ណឹងហើយ កំដូចជាយើញថាបងមិនត្រមត្រែងសោះ តែគោះជាយ៉ាងណា កំខ្ញុំបានតាំងចិត្តទុកជាមុនរួចហើយ ថានំនឹយកបងធ្វើជាមិត្រស្និទ្ធស្នេហាតាត្រកាកដតស្ងប់រ្យែយខ្លួយ ថាបើមិនដូច្នោះទេរូបខ្ញុំនឹងអត់អាហារ ចោកខ្ជូនសម្លាប់ខ្លួនមាត់ត្រង់បង ឲ្យស្លាប់ចោលបង់សឿតទៅល្អជាង ព្រោះថា ៖

៤៦-មនុស្សទុំជិនចិត្តអាក្រក់សាមាន្យ ប្រៀបដូចឆ្នាំងដីថែកបាក់ប្រេះធាតិចប៉ះហ៊ីសណាស់ ជល់តវិញមិនជាប់ទេ ឯលោកសាធុជនចិត្តសប្បុរស ប្រៀបដូចឆ្នាំងមាស មិនដាយបាក់ថែកប្រេះធាទេ ជល់ផ្សារស្លាប់វិញ តិដាយជាប់ ។

៤៧-ជាតំលោហធាតុទាំងអស់ លោយចូលគ្នាបាន ព្រោះដែកមានការលោយជាលក្ខណៈ ប្រឹតបក្សីទាំងឡាយរួបរួមចូលជាហ្វូងបាន ព្រោះមានរួបកងិសណ្ឋានជាលក្ខណៈ មនុស្សល្ងង់ រួបរួមគ្នាបានព្រោះមានភ័យនឹងលោកជាលក្ខណៈ, ឯសាធុជនមានមហាគ្នុន រួបរួមចូលគ្នាបាន ដោយទស្សនាញាណ (ស្គាល់ហេតុស្គាល់ផល) ។

៤៨-មែនពិត សាធុជនចិត្តល្អ គេមើលទៅឃើញមានតាការដូចផ្ទៃជូង ឯអ្នកដទៃទៀត គេមើលទៅឃើញដូចឆ្កែពុត្រា មានសំបកគ្រៀវលោនស្រែលគួរជាទីគេញចិត្ត

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

๔๘- ខ្សែមេត្រីចិត្តនៃលោកសប្បុរសទាំងឡាយ សូម្បីមានរួចស័ង្គ
អ្វីមកផ្តាច់ពីក្តីស្នេហាគ្នា តុណាប្រសើរមិនថ្លាស់ប្តូរប្រែប្រួលទេ ដូចដើម
ឈូក សូម្បីចាក់ពាក់កណ្តាល ក៏នៅតែមានជាប់សរសៃអន្លាយដែរ ។

๔๙-ភាពជាបុគ្គលមានចិត្តបរិសុទ្ធ ភាពជាបុគ្គលមានចិត្តចង់ឲ្យទាន
ភាពជាបុគ្គលមានចិត្តអធ់អាច ភាពជាបុគ្គលមានចិត្តស្មើកន្ត្រាស់ទុក្ខ
ភាពជាបុគ្គលមានចិត្តមេត្តាករុណា ភាពជាបុគ្គលមានចិត្តស្រឡាញ់កប់
អាន ភាពជាបុគ្គលមានចិត្តខឿងត្រង់ទាំងអស់នេះជាគុណសម្បត្តិនៃមិត្រ។
ខ្ញុំនឹងសៀវភៅមិត្រសម្លាញ់ឲ្យប្រកបដោយគុណសម្បត្តិដូច្នេះ ត្រៃ
ត្រូវបង្ហាញឯណាបាន ? » ។ កណ្តុរហិរណ្យកៈ លុះបានឮពាក្យកែកុក
លឃុបតនកៈពោលដូច្នេះហើយ ក៏ចេញពីត្រង់មកទាំងត្រៃ និយាយ
តបថា : « ខ្ញុំមានចិត្តត្រេកអរចំពោះសំដីបងណាស់ ដូចជាបានក្រេប
ផឹកទឹកអម្រឹត ត្រោះថា ៖

๔๗- កិរិយាមុជទឹកថ្លាត្រជាក់ត្រជុំក្តី , កិរិយាប្រកបដោយខ្សែក
ជាំហើយដោយកែវមុក្តាក្តី កិរិយាប្រោះព្រំតែរួតសាន្តកាយ ដោយទឹម
ចន្ទន៍ក្តី ទីឯថាមិនធ្វើបុគ្គលដែលក្តៅស្មុះស្មាច់ដោយកំដៅឲ្យត្រជាក់ស្រួល
ក៏មិនមែន តែមិនប្រសើរជាងសុភាសិតនៃលោកសប្បុរសទាំងឡាយ
ដែលអាចបួលទៅចំរោលដល់ចិត្តត្រជាក់មុនដោយបីតិជ្រះថ្លា ជាំក្រៃលែង

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្រ

ព្រោះលោកខុសគាស់តជាត្រឹមខ្លះ ខុសដូចជាមន្តស្រាប់ស្រួចចិត្តលោក សប្បុរសទាំងឡាយ ។

๙๘- ភិរយោទម្ហាយគាថាកំចាំងក្តី ល្មោភសមក្តី គាតជាបុគ្គលមានចិត្តរឹងរូសក្តី គាតជាបុគ្គលមានចិត្តរប៉ិលរប៉ូចក្តី សេចក្តីក្រោធច្រើនក្តី គាតជាបុគ្គលមិនមានសច្ចៈក្តី ស្រេរឹងឈ្លក់ក្នុលែស្នងក្តី ទាំងអស់នេះជាគ្រឿងប្រទូស្តនៃមិត្រ ។

តាមពាក្យសំដីដែលបងបានឱយាយមកទាំងអស់នេះរូបខ្ញុំមិនឃើញមានគោលជាគ្រឿងប្រទូស្តអ្វី សូម្បីតែមួយក៏អតអង្គើមាន ព្រោះថា ៖

๙๙- បុគ្គលតប្បីសង្កេតជាង ខ្លួកាតនៃបុគ្គលមានចិត្តអាក្រក់ និងកាតនៃបុគ្គលពោលពាក្យសច្ចៈ ដោយទឹកប្រយោតសំដី, បុគ្គលតប្បីមើលឃើញខ្លួកាតនៃបុគ្គលមានចិត្តមិនទៀងទាត់ និងកាតនៃបុគ្គលមានចិត្តមិនរប៉ិលរប៉ូច ដោយឃើញច្រចក្សុនឹងភ្នែក ។

๑๐๐- មែនពិត, មេក្រមចិត្តនៃបុគ្គលមានចិត្តចរិសុទ្ធ មានសភាតម្យ៉ាង ឯសំដីនៃបុគ្គលមានចិត្តអាក្រក់ទិលខូច មានសភាតម្យ៉ាងទៀត ។

๑๐๑- មនុស្សចិត្តអាក្រក់ ចិត្តគិតផ្សេង, សំដីនិយាយផ្សេងទៀត, កិរយាប្រព្រឹត្តធ្វើផ្សេងទៀត, ឯបុគ្គលមានមហាគ្គុន ចិត្តគិត សំដីនិយាយប្រព្រឹត្តធ្វើតែមួយ ។

www.budinst.gov.kh www.elibraryofcambodia.org

ហ៊ានោចទេស

ច្រៃតេហ៊ីយ ! ច្រៃតេហ៊ីយ ! សូមឲ្យបងបានសម្រេចតាមច្រកថ្នាកុំបីឃ្លាត , លុះនិយាយដូច្នោះហ៊ីយ កណ្តុរហ៊ានល្បាកៈត្រមត្រៀងចងស្ពានមេក្រែកចំគានជាមួយនឹងក្អែកលឃុបតនកៈ រឿងចំកោជនាហារ ដីតសេសឲ្យក្អែកចរកោតស្កប់ស្កល់ ហើយក៏លាចូលទៅកាន់ត្រង់បេះខ្លួនដូចច្រក្រតីដើមវិញ ឯក្អែកក៏លាត្រឡប់ទៅកាន់លំនៅខ្លួនវិញហោង ។ ចាប់ដើមតាំងតាំថ្ងៃនោះរៀងមក ក្អែកលឃុបតនកៈតែងហើរទៅជួបសន្ទនាដាំរីករាយសប្បាយជាមួយកណ្តុរហ៊ានល្បាកៈ រីឯកគាហារគ្នាចរកោតតាមមានតាមបាន សួរសុខទុក្ខទៅវិញទៅមកជ្រួតម្ដងៗសាកច្បាសាកសួរគ្នាតាំនតំលោកនតំធម៌រឿយ ។ ដោយសេចក្តីស្និទ្ធស្នាលជាក្រៃលែងអស់កាលយូរអង្វែង ។

ថ្ងៃមួយ ក្អែកលឃុបតនកៈនិយាយប្រាក្សាជាមួយកណ្តុរហ៊ានល្បាកៈថា: «ហៃសម្លាញ់ ! ខ្ញុំនេះសត្វក្អែកតែបាកគេចំណីគាហារចិញ្ចឹមជីវិតណាស់ ខ្ញុំតែងថាលះចង់ទីហានេះ ហើយនឹងហើរទៅស្វែងរកទីហានឯទៀត ដែលងាយរកចំណីគាហារចរកោតចិញ្ចឹមជីវិតជាងទីនេះ » ។ កណ្តុរហ៊ានល្បាកៈស្តាប់តាក្យក្អែកហ៊ីយ មានចិត្តថ្នាម្ត ទើបសួរទៅថា «នែសម្លាញ់ ! សម្លាញ់តែងទៅទីហានឯណាវិញ ? ព្រោះថា :

www.budinst.gov.kh www.elibraryofcambodia.org

ការតប់ម៉ត្រ

๑๐๒- (๑)អ្នកមានទ្រព្យ កាលដែលលើកដើងគ្រោយ លុះគ្រាតែដើងមុខជាន់ស៊ុបហើយគឺថា កេទីហានឯទៀតបានហើយ ទើបលះបង់ទីហានចាស់ចោលបាន ។

ក្នុងក្រាប់ថា ទីហានដែលខ្ញុំបានតាំងមើលឃើញថាល្អនោះ មានមួយកន្លែង ។ កណ្តុរហិរណ្យកៈសួរទៅវិញថា : « ចុះទីហាននោះនៅឯណា ? » ។ ក្អែកក្រាប់ថា : « មានស្រះមួយទីកថ្លាយល់ដីឈ្មោះកច្ចបនោះ (๒) ជិតនៅកងវាលទេណុក ; មានអណ្តើកមួយឈ្មោះមន្ថរៈជាមិត្រសម្លាញ់ខ្ញុំចិត្តថ្នើមល្អណាស់ អាស្រ័យនៅក្នុងស្រះនោះ ព្រោះថា៖

๑๐๓ - ការគ្រាន់តែប្រដេរដៀនដេនតាំងឡាយដទៃ ឲ្យតែបានជាបណ្តើត នរណាក៏ធ្វើបានដែរ តែការខ្ជាន់ខ្ជួនឯងឲ្យប្រព្រឹត្តទៅតាមនូវឯធម៌ជាការក្រៃ ធ្វើបានចំពោះតែបុគ្គលមានមហាភ័ន ។

អណ្តើកមន្ថរៈជាសម្លាញ់ខ្ញុំ មុនជាធ្វើថដាសណ្ឋានៈខ្លួនដោយគ្រឿងកោដនាហារដ៏ឆ្ងាញ់ពិសារក្រៃលែង » ។ កណ្តុរហិរណ្យកនិយាយតបទៅវិញថា : « បើដូច្នោះមែន រូបខ្ញុំនឹងក្រាញទៅកងទីនេះ តែម្នាក់ឯងធ្វើអ្វី ព្រោះថា ៖

---

๑. ហិតោបទេសសេចក្តីប្រែជាភាសាថាវាំងរបស់លោកឡង់សឺរ្ទមានន័យថាផ្សេងមួយទៀត គឺ: ឆ្មេញ, សក់, ក្រែចក និងមនុស្សបើដាស់ទីកន្លែងថ្មី ក្រៅពីកន្លែងដើម មិនល្អទេ អ្នកមានប្រាជ្ញារិះគិតឲ្យជ្រាលជ្រៅហើយ មិនគួរលះបង់ចោលទីហានឡើយ ។ ๒ មានពណ៌ខ្មៅពន់ប៉ុន។

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

១០៦- ប្រទេសឯណា មិនមានភេកប់គាន មិនមានផ្លូវកេស៊ុ
ចញ្ចឹមជីវិត មិនមានញាតិសន្ដានផៅពង្ស ឬ ក៏មិនមានវិញ្ញូជនមចំរើន
ចំណេះវិជ្ជា បុគ្គលគប្បីលះចង់ប្រទេសនោះចេញ ។

១០៧- លោកយាត្រា (ការលក់ដូរ) ១ សេចក្ដីភ័យ ១ អាជ័ីវ
មុខ ១ មេត្ដាករុណា ១ ការបរិច្ចាគទាន ១ ទីហានណា មិនមានធម៌ប្រការ
នេះទេ បុគ្គលមិនគប្បីតាំងទីហានអាស្រ័យនៅ នៅក្នុងទីនោះឡើយ ។

១០៨- មនុស្សសេងបំណុលគេ ត្រូវពួក១ សមណព្រាហ្មណ៍
ចេះដឹងវេទ ១ ខ្លួនមានទឹកថ្នាំចរិសុទ្ធ ១ នៃសម្លាញ់! ទីហានណាមិនមាន
វត្ថុ ៤ ប្រការនេះទេ បុគ្គលមិនគប្បីតាំងលំនៅ ក្នុងទីហាននោះឡើយ ។

កណ្ដុរហិរណ្យកៈនិយាយថា «សម្លាញ់អើយ ! បងចូរនាំគ្នា
ទៅជាមួយផង» ។ កែកនាំកណ្ដុរហិរណ្យកៈទៅ កាលចរណ្ដើរគ្នាទៅ
និយាយសន្ទនាគ្នាជាទីរីករាយ សប្បាយក្សេមក្សាន្តតាមដំណើរផ្លូវរៀង
ទៅគ្រាកែផល់ស្រះនោះ ។ ឯអណ្ដើកមន្ថរៈ កាលឃើញសត្វទាំងពីរ
ចរណ្ដើរគ្នាគ្រសង តាំងពីចម្ងាយមក រីករាយសប្បាយចិត្តណាស់ ក្នុ
ចដឹងសណ្ដាប់ ដឹងធ្ងន់ឮស់ តាមដែលបានតិតពុកមុន ១ ខ្លួលក្អែកត្រមាំង
កណ្ដុរហិរណ្យកៈជាភ្លៀវថ្មីដោយសក្ការៈកច៏ាគនដ៏ក្រៃលែង, ព្រោះថា:

១០៩- ទោះក្មេងក្ដី ឬ កម្លោះក្រមុំក្ដី ទោះចាស់ព្រឹទ្ធាចារ្យក៏ដោយ

www.budinst.gov.kh www.elibraryofcambodia.org

ដែលជាកូវមកដល់ផ្ទះហើយ បុគ្គលគប្បីរៀបចំគ្រឿងសក្ការៈចាប់អាននដល់ជននោះ ។ ព្រោះអ្នកចាំងនោះមកដល់ផ្ទះហើយ លោកខុកជាត្រូវចាំងអស់ ។

១០៨- ព្រះអគ្គិជាត្រូវនៃព្រាហ្មណ៍ចាំងឡាយ ព្រាហ្មណ៍ជាត្រូវនៃជនវណ្ណៈឯទៀត ប្តីជាត្រូវនៃភរិយាចាំងឡាយ ឯកូវដែលមកដល់ផ្ទះជាត្រូវជនចាំងអស់ ។

ទណៈនោះ ក្អែកលឃុបតនកៈនិយាយទៀងថា: ។ ម្នាលថងសំឡាញ់មន្ទរៈ សូមសម្លាញ់រៀបចំខួលកូវថ្មីនេះឲ្យជាពិសេស ព្រោះថាកូវថ្មីនេះ ជាស្តេចកណ្តារវណ្ណៈហ៊ានណាស់ ជាកំពូលនៃអ្នកប្រព្រឹត្តធ្វើបុណ្យទានចាំងឡាយ ជាកែវមុត្តានៃមនុស្សមានមេត្តាករុណាចាំងឡាយ បើខុកជាស្តេចនាគមានដ៏ឫទ្ធិ៦០០០ ខ្ញុំក៏ជឿថាមិនអាចនឹងគោលការសើរតិកិត្តិនុណាស្តេចកណ្តារនេះឲ្យអស់បានទេរ្យ" លុះក្អែកនិយាយដូច្នោះហើយ កំណាងរឿងស្តេចត្រាចចិត្តត្រឡប់មកថ្វាយថ្ងៃត្រាប់ទៀត ។ អណ្តើកមន្ទរៈបានស្តាប់ពាក្យក្អែកហើយ កំមានចិត្តសាទរវត្តុបមា ទើបនោរពថ្វាយកណ្តារហ៊ានណាស់ដ៏ក្រៃលែង ហើយពោលពាក្យប្រស្រ័យថា: "នែសំឡាញ់ដ៏ចំរើនអើយ ! សូមបងមេត្តាត្រាប់ហោតុដែលខ្ញុំមកកាន់ទីឋាននេះជនស្លាត់ដូច្នេះឲ្យខ្ញុំបានជឿនផង ! " ។ កណ្តារហ៊ានណាស់និយាយត្រាប់ថា: "សូមចាំស្តាប់ ខ្ញុំនឹងពណ៌នាតប្រព្រឹត្តហោតុឲ្យស្តាប់ដូចតទៅនេះ" ។

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

កថាទី ៤

រឿងកណ្តុរហិរណ្យកៈ

នៅក្នុងនគរចម្បកៈមានពួកបរិព្វាជកអាស្រ័យនៅច្រើន ។ បណ្តាបរិព្វាជកទាំងឡាយនោះ មានបរិព្វាជកម្នាក់ឈ្មោះបូរាណកណ៌ៈ តាំងទីហើនអាស្រ័យនៅក្នុងទីមួយ ។ គាត់តែងជាក់គោជនាហារសេសសល់ពីកិរិយាបរិភោគក្នុងចង្ក្រមួយ ហើយយកទៅញ្ជរទុកឲ្យជាំដៃតែវជាប្រក្រតីរួចសម្លុះផកលក់ទៅ ។ ខ្ញុំ (ហិរណ្យកៈ) លោតទៅលួចយកគាហារគោជនានោះមកបរិភោគជានិច្ចកាល ។ ថៃ្ង ។ គេលមួយនោះ! បរិព្វាជកម្នាក់ទៀតឈ្មោះវិណាកណ៌ៈ ជាមិត្រសម្លាញ់ភ្ជាប់ពាក់ព័ន្ធគ្នា ចូលមករកជួបបរិព្វាជកបូរាណកណ៌ៈនោះ ។ បរិព្វាជកទាំងពីរនេះយាយជជែកគ្នាសើចកំសាន្តសប្បាយដោយរឿងផ្សេង ។ កំពុងតែនិយាយ បរិព្វាជកបូរាណកណ៌ៈយកចន្ទះថ្មសរីកបាក់គោះដបូកៗ ធ្វើយាំងនេះញឹកញាយណាស់ ដើម្បីបំភ័យបន្ទាបខ្ញុំឲ្យចេញរត់ទៅ ។ ឯបរិព្វាជកវិណាកណ៌ៈ កាលឃើញអាការកិរិយាសម្លាញ់ខ្លួនដៅមិនស្រួម កំសួរទៅថា : « សម្លាញ់! សម្លាញ់មានរឿងអ្វី ? បានជាមិនទាំពាស្តាប់ពាក្យខ្ញុំនិយាយសោះ! ជួបជាមានរឿងកង្វល់ខ្វល់អ្វីដល់ថ្លូកនាំមិនឲ្យសុខស្រួល! » ។ បរិព្វាជកបូរាណកណ៌ៈធ្វើយតថា: នែសម្លាញ់! ខ្ញុំមិនមែនច្រើងើយតន្តើយទេ ប៉ុន្តែ

www.budinst.gov.kh www.elibraryofcambodia.org

សម្លាញ់មិនមើល គាសត្វកណ្តុរចង្រៃនេះ វាចេះតែមកវាយខ្ញុំ វាលបលោតមកលួចយកគោជនាហារដែលខ្ញុំក្នុងចង្ក្រានេះ យកទៅស៊ុកល់វេលា » ។ ចង្រៃជកវិញាកណ៌ដើរទៅលបមើលដៃកែវនោះ ហើយនឿងឆ្ងល់ខ្លាំងក្នុងចិត្ត ក៏សួរថា : « មេចក៏គាសត្វកណ្តុរនេះ វាលោតទៅគោនចង្ក្រានៅឆ្ងាយបាន បើខ្លួនវាតូច កម្លាំងតិចដូច្នេះហ្ន៎ ? ត្រាះថា ១០៨ ប្រតន្តក្រមុំស្រាប់តែធ្វើមារយាទាញស្រក់ប្តីចាស់ជាតជាប់ថើបហើយចាប់ទះញាក់ញ៉ីតតប្រណី ខ្ញុំសំនងនឹងមុខជាមានហេតុអ្វីឆ្ងល់មិនខាន ។ ចង្រៃជកបូងាកណ៌ៈសួរនឿងនោះថា : « តើរឿងនោះដូចម្តេច ? ។ ចង្រៃជកវិញាកណ៌ៈ តណ៌នារឿងនោះដូច្នេះថា ៖

កថាទី ៥

រឿងតាណ៌ជាចាស់ដរា និង ការយាក្រមុំ

នៅប្រទេសគៅទី(១)មានក្រុងមួយឈ្មោះកោសម្ពី ។ មានតាណ៌ជាម្ចាស់ឈ្មោះចន្ទាសៈ ជាអ្នកមានទ្រព្យសម្បត្តិច្រើន តាស្រ័យនៅក្នុងក្រុងនោះ ។ លុះដល់ចន្ទិមវ័យចាស់ជរាហើយ តាណ៌ជានោះទៅដណ្តឹងស្ត្រីក្រមុំម្ចាស់ឈ្មោះទាឝលិលវតី ជាធីតាសេដ្ឋីម្ចាស់យកមកធ្វើជាភរិយា ព្រោះសេចក្តីស្រឡាញ់ក្នុងកាមកត ទំនងខ្លាំងចង់ព្រោះតាមានទ្រព្យ

១-ប្រទេសឯណ្ឌ (ឥណ្ឌា)

www.budinst.gov.kh www.elibraryofcambodia.org

សម្បត្តិច្រើន ។ ឯនាងកិយោនោះ នៅក្មេងកំពុងតេញតាលក្រមុំខ្ចីល្អក់ ជាស្រីថញ្ចូពិនកល្យាណ៍ គួរជាទីប្រាថ្នាប្រុសក្នុងឆ្នាយ ច្រៀងដូច ជា ទង់សុវណ្ណផ្ការាលជាមានជ័យនៃកាមទេព(*) ។ ឯតាណាជាថ្មីចាស់ជាកមិនតាចញ៉ាំងកិយាក្មេងនោះ ឲ្យរីករាយស្កប់ស្កល់ដោយតាមចានឡើយ ព្រោះថា ៖

๑๑๐- តន្ត្រីត្រជាក់នៃព្រះចន្ទ មិនជាទីតេញចិត្តនៃមនុស្សក្រអា , តន្ត្រីក្តៅនៃព្រះអាទិត្យ មិនជាទីតេញចិត្តនៃមនុស្សក្តៅក្រហល់ក្រហាយ ថ្មីចាស់ជាគ្រាំគ្រាតត្រតតក្រត កំមិនជាទីតេញចិត្តនៃកិយាក្មេងដែរ ។

๑๑๑- ចើថ្មីចាស់មើលទៅយើញសក់ស្កូវសៃត្រាន់ហើយ ឲ្យកិយាក្មេងថ្លាថ្នាកាមរាគដូចម្តេចកើត ? កិយាណា មានចិត្តត្រតល់ ទ្បើទៅប្រុសដទៃទៀតហើយ កិយានោះ ខុកប្លែដូចជាថ្នាំកែរោគ ។ ឯតាចាស់ជាប្លែមានក្តីប្រតិព័ទ្ធស្នេហាចំពោះកិយា ទ្បាំងណាស់ទីឆ្ងល់ពណិនាដូចម្តេចក៏ពុំបានឡើយ ព្រោះថា ៖

๑๑๒ - សេចក្តីថ្នាថ្នាចង់បានត្រឡប់សម្បត្តិ សេចក្តីថ្នាថ្នាចង់ទ្បើមានតាយុយឺនយូរ ជាធម៌តែងមានទៅក្នុងចិត្តនៃសត្វសត្វទាំងឆ្នាយ ឯកិយាក្មេងរូបកាន់តាយស្រស់ឥតខ្ចោះត្រង់ណា ជាធម៌ជូនកណ្តាក

๑- រូបកទេពនៃកាមរោគ ។

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្រ

ជាប់ក្នុងចិត្តដំរៃក្រលែងនៃម្ដាយស់ជកជាងជាវែតទៅទៀត ។

១១៣- មនុស្សម្ដាយស់ជកលុះក្នុងវិស័យនៃកាម ឥន្ទិយរំភោគកាម កំមិនកើត ឬ ឥន្ទិយលះបង់ចោលកាមកំមិនកើតទៀត ដូចសត្វសុនខវែលបាក់ចង្កឹមហើយ ត្រាន់តែបានអង្គៀមយកអណ្ដាតលិឍន្ដឹងតែប៉ុណ្ណោះ។ លំដាប់មកមិនយូរប៉ុន្មាន, នាងលីលាវតីស្ដ្រីចិត្តចោកទៅស្រឡាញ់កម្លោះម្នាក់ជាកូនតាណិជ ឋានរួមទ្វេីយផ្ដេកផ្ដិតស្នេហាកន្ទួលច្រៃតណី ត្រកួល លះបង់ចោលតាជកឥតការល័យ ដោយសេចក្ដីស្រវឹងតាន់វ័យក្មេង ត្រាះថា :

១១៤- កំរៃយោច្រត្រឹត្តតាមចំនេនឥន្ទិយចិត្ត, កំរៃយោទៅកន្លងផ្លូវនៃចិតា, កំរៃយោចូលចិត្តមើលមហោស្រព, កំរៃយោចូលចិត្តសេពគប់នូវយោធាច្រើនឥន្ទិយញាតិ, កំរៃយោចូលចិត្តអង្គុយជិតបុរស, កំរៃយោទៅបាវេទស, សមាគមញយ ។ ដោយស្ដ្រីភាស, វិនាសច្រឡាសម្បត្តិត្រាះចាយវាយផកសណ្ដាប់ធ្នាប់, ស្ងាមិចាស់ជកប្រចណ្ដាបូស្បា ឥន្ទិយស្ងាមីធ្លាប់ណែនាំទៅប្រទេសស្រៅ អស់ពាំងនេះ ជាហេតុនាំឲ្យកំរៃយោក្សត័ចិត្តថ្លើ ។

១១៥ - កំរៃយោផឹកទឹកស្រវឹង១ កំរៃយោទៅច្រឡំចល់ដោយមនុស្សគាក្រក់១ កំរៃយោទៅស្ងាត់ពីស្ងាមី១ កំរៃយោដើរលេង១ កំរៃយោផ្ដេកក្នុងផ្ទះអ្នកដទៃ១ កំរៃយោទៅឆ្ងាយពីស្ងាមី១ ទោសពាំង ៦ ប្រការនេះ

www.budinst.gov.kh www.elibraryofcambodia.org

ជាគ្រឿងប្រទុស្ដនៃស្ដ្រីពាលឥឡាយ ។

๑๑๖- បពិត្រព្រះភាគមានព្រះ ! ស្ដ្រីដែលឈ្មោះថាមានសេចក្ដីស្មោះត្រង់ (សេចក្ដីចំសុទ្ធ) នោះ ដោយសារតែមិនមានកន្លែងស្មាត់ មិនមានឱកាសមួយស្រេចក់ និងមិនមានបុរសច្រើនដូចប៉ុណ្ណោះទេ ។

๑๑๗- ន័យថាបុរសណាស្ដ្រីមិនស្រឡាញ់ក៏មិនមែន . ន័យថាបុរសណាស្ដ្រីស្រឡាញ់ក៏មិនមែនទៀត ដោយពិត, ស្ដ្រីភាព ដូចគោដើរស្មៅកកស្មៅជាអាហារក្នុងព្រៃ តែងប្រាថ្នាខ្ចីស្មៅថ្មី ជានិច្ចរហូតតទៅ ។

๑๑๘- នារីមិនដូចជាឆ្នាំងទឹកញ៉ាំ បុរសមិនដូចក្អែង ហេតុនោះបាន ជាអ្នកប្រាជ្ញ សោកមិនតាមកាល់ពុកឆ្នាំងទឹកញ៉ាំនិងក្អែងក្នុងទីជិតគ្នាទេ ។

๑๑๙-(๑)ធម្មជាតជាស្ដ្រី, ន័យថាអៀនខ្មាសក៏មិនមែន ន័យថាមានខ្នះខ្នែងហើយក៏មិនមែន ន័យថាមានចិត្តស្មោះត្រង់ចំពោះប្ដី ក៏មិនមែន

๑-ហិរោចទេស សេចក្ដីប្រែជាភាសាបារាំងរបស់លោកឡង់ស៊ី មានន័យថាផ្សេងគ្នាខ្លះពីកាលយើងឃើញបុរសស្មៀកពាក់ហ៊ុមហា ទោះបងប្អូន ឬ កូនចៅ ស្ដ្រីភាពដែងសំដែងសេចក្ដីប្រាថ្នាឲ្យដឹងខុសភ្លាមៗ ទី! តាបសនារទ: នេះជាសេចក្ដីពិតដូចពាក្យដែរ ។ សេចក្ដីប្រែជាភាសាសៀម របស់លោក នាគប្រទីប មានន័យថាផ្សេងគ្នាខ្លះ ក- សេចក្ដីពិត ស្ដ្រីភាពមានចិត្តប្រែប្រួលជានិច្ច សូម្បីក្នុងប្រជុំទេវតាក៏មានល្បិចឈ្មោះ បុរសណាអាចប្រសោមនាងបានបុរសនោះ ពុកជាមានវាសនាល្អ ។ ๒-បុរសមិនគួរអង្គុយក្នុងទីស្ងាត់ជាមួយមាតា បងស្រី ឬប្អូនក្រមុំខ្លួន, ពាមនេះ បើទៅរួមគ្នាក្នុងទីស្ងាត់ មានកម្លាំងក្លៀវក្លាណាស់សូម្បីអ្នកប្រាជ្ញក៏ជាក់ឈ្លាក់ងងិតមុខទប់មិនជានែរ ។

www.budinst.gov.kh www.elibraryofcambodia.org

ការគប់មិត្រ

តុំនោះ ឪងឋាមានសេចក្តីភ័យខ្លាចក៏មិនមែនដែរ , សេចក្តីពិត គឺមិនមែនបុរសចង់ នេះជាហេតុនៃសេចក្តីស្មោះត្រង់ (ចរិយុទ្ធ) នៃស្ត្រីតាំងពីបុរាណ ។

១៦០-ម៉ែតាក្បាក្នុងកាលនៅក្មេង , ចង់ប្រុសត្រង់ត្រឹងកាលនៅក្រមុំ កូនប្រុសក្បាកាលដល់វ័យចាស់ជក ស្ត្រីគាតនៅឯកកផ្សំមិនគួរឡើយ ។

តមក ថ្ងៃមួយនាងលីលាវត៍ស្ត្រីចិត្តខ្ចោក កំពុងត្រេកត្រអាលជាមួយគូស្នេហាជាកូនពាណិជលើខែនសយនា ដែលរចនាំរលេចតណាំដំរិចត្រកួរផ្ទេកត្រាលឆ្ពិនផ្ទៅ ទ្រុះធ្លៀលប្រកាត់ដោយកែវមណី និយាយសាសងនៃយូរឆ្ងល់ស្អួកស្ងិនដោយក្តីរីករាយ ស្រាប់តែយើញគាចាស់ជាថ្មើរលេះលោងមកដល់ជិតមិនដឹងខ្លួន គាងក៏ស្ទុះច្រញាច់ច្រញាល់លោតទៅចរគោងកស្ងាម៉ាចាស់ ចាប់ពាញសក់ច្រកៀកប្រឆមដប់ថើបធ្លៃចែបស្ងួនស្ងាលណាស់ ឯកូនពាណិជជាសាហាយ ចាន់ឆកាសកំលុចលាក់ខ្លួនគេចរត់ចេញទៅចាត់ក្លាម ព្រោះថា :

១៦១-តាបស[1]សនា(១) និងព្រះត្រីហស្សតី លោកចេះជឹងកលមាយាសាស្ត្រឯណា កលមាយាសាស្ត្រនោះ ប្រកិស្ងានស្រេចហើយក្នុងច្បាប់នៃស្ត្រីភាព តាមសភាពតាំងតែពីកំណើតមកស្រាប់ ។

ក្បែរណានោះ, មានស្ត្រីឆ្លាសម្នាក់ឈរនៅកន្លែងជិតនោះ ចាន

១-តាបសជាគ្រូពួកអសុរ ។

www.budinst.gov.kh www.elibraryofcambodia.org

ហិរោចទេស

ឃើញគាការកលមាយានាងលីលវតីដូច្នោះ កំនឹកឆ្ងល់ខ្វល់ក្នុងចិត្តឥត
ឧបមា មិនចេញវាចាយ៉ាងថាអ្ហ៎សោះចេះតែគិតមមៃក្នុងចិត្តថា: « មាន
ម៉ោហ៎យ! បើមិនមានរឿងអ្វីថ្មីក នាងនេះមុខជាមិនចេញស្នៀតចាប់ខុស
ជាប់ថើចប្តីចាស់ដូច្នេះទេ » ។ តមក, មិនយូរប៉ុន្មាន ស្ត្រីជាមាសដឹង
រឿងកំពេះអស់ជើង កំត្រូវនាងលីលវតីសួរកូនចាំនាមស្រាក់យ៉ាងច្រើន
ជាតម្លៃជួយលាក់បិទបាំងរឿងការមិនឲ្យមនុស្សដឹងតទៅ ។ ព្រោះហេតុ
នេះបានជាខ្ញុំ (ចរិញ្ញាជកវិណាកណិ:) គោនតាថាមានគាថាថា: « ប្រតន្ត
ក្រមុំ ស្រាប់តែគាញស់ក្តីចាស់ជក » ដូច្នេះជាដើម (១០៩) ។

ចរិញ្ញាជកវិណាកណិ:ត្រង់រៃតថា : « ប្រសៃហាលជាមានហេតុអ្វីមួយ
សំខាន់ខ្លាំងក្នុងចិត្តនោះ បានជាកណ្តុរនេះមានកម្លាំងខ្លាំងម្ល៉េះ ? » តាបស-
ណាមួយស្រែចក់ ទើបតោលថា : « គង់មានទ្រព្យច្រើន ជាប្រភពនៃ
រឿងនេះមិនខាន ព្រោះថា :

១៦៦-សត្វកិច្ចការ ត្រូវចិញ្ចឹម ត្រូវបំពាលវេលា ក្នុងលោកនេះ
បុគ្គលមានទ្រព្យច្រើន ឈ្មោះថាមានកម្លាំង, សេចក្តីពិត . ព្រះរាជាមាន
ភាពជាមហាអំណាច ព្រោះមានទ្រព្យជាមូលហេតុ » ។

លំដាប់នោះ, ចរិញ្ញាជកវិណាកណិ: យកជំនឹកទៅជីកត្រង់ដែលខ្ញុំ
(ចរិណ្ឌកៈ) តាស្រែទៅ ជណ្តើមយកទ្រព្យសម្បត្តិខ្ញុំ ដែលទំនង់

www.budinst.gov.kh www.elibraryofcambodia.org

ខុកមកយូរហើយអស់លើងធេងឯ ។ តាំងពីគេលោះមក ខ្ញុំទៅជាខ្សត់ទ្រព្យអស់ឫទ្ធិអំណាច ទៅឃ្លាយឃ្លាយមាម មិនអាចស្មុះស្មែងរកចំណីអាហារចិញ្ចឹមជីវិតបានទៀយ ចេះតែដើរក្រវេចក្រវៀនទៅមកសន្សឹម ។ តិច។ ដោយសេចក្តីតឹតតែង ឯមវិញ្ញូជក លុះឃើញខ្ញុំធ្លាក់ក្នុងឋានៈដូច្នេះហើយ ក៏គោលថា ៖

១៦៣- ក្នុងលោកនេះ បុគ្គលមានទ្រព្យ ឈ្មោះថាមានកម្លាំង ឈ្មោះថាឋណ្ឌិត, អ្នកចូរមើល ! គាស្រូកណ្តុរចង្រៃនេះ វាធ្លាក់ខ្លួនទៅតាមសភាពដើមវាវិញហើយ ។

១៦៤- បុគ្គលមានការចេះដឹងតិច តាលបើហ៊ានហោចរលំរលោយទ្រព្យអស់ហើយ, កិច្ចការតាំងឡាយឯទៀត ក៏ឈ្មោះថាវិនាសអន្តរធានទៅដែរ ដូចជាស្តីឯមានទឹកអំបិលស្រស់តម្លៃជូរកើនឯស្តុកហួតហែងអស់រលីង។

១៦៥- អ្នកមានទ្រព្យ ឈ្មោះថាមានមិត្រ, អ្នកមានទ្រព្យ ឈ្មោះថាមានផៅពង្ស, អ្នកមានទ្រព្យ ឈ្មោះថាជាបុរស, អ្នកមានទ្រព្យ ឈ្មោះថាជាឋណ្ឌិត ។

១៦៦- ផ្ទះអ្នកមិនមានកូន ជាផ្ទះសោះសូន្យ, នរជនមិនមានមិត្រចិត្តល្អ ជាបុគ្គលសោះសូន្យ, ទិសមនុស្សល្ងង់ខ្លៅ ក៏ជាទិសសោះសូន្យ ឯភាគមនុស្សក្រីក្រ ឈ្មោះថាជាភាពសោះសូន្យ ជាងអ្វីទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ហិតោបទេស

๑๖๗ - (๑)ចើតន្ត្រីយតាំងឡាយមិនវិតលហើយ តើរណ្តែះកំនៅជដែល, ចើត្រាជ្ញាមិនវិចក្ខណៈហើយ រាចាកំនត់នៅជដែលមិនថ្លឹក ចើបុរសត្រាសចាកកម្លាំងព្យាសម្បត្តិអស់លើងហើយ អ្វីជនៃទៀតដែលមិនឈ្មោះថាវលំវលោយទៅកន្លងមួយៗណាៈនោះដែរឬ ? ពុធម្មជាតិអស់នេះគួរឲ្យស្អប់អស្ចារ្យណាស់ហ្ន៎ !

លុះខ្ញុំ (ហិរណ្យកៈ) ចានស្តាប់ពាក្យនេះរួចស្រេចហើយ ក៏ពិនិតិតថា : "ឥឡូវនេះ អាត្មាអញមិនគួរនឹងអាស្រ័យនៅក្នុងទីនេះតទៅទៀតទេ ឬនឹងនិយាយរឿងនេះឲ្យគេឯងដឹងឮទៀតក៏ពុំគួរដែរ, ព្រោះថា :

๑๖๘- អ្នកមានព្រាជ្ញាមិនគួរគប្បីប្រកាស ការរំនាសព្យសម្បត្តិ ការក្តៅក្រហាយចិត្ត ពុះពារ ១ចព្រួតចង្រៃក្នុងផ្ទះ ការត្រូវគេប្រវ័ញ្ចន៍ និងការគេមើលងាយ ឲ្យគេដឹងឮឡើយ ។

๑๖๙- តាយុជវិត , ព្យសម្បត្តិ , គោលជាចន្ទោះក្នុងផ្ទះ, មន្ត្រី (រឿងសម្ងាត់) មេថុន, កេសជ្ជៈ, (ថ្នាំកែកោន) តបធម៌ , ការឲ្យទាន និងការគេមើលងាយ លក្ខណៈ ៥ ប្រការនេះ បុគ្គលគប្បីត្រង់ត្រងរក្សា

๑- ហិតោបទេសសេចក្តីប្រែជាភាសាសៀមរបស់លោកនាគប្រទីបមានគាថាលើសនូវនេះ "បណ្តាសេចក្តីក្រក្រ និង សេចក្តីស្ងាប់ពីប្រការនេះ គេចូលចិត្តសេចក្តីក្រក្រជាងសេចក្តីស្ងាប់ តែដោយពិតសេចក្តីស្ងាប់នាំឲ្យកើតក្តីទុក្ខស្រាលទេ ហើយតែម្តងក៏អស់ទៅ ឯសេចក្តីក្រក្រធ្វើឲ្យកើតក្តីព្រួយយ៉ាងខ្លាំងចំរើនស្ទើតែអត់ត្រាំមិនបាន ។

www.budinst.gov.kh www.elibraryofcambodia.org

ខុសដោយប្រយ័ត្នប្រយែងមែនទែន ។

១៣០- អ្នកមានថ្លាជ្ញា តែខ្សត់ទ្រព្យ បើត្រង់វាសនាមិនជួយ ត្បាយោមថេរប់បុរសកំសត្រយោជន៍ តើនឹងស្វែងរកសេចក្តីសុខដែលណា ក្រៅពីការចូលទៅនៅក្នុងព្រៃ ?

១៣១-អ្នកមានថ្លាជ្ញា៖ បើខុកជាត្រូវស្លាប់ក៏មិនប្រកែក តែមិនត្រមទ្បាក់ខ្លួនទៅជាក្រីក្រទេ ! ដូចជាក្តើងសូម្បីរលត់ហើយក៏មិនត្រមត្រជាក់ ។

១៣២-អ្នកមានថ្លាជ្ញា នឹងថ្លាកូនមានសភាពដូចគ្នា ស្ថិតនៅក្នុងតែ ២ យ៉ាងគឺ: ១ ទៅទំលើកក្បាលនៃនរជនចាំនួនឹង ២ -ស្រោចស្ថិតក្រៀមក្រញ៉ំស្លាប់នៅក្នុងព្រៃ ។

ឯកិរិយាសៅទៅដោយការដើរសូមទានគេចាត់ថ្នឹមជីវិតនេះ មុខតួទ្បាអាម៉ាស់មុខណាស់ហ្ន៎ ! , ត្រោះថា ៖

១៣៣ នរជនថ្លាក់ខ្លួនទៅជាក្រីក្រ លោភទម្លាក់ខ្លួនកន្លងតំនរក្តើងទ្បាស្លាប់ចាត់បង់ជីវិតស្រឡះទៅប្រសើរជាង ការដើរទៅអង្គុតដើតសូមទានគេដែលគេឥតគួរសម កំណាញ់មិនចង់ទ្បាទាន មិនប្រសើរឡើយ ។

១៣៤ សេចក្តីក្រីក្រ នាំទ្បាកើតក្តីអៀនខ្មាស, ក្តីអៀនខ្មាស នាំទ្បាចាត់ក្តីក្លាហាន, ការចាត់ក្តីក្លាហាន នាំទ្បាបុគ្គលដទៃមើលងាយ, ការគេមើលងាយ នាំទ្បាកើតក្តីស្អប់ខ្ពើម, ក្តីស្អប់ខ្ពើម នាំទ្បាកើតសេចក្តីទុក្ខ

www.budinst.gov.kh www.elibraryofcambodia.org

